**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ស្ត្រី និងការអភិវឌ្ឍជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ធី ស្រីអូន**

កញ្ញា **អ៊ី លីណា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ណែនាំដោយ

សាស្ត្រាចារ្យ **ឡឿក ពិដោរ**


ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ស្ត្រី និងការអភិវឌ្ឍជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ធី ស្រីអូន**

កញ្ញា **អ៊ី លីណា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ណែនាំដោយ

សស្ត្រាចារ្យ **ខឿក ពិដោរ**

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរនាក់ ឈ្មោះ **ធី ស្រីអូន** និង**អ៊ី លីណា** ជានិស្សិតផ្នែក រដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៧។

កូនសូមឱនកាយថ្វាយបង្គំ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះទឹកចិត្តអ្នកមានគុណ **លោកឪពុក** និង**អ្នកម្តាយ** ជាទីស្រឡាញ់ស្មើនឹងដួងជីវិតរបស់កូន លោកអ្នកមានគុណទាំងទ្វេបានផ្តល់ក្តីស្រឡាញ់ដល់ពួកយើងតាំងពីតូចរហូតដល់ធំ ប្រកបដោយព្រហ្មណ៍វិហារធម៌ ទោះបីលំបាកនឿយហត់យ៉ាងណាក៏លោកទាំងពីរមិនត្អូញត្អែរដែរ ហើយមិនដែរចង់បានអ្វីពីកូន ក្រៅតែពីចង់ឃើញមានក្តីសុខរស់នៅប្រកបដោយភាពថ្លៃថ្នូរ មានសីលធម៌ មានចំណេះដឹង និងជាធនធានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិ។ គឺលោកបានអប់រំទាំងផ្នែកស្មារតីដើម្បីឱ្យកូនបានទៅរៀនសូត្រមានចំណេះដឹងរហូតបានជោគជ័យដូចថ្ងៃនេះជាគុណូបការៈរបស់លោកឪពុក និងអ្នកម្តាយជាទីស្រឡាញ់របស់កូន។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាដែលបានយកចិត្តទុកដាក់ទៅលើវិស័យអប់រំ បានបង្កើតសាលារៀន គ្រឹះស្ថានសិក្សានានា រីកចម្រើនគ្រប់ទីកន្លែង ដើម្បីងាយស្រួលដល់សិស្ស និស្សិតដែលស្រឡាញ់ការសិក្សាចូលទៅក្រេបជញ្ជក់យកចំណេះដឹងពីគ្រឹះស្ថានទាំងអស់នោះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ និងមន្ត្រីរាជការ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សាស្ត្រចារ្យ ឡឿក ពិដោរ** ដែលលោកបានលះបង់ទាំងកម្លាំងកាយកម្លាំងចិត្ត ព្រមទាំងពេលវេលាក្នុងការជួយណែនាំសារណានេះតាំងពីដើមរហូតដល់ចប់ជាស្ថាពរ។

ជាទីបញ្ចប់ យើងខ្ញុំជាកូននិងជាសិស្សចាំជានិច្ចនៅក្នុងក្រអៅបេះដូងនូវមហាគុណអំណាចដ៏មហិមានេះ សូមសច្ចាតបស្នងគុណ ចំពោះលោកពុក អ្នកម្តាយ និងសាស្ត្រាចារ្យទាំងអស់ដោយក្តីគោរព។ កូនសូមលើកហត្ថាទាំងទ្វេបួងសួងដល់អស់ទេវតា ឥន្ទ្រព្រហ្ម និងវត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោកនេះ សូមជួយតាមថែរក្សាលោកអ្នកមានគុណឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន និងអាយុយឺនយូរដើម្បីជាម្លប់ដ៏ត្រជាក់ និងរឹងមាំដល់កូនចៅ និងនិស្សិតទាំងអស់គ្នា។

# អារម្ភកថា

នាងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១៧។ យើងខ្ញុំបានជ្រើសរើសប្រធានបទ **ស្ត្រី និងការអភិវឌ្ឍជាតិ** ដែលក្រុមនាងខ្ញុំបានលើកឡើងចងក្រងជាសៀវភៅនេះសង្ឃឹមថាវាជាប្រធានបទមួយដែលជាជំនួយសម្រាប់មិត្តអ្នកសិក្សា គ្រប់រូបបានយល់អំពីបញ្ហាយេនឌ័រនៅក្នុងសង្គមកម្ពុជាយើងឱ្យកាន់តែច្បាស់ជាងមុន និងជួយធ្វើយ៉ាងឱ្យមានសមភាពយេនឌ័រកើតឡើងច្រើនជាងមុនឱ្យបានគ្រប់ទីកន្លែងផងដែរ។

ទោះបីជាការស្វែងរកឯកសារមកចងក្រងជាប្រធានបទនេះមានការលំបាកយ៉ាងណាក៏ដោយ ក៏នាងខ្ញុំខំស្វះស្វែងរកមកចងក្រងជាសៀវភៅដោយខានពុំបាន ព្រោះទីមួយវាជាកាតព្វកិច្ចក្នុងការសិក្សាទីពីរនាងខ្ញុំយល់ថានៅក្នុងសង្គមកម្ពុជារបស់យើង ស្ត្រីមិនទាន់បានចូលរួមគ្រប់សកម្មភាពក្នុងសង្គមនៅឡើយនោះទេបើធៀបទៅនឹងបុរស។ ទោះបីជាមានការចូលរួមរបស់ស្ត្រីក្នុងវិស័យមួយចំនួនក្តី តែការចូលរួមរបស់ស្ត្រីក៏នៅតែមានកម្រិតទាប។ នៅក្នុងប្រធានបទបានលើកឡើងចំណុចវិជ្ជមានមួយចំនួនដែលស្ត្រីត្រូវតែទទួលបាន ហើយឆ្ពោះទៅគោលដៅសមភាពភេទដើម្បីវឌ្ឍនភាពរបស់នារីផងដែរ ហើយយើងគួរបន្តអនុវត្តន៍ទៅថ្ងៃខាងមុខទៀត ទន្ទឹមនឹងចំណុចវិជ្ជមាននេះ ក៏មានចំណុចអវិជ្ជមានដែរបានលើកឡើងដែលវាជាបញ្ហាក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងសង្គមខ្មែរយើង ដែលធ្វើឱ្យយើងគ្រប់គ្នាធ្វើយ៉ាងណាជួយបញ្ចៀសបញ្ហានេះកុំឱ្យកើតមានឡើងតទៅទៀត។

នាងខ្ញុំសង្ឃឹមថា ប្រធានបទស្តីពី **ស្ត្រី និងការអភិវឌ្ឍជាតិ** វាជាវិភាគទានមួយជួយដល់អ្នកសិក្សាគ្រប់រូប ដើម្បីស្វែងយល់អំពីបញ្ហាយេនឌ័រនៅក្នុងសង្គមខ្មែរយើង ក៏ដូចជាសិទ្ធិមួយចំនួនដែលស្ត្រីត្រូវតែទទួលបានក្នុងច្បាប់កំណត់ មិនថាច្បាប់ជាតិ ឬច្បាប់អន្តរជាតិឡើយ ធ្វើយ៉ាងណានាំគ្នាលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងការបន្ទាបបន្ថោក ដល់តម្លៃស្ត្រីឱ្យមានសមភាពយេនឌ័ររវាងបុរស និងស្ត្រី លើសពីនេះទៅទៀតត្រូវផ្តល់ឱកាសឱ្យស្ត្រីចូលរួមក្នុងសង្គមឱ្យបានច្រើន។ ថ្វីត្បិតតែការសរសេរចងក្រងជាសៀវភៅនេះក្រុមរបស់នាងខ្ញុំមានការត្រួតពិនិត្យយ៉ាងណាក៏ដោយ វាមិនប្រាកដថាគ្មានចន្លោះប្រហោងនោះទេ ខ្ញុំជឿជាក់វាពិតជាមានកំហុសឆ្គងណាមួយជាក់ជាមិនខានឡើយ ដូចនេះ សូមមិត្តអ្នកសិក្សា ក៏ដូចជាមិត្តអ្នកអាន ជួយកែសម្រួលកំហុសឆ្គងនោះដោយក្តីអនុគ្រោះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ស្ត្រីកម្ពុជា**

**១.១. ស្ត្រីកម្ពុជាអតីតកាល** ........................................ ៤

១.១.១. ស្ត្រីក្នុងគ្រួសារ ........................................ ៤

១.១.២. ការរៀនសូត្ររបស់ស្ត្រី ........................................ ៧

**១.២. ស្ត្រីកម្ពុជាបច្ចុប្បន្ន** ........................................ ៨

១.២.១. ការបង្កើតទិវាសិទ្ធិនារីអន្តរជាតិ ........................................ ៨

១.២.២. ការផ្លាស់ប្តូរតួនាទីស្ត្រីនាពេលបច្ចុប្បន្ន ........................................ ១១

**ជំពូកទី២**

**ការចូលរួមរបស់ស្ត្រីក្នុងវិស័យសំខាន់ៗ**

**២.១. ស្ត្រីក្នុងវិស័យសំខាន់ៗ** ........................................ ១៣

២.១.១. វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ........................................ ១៣

២.១.១.១. វិស័យសេដ្ឋកិច្ច ........................................ ១៣

២.១.១.២. វិស័យសង្គមកិច្ច ........................................ ១៥

២.១.២. វិស័យនយោបាយ ........................................ ១៦

២.១.៣. វិស័យសុខាភិបាល ........................................ ១៧

២.១.៤. វិស័យបច្ចេកវិទ្យា និងឌីជីថល ........................................ ១៨

២.១.៥. វិស័យអប់រំ ........................................ ២២

២.១.៥.១. ការអប់រំនៅបឋមសិក្សា ........................................ ២២

២.១.៥.២. ការអប់រំនៅមធ្យមសិក្សា និងកំរិតឧត្តមសិក្សា ........................................ ២៣

២.១.៥.៣. ការហ្វឹកហ្វឺនជំនាញ និងវិជ្ជាជីវៈ..........២៤
**២.២. ស្ត្រីខ្លាំងកម្ពុជា**..........២៤
២.២.១. លោកយាយដូនពេញ..........២៤
២.២.២. ព្រះនាងឥន្ទ្រទេវី..........២៦
២.២.៣. លោកជំទាវបណ្ឌិត ពេជ ចន្ទមន្នី..........២៧
២.២.៤. អ្នកនាង រស់ រតនៈ (Chef Nak)..........២៨

## ជំពូកទី៣

## ផលវិបាក និងដំណោះស្រាយ

**៣.១. ផលវិបាក**..........៣១
៣.១.១. បញ្ហាប្រឈមរបស់ស្ត្រីក្នុងការចូលរួមវិស័យនយោបាយ..........៣២
៣.១.១.១. បុរសជាគំរូនៃវិស័យនយោបាយ..........៣២
៣.១.១.២. ឧបសគ្គក្នុងសង្គម-សេដ្ឋកិច្ច..........៣២
៣.១.១.៣. ខ្វះទំនុកចិត្ត និងការគាំទ្រពីសង្គម និងសមាជិកគ្រួសារ..........៣៣
៣.១.២. ឧបសគ្គរាំងការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យានៅកម្ពុជា..........៣៤
**៣.២. ដំណោះស្រាយ**..........៣៥
៣.២.១. អនុសញ្ញាស្តីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី..........៣៥
៣.២.១.១. វិធានការទូទៅដើម្បីលុបបំបាត់ការរើសអើង..........៣៦
៣.២.១.២. គណកម្មាធិការ CEDAW..........៣៩
៣.២.២. ក្រសួងកិច្ចការនារី..........៤០
៣.២.២.១. ការបង្កើតក្រសួងកិច្ចការនារី..........៤០
៣.២.២.២. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី..........៤០

សេចក្តីសន្និដ្ឋាន ....................................................................................................................៤៥
អនុសាសន៍ ...........................................................................................................................៤៧
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅគ្រប់សម័យកាលណាក៏ដោយដើម្បីកសាងសង្គមជាតិឱ្យមានការរីកចម្រើនលូតលាស់ទៅមុខបានល្អ ចាំបាច់ត្រូវមានការចូលរួមសកម្មភាពរបស់ស្ត្រីដែរមិនអាចខ្វះបាន។ ទោះបីការងារនេះតូចក្តីធំក្តីត្រូវតែមានស្ត្រីចូលរួមជាសមាជិក។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ស្ត្រីចូលរួមចំណែកយ៉ាងសំខាន់ និងមើលឃើញនៅក្នុងការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និងសង្គម។ ការរួមចំណែកទាំងនេះ គឺជាការចូលរួមយ៉ាងសំខាន់សម្រាប់សុខុមាលភាពគ្រួសារ និងសហគមន៍ ជាពិសេសក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ នៅក្នុងគ្រួសារភាគច្រើនស្ត្រីគឺជាអ្នកទទួលខុសត្រូវលើផ្នែកអាហារូបត្ថម្ភ ការអប់រំ និងការការពារសុខភាពរបស់សមាជិកក្រុមគ្រួសារ និងសហគមន៍ទាំងមូល។ ប៉ុន្តែ ស្ត្រីតែងតែទទួលបាននូវការអប់រំ ការថែរក្សាសុខភាព ឱកាសការងារ និងប្រកបអាជីវកម្មតិចតួចបើធៀបទៅនឹងបុរស។ ជាប្រពៃណី ស្ត្រីមានតួនាទីតិចជាងបុរសនៅក្នុងឆាកនយោបាយ ដែលនេះជាការរារាំងមួយក្នុងការចូលរួមអោយបានសកម្មនៅក្នុងការសម្រេចចិត្តដែលពាក់ព័ន្ធដល់សុខុមាលភាព និងការរស់នៅរបស់ពួកគេ។ មានមនុស្សជាច្រើនដែលមានគំនិតសុទិដ្ឋិនិយមអំពីការកើនឡើងនូវការចូលរួមរបស់ស្ត្រី ព្រោះគេបានគិតថាមានស្ត្រីជាតំណាងនៅក្នុងវិស័យនយោបាយនឹងកាន់តែនាំមកនូវការអភិវឌ្ឍនៅក្នុងសហគមន៍ គេយល់ថាអ្នកដឹកនាំជាស្ត្រីមានការប្តេជ្ញាចិត្តខ្ពស់ និងចូលរួមនៅក្នុងសហគមន៍សកម្មជាងបុរស ស្ត្រីមានភាពជាអ្នកដឹកនាំខ្ពស់ក្នុងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាំងក្នុងកិច្ចការសង្គម និងសេដ្ឋកិច្ច។ ការចូលរួម និងការដឹកនាំរបស់ស្ត្រីអាចជួយដល់ការងារលើកកម្ពស់កំរិតជីវភាពរបស់ប្រជាជនខ្មែរទាំងមូល និងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា ដែលក្នុងនោះគោលដៅទី៣ ស្តីពីការលើកកម្ពស់ សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ ការជម្រុញអោយមានការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅតែជាបញ្ហាប្រឈមដែលត្រូវដោះស្រាយដូចជា បញ្ហាជំនឿ ដែលចាត់ទុកថាស្ត្រីមិនសក្តិសមនឹងតំណែងធំៗ ឬចូលរួមនៅក្នុងសេចក្តីសម្រេចចិត្ត។ ស្ត្រីត្រូវទទួលបន្ទុកបន្ថែមជាអ្នកមើលថែទាំ និងទទួលខុសត្រូវការងារផ្ទះសម្បែងដែលទាំងនេះនៅតែជាបញ្ហាចំបង ដែលរារាំងស្ត្រីក្នុងការចូលរួមក្នុងឆាកនយោបាយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

- តើពេលបច្ចុប្បន្ន យេនឌ័របានចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិយ៉ាងដូចម្តេច ?
- តើស្ត្រីមានតួនាទីយ៉ាងណាដែរដល់ការអភិវឌ្ឍនសង្គមរបស់កម្ពុជា ?

- តើតួនាទីរបស់ស្ត្រីក្នុងសង្គមកម្ពុជាយើងបានផ្លាស់ប្តូរយ៉ាងណាដែរពីអតីតកាលរហូតមកបច្ចុប្បន្ន ?
- ខណៈពេលដែលកម្ពុជានិងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ តើសមភាពយេនឌ័រមានសារៈសំខាន់យ៉ាងណាដែរសម្រាប់កម្ពុជាក្នុងការសម្រេចគោលដៅនេះ ?
- តើអ្វីទៅជាឧបសគ្គក្នុងការរាំងការផ្សព្វផ្សាយ ក៏ដូចជាការអប់រំពីការលើកកម្ពស់សិទ្ធិស្ត្រីនៅក្នុងប្រទេសកម្ពុជា ?
- តើការរើសអើងប្រឆាំងនឹងស្ត្រីគឺជាអ្វី ?
- តើអនុសញ្ញា CEDAW មានកាតព្វកិច្ចអ្វីខ្លះដល់រដ្ឋាភិបាល ?
- តើអនុសញ្ញានេះអនុវត្តយ៉ាងដូចម្តេចនៅប្រទេសកម្ពុជា ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងដែលជំរុញឱ្យនាងខ្ញុំទាំងពីរនាក់ លើកយកប្រធានបទ «**ស្ត្រី និងការអភិវឌ្ឍជាតិ**» មកធ្វើការវែកញែក ព្រោះយើងមានគោលបំណងដូចខាងក្រោម៖

- ពង្រឹងឆន្ទៈ និងការប្តេជ្ញាចិត្តលើការលើកកម្ពស់សមភាពយេនឌ័រក្នុងការដឹកនាំ និងការគ្រប់គ្រងកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពង្រឹង និងកែលម្អប្រព័ន្ធគ្រប់គ្រងនីតិវិធី និងរបៀបរបបអនុវត្តការងាររបស់រដ្ឋបាល ថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងសមភាពយេនឌ័រ
- ពង្រឹង និងកែលម្អប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងសមភាពយេនឌ័រ
- ពង្រឹង និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងសមភាពយេនឌ័រ។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃការស្រាវជ្រាវប្រធានបទមួយនេះបានកំណត់សមភាពយេនឌ័រ និងបង្កើតភាពអង់អាចដល់ស្ត្រី និងក្មេងស្រីទាំងអស់តាមរយៈការលប់បំបាត់នៃការរើសអើងប្រឆាំងនិងស្ត្រី និងក្មេងស្រី។ ហើយក្រុមនាងខ្ញុំ និងធ្វើការសិក្សាស្រាវជ្រាវនូវឯកសារដែលពាក់ព័ន្ធនិងធ្វើការបកស្រាយនូវរាល់ព័ត៌មានដែលទទួលបានពីការស្រាវជ្រាវអោយមានខ្លឹមសារ និងអត្ថន័យសម្រាប់សារណានាងខ្ញុំ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់នាងខ្ញុំទាំងពីរនាក់ជាពិសេសដល់មិត្តនិស្សិត សិស្សប្អូន អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ និងសាធារណៈជនទាំងអស់ឱ្យបានយល់កាន់តែច្បាស់អំពីស្ត្រី និងក្មេងស្រីបានចូលរួមចំណែកអ្វីខ្លះក្នុងការអភិវឌ្ឍសង្គមមួយ ឬប្រទេសមួយឲមានការរីកចម្រើន។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ និងបកស្រាយនូវប្រធានបទខាងលើ នាងខ្ញុំទាំងពីរនាក់បានធ្វើការស្រាវជ្រាវនូវរាល់ឯកសារដែលពាក់ព័ន្ធនឹងស្ត្រី និងឯកសារមួយចំនួនទៀតក៏ទទួលបានបណ្ណាវបសាយ ឬប្រព័ន្ធផ្សព្វផ្សាយនានាលើអនឡាញផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទមួយនេះ គឺបានបែកចែកជា៣ជំពូកគឺ៖

- ជំពូក១ ស្ត្រីកម្ពុជា ក្នុងនោះមានបែងចែកជា២ផ្នែកទៀត គឺផ្នែកទី១ ស្ត្រីកម្ពុជាអតីតកាល ផ្នែកទី២ ស្ត្រីកម្ពុជាបច្ចុប្បន្ន
- ជំពូក២ ការចូលរួមរបស់ស្ត្រីក្នុងវិស័យសំខាន់ៗ ក្នុងនោះមានបែងចែកជា២ផ្នែកទៀត គឺផ្នែកទី១ ស្ត្រីស្ត្រីក្នុងវិស័យសំខាន់ៗ ផ្នែកទី២ ស្ត្រីខ្លាំងកម្ពុជា
- ជំពូកទី៣ ផលវិបាក និងដំណោះស្រាយ ក្នុងនោះមានបែងចែកជា២ផ្នែកទៀត គឺផ្នែកទី១ ផលវិបាក ផ្នែកទី២ ដំណោះស្រាយ

# ជំពូកទី១

# ស្ត្រីកម្ពុជា

# ជំពូកទី១
# ស្ត្រីកម្ពុជា

## ១.១. ស្ត្រីកម្ពុជាអតីតកាល

### ១.១.១ ស្ត្រីក្នុងគ្រួសារ

កម្ពុជាគឺជាប្រទេសមួយដែលកំពុងវិវត្តន៍ខ្លួនពីប្រទេសកំពុងអភិវឌ្ឍន៍ឆ្ពោះទៅជាប្រទេសអភិវឌ្ឍមួយដូចបណ្តាប្រទេសនានានៅលើពិភពលោកដែរ ហើយនៅក្នុងការប្រតិបត្តិលើគ្រប់វិស័យនោះ កម្ពុជាបាននឹងកំពុងតែលើកកម្ពស់ការយល់ដឹងសង្គមដល់ប្រជាពលរដ្ឋទាំងពីរភេទ ក្នុងការផ្តល់នូវភាពក្លាហានដល់យេនឌ័រក្នុងការបំពេញភារកិច្ចរបស់ខ្លួន គឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់ នឹងជាទីមោទនៈផងដែរ។ យ៉ាងណាមិញ ការផ្តល់ភាពក្លាហានចំពោះស្ត្រីនៅក្នុងប្រទេសកម្ពុជាយើង ក៏មានការយកចិត្តទុកដាក់ជាពិសេសផងដែរ គឺស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គមស្ទើរគ្រប់វិស័យពោលគឺ ស្ត្រីពិតជាមានភារកិច្ចយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការជួយបង្កើនសេដ្ឋកិច្ចគ្រួសារ ហើយស្ត្រីក៏ជាឆ្អឹងខ្នងដ៏សំខាន់ក្នុងការជួយបង្កើនសេដ្ឋកិច្ចសង្គម កម្ពុជាដែលមិនអាចខ្វះបាន។ ហើយបើយើងសង្កេតជាទូទៅឃើញថា ទាំងអង្គការសង្គមស៊ីវិល ក៏ដូចជាក្រសួង មន្ទីរ នឹងស្ថាប័នមួយចំនួនដែលមានទាំងក្រសួងកិច្ចនារីផងដែរ បានកត់សម្គាល់ឃើញថា បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវគោលនយោបាយលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រីក្នុងសង្គមយ៉ាងណាក៏ដោយ ក៏គេនៅតែសង្កេតឃើញថា បញ្ហាយេនឌ័រ ជាពិសេសស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួនក្នុងការរួមចំណែកអភិវឌ្ឍន៍គ្រួសារ និងសង្គមជាតិខ្លួនដែលបញ្ហានេះ រាជរដ្ឋាភិបាលបាននឹងកំពុងពង្រឹង និងពង្រីកការយកចិត្តទុកដាក់បន្ថែមទៀតចំពោះស្ត្រី។ ទន្ទឹមនឹងការយកចិត្តទុកដាក់ពីសង្គមនេះ ស្ត្រីខ្លួនឯងក៏គួរតែត្រូវខិតខំពង្រីកចំណេះដឹងពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីជម្នះរាល់ឧបសគ្គឈានទៅរកភាពជោគជ័យក្នុងតួនាទីនិងភារកិច្ចរបស់ខ្លួនជាស្ត្រី។ បើយោងតាមការអង្កេតជាទូទៅ ស្ត្រីជាផ្នែកមួយនៃដំណើរការរបស់យុទ្ធនាការសិទ្ធិស្ត្រី ក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌។ ស្ត្រីគឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ សង្គម និងគ្រួសារ ប៉ុន្តែជាញឹកញយស្ត្រីត្រូវបានសង្គម និងគ្រួសារបំភ្លេចចោល ហើយយកការចូលរួមនៅក្នុងសង្គមរបស់ស្ត្រី គឺជារឿងធម្មតាទៅវិញ។ បច្ចុប្បន្នមានបុរសស្វាមី ឬក្រុមគ្រួសារមួយចំនួនបានលើកឡើងនូវពំនោលថា ភរិយា ម្តាយ ឬបងប្អូនស្រីរបស់ខ្លួនមិនមានធ្វើអ្វីទេ គឺនៅតែផ្ទះ។ តែទន្ទឹមនឹងពំនោល ស្ត្រី នៅតែផ្ទះនេះ គឺការងារ១០០ជំពូកស្ថិតក្នុងកណ្តាប់ដៃស្ត្រីដែលជាអ្នកនៅផ្ទះនោះ គឺស្ត្រីជាកម្មករក្នុងគ្រួសារ ស្ត្រីជាអ្នកបោសជូតបោកគក់ ស្ត្រីជាចុងភៅ ស្ត្រីជាអ្នកមើលថៃកុមារនិងមនុស្សចាស់ជរា ក៏ដូចជា ការមើលការខុសត្រូវនូវរាល់ការងាររាក់ជ្រៅសព្វយ៉ាង ដែលស្ត្រីមិនដែលបានទទួលកម្រៃថ្លៃឈ្នួល

ពីការងារទាំងនោះទេ។ ដូច្នេះ «ក្នុងនាមយើងជាស្ត្រី និងក្នុងនាមយើងជាមនុស្សនៅក្នុងសង្គម យើងត្រូវដឹងឱ្យបានច្បាស់ថា ស្ត្រីជាកម្លាំងចលករ ស្ត្រីជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ច ស្ត្រីជាផ្នែកមួយដ៏សំខាន់ដែលធ្វើឱ្យសង្គមជាតិ សង្គមគ្រួសាររឹងមាំ ស្ត្រីមិនមែនជាជនរងគ្រោះ ឬជាជនទន់ខ្សោយនោះឡើយ»។ ពាក់ព័ន្ធនឹងការផ្តល់ភាពអង់អាចក្លាហាន និងការលើកកម្ពស់ចំពោះស្ត្រី ការផ្តល់ភាពអង់អាចក្លាហានផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ ត្រូវបានគេចាត់ទុកថាវាជាយុទ្ធសាស្ត្រចាំបាច់ក្នុងការផ្លាស់ប្តូរផ្នត់គំនិតនៃការគិតគូរអំពីគម្លាតយេនឌ័រនៃសេដ្ឋកិច្ច។ យ៉ាងណាមិញប្រទេសកម្ពុជា គឺជាសង្គមសមូហភាពមួយដែលអាចបង្កើនសក្តានុពលភាពនៃធនធានស្ត្រីឱ្យក្លាយទៅជាធនធាន ដែលមានតម្លៃនៅក្នុងសេដ្ឋកិច្ចនិងសង្គមផងដែរ គឺតាមរយៈការលើកកម្ពស់សិទ្ធិស្ត្រី។ តែទោះជាយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួនផងដែរក្នុងការលើកស្ទួយជួយពង្រឹងសេដ្ឋកិច្ចក្នុងគ្រួសាររបស់ខ្លួន។ បញ្ហាប្រឈមទាំងនោះមានដូចជា ស្ត្រីនៅតែប្រឈមនូវបញ្ហាក្នុងការចាប់ផ្តើមដំណើរការពង្រីកនិងពង្រឹងអាជីវកម្មរបស់ខ្លួន ស្ត្រីជាទូទៅនៅតែទទួលបានឱកាស និងការគ្រប់គ្រងចំណូលសេដ្ឋកិច្ចតិចតួចជាងបុរស មិនតែប៉ុណ្ណោះស្ត្រីថែមទាំងទទួលបន្ទុកគ្រួសារ ជាពិសេសសមាជិកចាស់ជរាក្នុងគ្រួសារ និងការងារគ្មានប្រាក់កម្រៃក៏ដូចជាការងារដែលងាយរងគ្រោះជាច្រើន។

យើងទាំងអស់គ្នាបានដឹងហើយថា ការបង្កើនភាពអង់អាចដល់ស្ត្រី គឺជាកត្តាចាំបាច់ក្នុងការផ្លាស់ប្តូរផ្នត់គំនិតនៃការគិតគូរសម្រាប់ការអភិវឌ្ឍនិងកសាងប្រទេស។ មានស្ត្រីមួយចំនួនដែលជាអ្នកធ្វើការតាមរោងចក្រ សហគ្រាសនានាបានយកកម្រៃថវិកាដែលនាងទទួលបានពីការធ្វើការតាមរោងចក្រ និងសហគ្រាសទាំងនោះទៅជួយផ្គត់ផ្គង់ដល់សាច់ញាតិរបស់ខ្លួន ជាពិសេសគឺជួយដល់មាតាបិតាដែលចាស់ជរា និងផ្គត់ផ្គង់ដល់បងប្អូនកូនក្មួយៗដែលកំពុងបន្តការសិក្សានៅតាមភូមិសិក្សានានា។ ដូច្នេះ ការងារតាមរោងចក្រ និងសហគ្រាសក៏បានរួមចំណែកយ៉ាងសំខាន់ជាមួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមកម្ពុជា ហើយរដ្ឋាភិបាលក៏បាននឹងកំពុងតែបង្កើនការពង្រឹង និងពង្រីកការយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិស្ត្រីឱ្យបានច្រើនថែមទៀត ដើម្បីផ្តល់នូវតម្លៃដល់ស្ត្រីដែលបម្រើការងារតាមរោងចក្រទាំងនោះបន្ថែមទៀតផងដែរ ច្បិតសព្វថ្ងៃការឱ្យតម្លៃរបស់សង្គមទៅលើស្ត្រីនៅមានកម្រិតនៅឡើយ។ នាពេលកន្លងមក ស្ត្រីដែលបម្រើការនៅតាមរោងចក្រ សហគ្រាសទាំងនោះតែងតែបានស្នើឱ្យរាជរដ្ឋាភិបាលលើកស្ទួយស្ត្រីឱ្យបានច្រើន ហើយត្រូវផ្តល់តម្លៃស្ត្រីឱ្យបានកាន់តែច្រើន ដ្បិតស្ត្រីអាចធ្វើអ្វីៗបានគ្រប់យ៉ាងទាំងអស់ដែលមានការងារខ្លះបុរសមិនអាចធ្វើបានទៀតផង ប៉ុន្តែស្ត្រីអាចធ្វើបានដូចជា ការពពោះ ការបង្កើតកូន ការចិញ្ចឹមកូនដោយទឹកដោះម្តាយផ្ទាល់ក៏ដូចជាការមើលថែបីបាច់សមាជិកក្នុងគ្រួសារ និងការចិញ្ចឹមបីបាច់ថែរក្សាកូនដោយមានទំនួលខុសត្រូវ។ សព្វថ្ងៃក្រៅពីវិស័យសេដ្ឋកិច្ច ស្ត្រីខ្មែរក៏បានចូលប្រឡូកស្ទើរគ្រប់វិស័យ ទាំងវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ ដែលបានបង្ហាញតាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់កន្លងមក គឺគណបក្សនយោបាយនីមួយៗបានចាប់អារម្មណ៍និងផ្តល់ឱកាសឱ្យស្ត្រីក្លាយជា

បេក្ខជន ហើយកន្លងមកស្ត្រីក៏បានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យ រួមទាំងបញ្ហាដែលស្ត្រីជួបប្រទះក្នុងវិស័យសេដ្ឋកិច្ចទាំងក្នុងគ្រួសារនិងសង្គម និងលើកឡើងពីតម្រូវការរបស់ស្ត្រីក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព សមធម៌ ក៏ដូចជាការពង្រឹងនិងពង្រីកនូវសាមគ្គីភាពនៃចលនាស្ត្រីនៅកម្ពុជា ប៉ុន្តែវាហាក់បីដូចជានៅមានកម្រិតនៅឡើយ។ ដូច្នេះ មុននឹងយើងសិក្សានិងវិភាគឱ្យបានស៊ីជម្រៅចំពោះបញ្ហានេះ យើងគួរស្វែងយល់ពីពាក្យយេនឌ័រជាមុនសិន។

**ន័យនៃពាក្យយេនឌ័រ**

នាពេលបច្ចុប្បន្ន ពាក្យយេនឌ័រតែងតែត្រូវគេប្រើជំនួសឱ្យពាក្យភេទរបស់មនុស្សម្នាក់ (ប្រុស ឬស្រី) និងមានការឱ្យនិយមន័យផ្សេងៗគ្នានូវពាក្យ យេនឌ័រ និងភេទនៅក្នុងវិទ្យាសាស្ត្រសង្គមមានលក្ខណៈខុសគ្នាដូចជា ពាក្យ «**ភេទ**» សំដៅទៅលើខ្លួនប្រាណរបស់នរណាម្នាក់។ ដែលបង្ហាញពីភាពជាស្រី ឬប្រុស របស់ ខ្លួនប្រាណខាងក្រៅរបស់នរណាម្នាក់។ ពាក្យ "**យេនឌ័រ** (**Gender**) " គឺជាភាពស្មើគ្នារវាងបុរស និងស្ត្រីស្តីអំពីសិទ្ធិតួនាទី ការទទួលខុសត្រូវ ការសម្រេចចិត្ត ឧបសគ្គ ឱកាស និងតម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទគ្រប់វិស័យ និងគ្រប់មជ្ឈដ្ឋានទាំងអស់ដែលកំណត់ដោយសង្គមវប្បធម៌ ហើយអាចផ្លាស់ប្តូរបានទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង ឬអាចនិយាយថាជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទី និងទំនួលខុសត្រូវ។ យេនឌ័រក៏ជាការកំណត់របស់គ្រួសារ សហគមន៍ និងសង្គមពាក់ព័ន្ធនឹងការបែងចែកការងារ ការអប់រំ សិទ្ធិអំណាច ឋានៈ និងតួនាទីដល់កូនស្រីកូនប្រុស ស្ត្រី និងបុរស។ យេនឌ័រអាចផ្លាស់ប្តូរកែប្រែបានព្រោះវាជាលក្ខខណ្ឌសង្គមមិនមែនមានពីកំណើតនោះទេ។ ពាក្យ «**យេនឌ័រ**» គឺសំដៅទៅលើបុគ្គលិកលក្ខណៈ និងអត្តចរិតរបស់នរណាម្នាក់ដែលបង្ហាញអំពីអារម្មណ៍ ឬកាយវិការរបស់មនុស្សម្នាក់ថាតើគេដូចមនុស្សស្រី ឬដូចមនុស្សប្រុស។

យេនឌ័រ គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទី ទំនួលខុសត្រូវ ឧបសគ្គឱកាស និងតម្រូវការរបស់បុរសនិងស្ត្រីនៅគ្រប់បរិបទ គ្រប់វិស័យ គ្រប់មជ្ឈដ្ឋាន។ ឧទាហរណ៍ ស្ត្រី និងបុរសអាចធ្វើជាគ្រូបង្រៀន វិស្វករ កម្មករ... ហើយស្ត្រី និងបុរសអាចមើលថែកូន និងមនុស្សចាស់ជាដើម។ យេនឌ័រ សំដៅលើភាពខុសគ្នារវាងបុរសនិងស្ត្រីដែលកំណត់ដោយសង្គម ហើយដែលគេបាន រៀនសូត្រ និងមានការប្រែប្រួលពីពេលមួយទៅពេលមួយ។ យេនឌ័រមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរស និងស្ត្រីទៅតាមវប្បធម៌មួយទៅវប្បធម៌មួយ។ មួយវិញទៀតយេនឌ័រ គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ច និងសង្គមក្នុងការវិភាគនៃតួនាទីទទួលខុសត្រូវ ឧបសគ្គ និងតម្រូវការរបស់បុរស និងស្ត្រីនៅគ្រប់បរិបទទាំងអស់។ ដោយសារយេនឌ័របានបង្កើត

ឡើងដោយសង្គមទើបការកំណត់អំពីតួនាទីតម្រូវការអាទិភាព និងសកម្មភាពរបស់ស្ត្រីមានទំនាក់ទំនងទៅនឹងបរិបទជាក់ស្តែងនៃវប្បធម៌ សាសនា និងសេដ្ឋកិច្ចសង្គម។[១]

### ១.១.២ ការរៀនសូត្ររបស់ស្ត្រី

ការរៀបចំព្រះនគររបស់ខ្មែរ កាលពីដើមកាលណាកូនស្រីរបស់មាតាបិតានឹងបានដល់អាយុ ១៦ឆ្នាំ និងជាកូនស្រីដ៏ពេញបរិបូរណ៍ហើយ ព្រះនាងត្រូវបានឪពុកម្តាយនឹងខំបង្រៀននៅផ្ទះនិងឱ្យចេះអក្សរ ឱ្យចេះលេខគក្កក្បួនតំរាអីមួយចំនួនធំហើយ ព្រោះក្នុងរយៈពេលអាយុ១៦ឆ្នាំ។ ដូច្នេះ សូមនិយាយថយទៅក្រោយបន្តិចថាពីដើមម្តាយ និងឪពុកមានតួនាទីធ្វើជាគ្រូបង្រៀនតាមផ្ទះសម្រាប់កូន ក្មួយ ដែលបានកើតមកក្នុងជំនាន់បុត្ររបស់ខ្លួននោះ ដោយអត់ប្រកាន់ទេ ហើយផ្ទះពីដើមគឺបានធ្វើប្រហាក់ប្រហែលគ្នាមានរានហាលសម្រាប់ទុកឱ្យបង្រៀនក្មេងដែលនៅក្នុងការគ្រប់គ្រងរបស់មាតាបិតា។ លុះកូនស្រីទាំងអស់មានវិជ្ជាជីវៈអក្សរសាស្ត្រ ហើយគេត្រូវបន្តមកយកវិជ្ជាជីវៈ៣ទៀតនៅក្នុងសាលាឥន្ទ្រពត្រ្តបុរី។ ដំបូងបង្អស់កាលណាមានអាយុ ១៦ឆ្នាំហើយ ព្រះអង្គត្រូវហែរមកកាន់សាលាឥន្ទ្រពត្រ្តបុរី សាលានោះត្រូវធ្វើមានស្ពាននោះពីរសង្កាត់ ហើយនៅខាងមុខស្ពាននោះគេហៅ គ្រែដែលមាន៣ទិស ហើយគ្រែដែលមាន៣ទិសនោះគេហៅ គ្រែមេត្រីយ ទៅដល់នោះព្រះមេត្រីយទាំង៣នឹងក៏បានចុះឈ្មោះ បន្ទាប់ពីចុះឈ្មោះនាងគ្រប់ព្រះអង្គទាំង៣អង្គនឹងហើយ ចឹងយើងឃើញថានៅក្នុងនឹងគេមានមន្ត្រីរបស់គេនៅក្នុងវត្តឥន្ទ្រពត្រ្តបុរីនឹងគេហៅសកកែវទេពមានចែកចេញជា៣ មានព្រះអង្គចេក ព្រះអង្គចម ព្រះអង្គជុំលុះបានកត់ឈ្មោះនាងរួចហើយត្រូវបានតែងនាងនោះឱ្យក្លាយទៅជាកូននាគ ដើម្បីដឹងគុណទៅដល់ព្រះកោនាគមនោពោធិសត្តដែលព្រះអង្គបានចាប់បដិសន្ធិពីនាគមកមនុស្ស ហើយបានដឹងគុណទៅដល់នាគល្វោពោធិសត្ត ម្តាយដើមបំផុតរបស់ខ្មែរ តែងបានជានាគហើយ កូននាគនោះក៏ត្រូវបានឆ្លងកាត់ស្ពាននាគ ហើយពីដើមស្ពាននាគនោះនៅក្នុងប្រាសាទឥន្ទ្រពត្រ្តបុរីដែលយើងហៅនគរវត្តសព្វថ្ងៃគឺមានក្រាលកម្រាលប្រាក់ រួចហើយបានឆ្លងពីកម្រាលប្រាក់នឹងទៅយើងឃើញថា គេបានហែរម្តាយឪពុកអីទាំងអស់ណើងនាំគ្នាស្ទួយ ឬក៏សែងកូននឹងទៅតាមចំណង់ចំណូលចិត្តឪពុកម្តាយបញ្ជាក់ភាពដែលត្រូវសម្រេចចិត្តយកកូនស្រីជាទីស្រលាញ់ឱ្យមកកាន់សាលាឥន្ទ្រពត្រ្តបុរី។ នៅក្នុងនោះមាតាបិតានឹងចង់ឱ្យកូននឹងបានមករៀនវិជ្ជាជីវៈដើម្បីឱ្យក្លាយខ្លួនទៅជាស្ត្រីនៃលោកពិតប្រាកដកន្លែងនេះគេចង់និយាយថា យើងសព្វថ្ងៃកូនស្រីរបស់យើងអត់បានរៀនសូត្រវិជ្ជាជីវៈដូចកាលសម័យបូរាណទេ ហើយសព្វថ្ងៃនេះយើងអត់ចេះត្បាញ អត់ចេះរវៃ អត់ចេះប៉ាក់ អត់ចេះស្លរដាំ អត់ចេះធ្វើកិច្ចការមួយចំនួនដែលជាការងារមេផ្ទះដូចសម័យដើមទេ ពេលនោះពេលមានជួបគូរស្រេករក៏ឪពុកម្តាយ

[១] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/២១៦២៦៧-២០២១-១០-១៥-០២-១៣-១៩.html https://ncdd.gov.kh/news-kh/gender-lead-to-happiness/, ដកស្រង់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤

ខ្លះមិនបានដឹង ខ្លះទៅបានដឹងហើយក៏បានជួបគ្នាពេលខ្លី ហើយក៏ត្រូវឈ្លោះប្រកែកគ្នា លែងលះគ្នា ដោយសារតែការយើងមិនបានបង្រៀនកូនចៅរបស់យើងឱ្យស្គាល់ពាក្យថា វិជ្ជាជីវៈស្ត្រី នោះឯង។ ចឹងឃើញថាសាសនាព្រះកោនាគមនោពោធិសត្តពីដើមព្រះនាងនិងក៏បានរៀបចំឱ្យស្ត្រីខ្មែរទាំងអស់បានចូលរៀននៅសាលាឥន្ទ្រពត្របុរីនោះគឺឱ្យរៀនវិជ្ជា៣ ចឹងឪពុកម្ដាយនិងបានជួបកូនស្រីនឹងលើកចុងក្រោយក្នុងពេលដែលនាងនឹងត្រូវបានចូលមកកាន់ទីអារាមដើម្បីបួសរៀនជាចារីយផង បានសិក្សារៀនសូត្រវិជ្ជាជីវៈជាស្ត្រីនោះផង។[២]

## ១.២. ស្ត្រីកម្ពុជាបច្ចុប្បន្ន

### ១.២.១. ការបង្កើតទិវាសិទ្ធិនារីអន្តរជាតិ

ចុងសតវត្សទី១៩ បច្ចេកវិទ្យាបានរីកចម្រើនយ៉ាងខ្លាំងក្លានៅលើសកលលោក ជាពិសេសនៅសហរដ្ឋអាមេរិក និងបណ្ដាប្រទេសដែលមានខឿនឧស្សាហកម្មរីកចម្រើន។ នារី និងកុមារក្រីក្ររាប់លាននាក់ត្រូវបានទាក់ទាញឱ្យចូលធ្វើការនៅក្នុងរោងចក្រសហគ្រាសឯកជននានាទាំងឡាយ។ ម្ចាស់រោងចក្រសហគ្រាសមួយចំនួនមានគំនិតលោភលន់ កេងប្រវ័ញ្ចមិនស្ដាប់ស្ដល់លើកម្លាំងរបស់នារី កុមារ និងកម្មករបានបង្ខំឱ្យពួកគេធ្វើការជាទម្ងន់ក្នុងមួយថ្ងៃពី ១២ម៉ោង ទៅ១៦ម៉ោង ហើយផ្ដល់ប្រាក់បៀវត្សយ៉ាងតិចតួចបំផុត ដោយមិនគិតពីសុខភាពរបស់កម្មករឡើយជាហេតុធ្វើឱ្យនារី និងកុមារទាំងនោះត្រូវរស់នៅក្នុងជីវភាពដុនដាបលំបាកវេទនា។ ដោយការឈឺចាប់យ៉ាងពុះពារចំពោះអំពើកៀបសង្កត់កេងប្រវ័ញ្ចហួសប្រមាណនោះនៅថ្ងៃទី៨ មីនា ឆ្នាំ១៨៩៩ កម្មការិនីផ្នែកតម្បាញ និងកាត់ដេរនៅទីក្រុងស៊ីកាហ្គោ និងញូវយ៉ក សហរដ្ឋអាមេរិក បានសាមគ្គីឯកភាពគ្នាក្រោកឈរឡើងតស៊ូយ៉ាងប្ដូរផ្ដាច់ទាមទារឱ្យបន្ថយម៉ោងធ្វើការ និងដំឡើងប្រាក់បៀវត្ស។ ប៉ុន្តែ ជាលទ្ធផល កម្មការិនីទាំងនោះត្រូវបានទទួលការកៀបសង្កត់យ៉ាងពេញទំហឹងត្រូវគេចាប់ចងធ្វើទារុណកម្ម និងត្រូវបណ្ដេញចេញពីរោងចក្រ។ ទោះបីត្រូវទទួលការឈឺចាប់ និងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរក៏ដោយ កម្មការិនីនៅតែសាមគ្គីគ្នាយ៉ាងជិតស្និទ្ធ តស៊ូស្វិតស្វាញ ងើបឈរឡើងតវ៉ាប្រឆាំងជាសាធារណៈម្ដងហើយម្ដងទៀតបង្ខំឱ្យម្ចាស់រោងចក្រសហគ្រាសត្រូវតែទទួលយល់ស្របតាម។ ដំណើរតស៊ូនៃកម្មការិនីទាំងនោះបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះចលនានារីពលករលើសកលលោកទាំងមូល។ ចលនាដ៏ស្វិតស្វាញនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនារីពលករនៅប្រទេសអាឡឺម៉ង់ដែលជាប្រទេសឧស្សាហកម្មធំមួយនាសម័យនោះ។ នៅប្រទេសអាឡឺម៉ង់ក្នុងពេលនោះ បានលេចឡើងនូវយុវនារី ៣រូបដ៏ល្បីល្បាញគឺ អ្នកស្រី ក្លារ៉ា ស្សេតគិន ជនជាតិអាឡឺម៉ង់ និងរ៉ូស្សាលុមស្ស័ប្បេរ ជនជាតិប៉ូឡូញ ដែលបានចូលរួមគ្នាយ៉ាងជិតស្និទ្ធជាមួយអ្នកស្រី គ្រុបស្កាយ៉ា (ភរិយាលោកឡេនីន) បំផុស

[២] គេហទំព័រ https://khmerhistorydiscovery.wordpress.com/២០២០/០៦/១៦/khd-៥៧-learn-baley-khmer/, ដកស្រង់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤

ចលនាបង្កិតបានជាគណៈលេខាអន្តរជាតិដើម្បីដឹកនាំចលនានារី។ បន្ទាប់មកនៅឆ្នាំ១៩១០ សន្និបាតអន្តរជាតិនារីដែលមានប្រទេស ១៧ ចូលរួមបានធ្វើឡើងនៅទីក្រុងកូប៉ែនហាក រដ្ឋធានីនៃប្រទេសដាណឺម៉ាក បានសម្រេចយកថ្ងៃ ៨ មីនា "**ទិវានារីអន្តរជាតិ**" ថ្ងៃមហាសាមគ្គីតស៊ូរបស់នារីពលករទូទាំងសាកលលោក ដើម្បីសិទ្ធិសេរីភាពប្រជាធិបតេយ្យដោយភ្ជាប់ជាមួយនឹងពាក្យស្លោកថា **«មួយថ្ងៃធ្វើការប្រាំបីម៉ោង» «ធ្វើការស្មើគ្នាបៀវត្សស្មើគ្នា»**, **«ការពារសុខភាពមាតា និងទារក»**។ ចាប់តាំងពីថ្ងៃនោះមក ថ្ងៃទី៨ មីនាបានក្លាយទៅជាថ្ងៃបុណ្យអន្តរជាតិនារី ដែលរំឭកអំពីការតស៊ូរបស់នារីពលករទូទាំងសកលលោក ដែលប្រឹងប្រែងដើម្បីរំដោះនារីដោយទាមទារឱ្យអនុវត្តសិទ្ធិស្មើភាពរវាងបុរស និងនារី។ គឺដោយសារតែមានកិច្ចប្រឹងប្រែងដោយអំណត់ និងពុះពារនឹងការលំបាកគ្រប់បែបយ៉ាងពី ១០០ ឆ្នាំមុននេះ ហើយទើបបច្ចុប្បន្ននេះ នារីក្នុងពិភពលោកមានឱកាសទទួលបាននូវសិទ្ធិស្មើភាពក្នុងការបន្ទុះបង្អាប់ខ្លះៗក៏ដោយ។ លទ្ធផលដ៏គ្រចះគ្រចង់នេះបានកាត់បន្ថយអស់ជាច្រើននូវអំពើហិង្សា និងការរើសអើងចំពោះនារីភេទដែលគេតែងចាត់ទុកជាភេទទន់ខ្សោយនោះ។ ជាបន្ទាប់ចលនានារីអន្តរជាតិបានខិតខំដោះស្រាយបញ្ហានារីដែលនៅសេសសល់តាមរយៈការស្នើឡើងទៅអង្គការសហប្រជាជាតិដោយសន្និសីទនារីជាច្រើនលើកច្រើនសារ។ នៅឆ្នាំ១៩៧៥ សន្និសីទពិភពលោករបស់នារីលើកទី១បានធ្វើឡើងនៅទីក្រុងម៉ិចស៊ិចកូ ប្រទេសម៉ិចស៊ិច ក្រោមប្រធានបទ «**សមភាពវឌ្ឍនភាព និងសន្តិភាព**»។ ផែនការសកម្មភាពដែលបានសម្រេចនៅពេលនោះ គេបានអំពាវនាវឱ្យមានការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងរៀបចំទម្រង់ការដ៏មានប្រសិទ្ធភាពសម្រាប់អនុម័តអនុសញ្ញានេះ។ ខែតុលាឆ្នាំ១៩៧៥ ដដែលអង្គការសហប្រជាជាតិបានប្រកាសថាពីឆ្នាំ១៩៧៦ ដល់ ១៩៨៥ ជាសតវត្សសម្រាប់នារី។

នៅឆ្នាំ១៩៨០ សន្និសីទពិភពលោកលើកទី២ របស់នារីបានធ្វើឡើងនៅទីក្រុងកូប៉ែនហាក ប្រទេសដាណឺម៉ាក ដើម្បីពិនិត្យមើលការរីកចម្រើន និងការអនុវត្តផែនការសកម្មភាពដែលកំណត់ក្នុងសន្និសីទលើកទី១ និងគ្រោងទុកនូវខ្សែលើកយកមកពិភាក្សា គឺការអប់រំការងារ និងសុខភាព។ ឆ្នាំ១៩៨៥ ចុងបញ្ចប់នៃទសវត្សនារីគេបានរៀបចំសន្និសីទលើកទី៣ម្តងទៀត នៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា ដើម្បីពិនិត្យ និងវាយតម្លៃលើលទ្ធផលសម្រេចរបស់ទសវត្សនារីព្រមទាំងធ្វើការអនុម័តលើយុទ្ធវិធីចម្រើនទៅមុខសម្រាប់ភាពលូតលាស់របស់នារីក្នុងឆ្នាំ២០០០។ នៅចុងក្រោយនេះ គឺឆ្នាំ១៩៩៥ ពីថ្ងៃទី៤ ដល់ថ្ងៃទី១៥ ខែកញ្ញា អង្គការសហប្រជាជាតិបានរៀបចំសន្និសីទនារីពិភពលោកលើកទី៤ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។ ប្រធានបទជាគោលគឺ «**សមភាពវឌ្ឍនភាព និងសន្តិភាព**» ដដែលតែនៅបានបន្ថែមក្នុងកិច្ចពិភាក្សានូវកង្វល់ របស់នារីថែមទៀតគឺ «**ភាពក្រីក្រ ការអប់រំ អំពើហឹង្សា ផលវិបាកនៃជម្លោះ អាវុធ**» នារីក្នុងរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ចតួនាទីនារីក្នុងការធ្វើសេចក្តីសម្រេចចិត្ត យន្តការលើកកម្ពស់ការរីកចម្រើនរបស់នារី សិទ្ធិនារីលើប្រព័ន្ធផ្សព្វផ្សាយបរិស្ថាន និងបញ្ហាកុមារី។ ទាំងនេះគឺជាយុទ្ធសាស្ត្រ និងរបៀបដោះស្រាយរបស់នារីដែលតែងតែអនុវត្តតាមបែប

សន្តិវិធីតាមការបញ្ចេញមតិតែប៉ុណ្ណោះ។ ឯលទ្ធផលដែលនារីទទួលបាន គឺការផ្តល់នូវសិទ្ធិស្មើភាពឱ្យបានគ្រប់គ្រាន់ និងតម្លៃជាមនុស្ស ពោលគឺពុំមានទាមទារអ្វីឱ្យលើសពីនេះឡើយ។

ទិវានារីអន្តរជាតិ ៨មីនា ជាទិវាមួយដែលនារីជុំវិញពិភពលោកប្រារព្ធពិធីដើម្បីរំឭកអបអរសាទរនូវប្រវត្តិនៃការទាមទារសិទ្ធិរបស់ខ្លួន។ ទិវានេះក៏ត្រូវបានអង្គការសហប្រជាជាតិប្រារព្ធនិងអបអរសាទរផងដែរ លើសពីនេះទៅទៀតក៏មានប្រទេសជាច្រើនបានកំណត់យកទិវានេះថាជាថ្ងៃបុណ្យជាតិរបស់ខ្លួនថែមទៀតផង។ កន្លងមក នារីក្នុងលោកតែងត្រូវបែងចែកដោយព្រំដែនជាតិ ដោយជាតិពន្ធខុសគ្នា ដោយភាពខុសគ្នាខាងភាសា វប្បធម៌ សេដ្ឋកិច្ច និងនយោបាយជាដើម។ ប៉ុន្តែ ក្រោយពេលនារីក្នុងលោកចាប់ផ្តើមទាមទារសិទ្ធិសេរីភាពបានទទួលជោគជ័យ ទិវានារីថ្ងៃទី៨ ខែមីនា ត្រូវបានគេប្រារព្ធរំឭក និងអបអរសាទរជារៀងរាល់ឆ្នាំ។ ការបង្កើតពិធីទិវានារីនេះឡើង គឺក្នុងគោលបំណងរំឭកឡើងវិញនូវប្រពៃណីនៃការតស៊ូរបស់នារីក្នុងសម័យអតីតកាល ដើម្បីសមភាព យុត្តិធម៌ សន្តិភាព និងអភិវឌ្ឍន៍។

ដោយឡែកនៅប្រទេសកម្ពុជា គេតែងចាត់ទុកថាសង្គមខ្មែរជាសង្គមមេនិយម គឺការឱ្យតម្លៃស្ត្រីជាធំ ជារបបមាតាធិបតេយ្យ។ ក្នុងជីវភាពប្រចាំថ្ងៃយើងឃើញមានភស្តុតាងជាច្រើនដែលខ្មែរបានឱ្យតម្លៃស្ត្រី ជាក់ស្តែងដូចជាការរក្សាវប្បធម៌ ការរក្សាអត្តសញ្ញាណជាតិ ស្ត្រីតែងចេះប្រកបការងារសិប្បកម្ម ការងារសិល្បៈ ស្ត្រីមានចរិយាមារយាទ សម្តីសំដៅ ការស្លៀកពាក់បែបជាតិជាដើម។ ដោយចាស់បុរាណកំណត់ថា ក្រឹត្យនៅនឹងស្រី វិន័យនៅនឹងសង្ឃ។ តាមប្រវត្តិសាស្ត្រ តាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ននេះ ខ្មែរមានស្ត្រីឆ្នើមជាច្រើនរូបដែលបានធ្វើពលីកម្មធំធេង ដើម្បីជាតិមាតុភូមិប្រកបដោយមោទនភាពដូចជា ព្រះនាងសោមា (លីវ យី) ព្រះនាងឥន្ទ្រទេវីជាដើម។ ក្នុងពិធីអាពាហ៍ពិពាហ៍មង្គលខ្មែរតែងរៀបចំពិធីនៅផ្ទះខាងស្រី ដោយឱ្យស្ត្រីនៅទីខ្ពង់ជាងខាងប្រុស។ ខ្មែរតែងនិយមហៅអ្នកដើមពិធីខាងស្រីថា ខាងលើអ្នកដើមពិធីខាងប្រុសថាខាងក្រោម។ ការប្រើពាក្យប្រចាំថ្ងៃ អ្វីដែលធំខ្ពង់ខ្ពស់ ចម្បង ខ្មែរតែងហៅថាមេដូចជា មេទ័ព មេចោរ មេទ្វារ មេដំបូង ជាដើម។ ក្នុងរឿងព្រេងខ្មែរក៏បានលើកតម្លៃស្ត្រីដូចជា រឿងគង់ហ៊ាន រឿងមាយើង រឿងភ្នំប្រុសភ្នំស្រីជាដើម សុទ្ធតែបានលើកយកតម្លៃតួនាទីស្ត្រីជាធំ។ លំអាននៃការលើកតម្កើងស្ត្រីទាំងនេះក៏កើតមានក្នុងផ្នត់គំនិតខ្មែរតាំងពីយូរមកហើយ ដែលផ្នត់គំនិតនេះក៏បានកើតមានក្នុងស្មារតីដឹកនាំស្ថាប័នតូច ធំជាប្រចាំ។ ប្រពៃណីលើកតម្កើង និងផ្តល់តម្លៃនារីត្រូវបានថ្នាក់ដឹកនាំវិទ្យាស្ថានភាសាជាតិជាបន្តបន្ទាប់ តាំងពីក្រោមការដឹកនាំរបស់អតីតប្រធានវិទ្យាស្ថាន ឯកឧត្តមបណ្ឌិតសភាចារ្យ ឡុង សៀម ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ីវ ច័ន្ទ រហូតមកដល់ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត ជួរ គារី នាពេលបច្ចុប្បន្ន ក៏បានបន្តការប្រារព្ធ អបរសាទរ ដើម្បីបង្ហាញពីសាមគ្គីភាព សមភាព និងផ្តល់ការគោរពដល់នារីជារៀងរាល់ឆ្នាំ។ ស្មារតីទិវានារីអន្តរជាតិ៨ មីនា ក៏ដូចជាការលើកតម្កើងនារីតាមរយៈផ្នត់គំនិតខ្មែរ ជាការរួមចំណែកក្នុងការគោរព ផ្តល់តម្លៃដល់នារី ការផ្តល់ផលប្រយោជន៍ ក្នុងទទួលការងារ ដោយ

លក្ខណៈសមភាពរវាងបុរស និងស្ត្រីជាមូលដ្ឋាន។ ហើយសូមឱ្យស្មារតីទិវានារីស្ថិតនៅអមតៈក្នុងស្ថាប័ន ក្នុងសង្គមកើតមានជានិច្ចនិរន្តរ៍ និងកុំឱ្យមានស្មារតីចាត់ទុកនារីជាកម្លាំងទន់ខ្សោយតទៅទៀត។

ហេតុនេះ ការលើកស្ទួយសិទ្ធិស្ត្រីក្នុងសង្គមខ្មែរអាស្រ័យទៅលើភាពបត់បែននៃផ្នត់គំនិតសង្គមទៅលើស្ត្រីនេះឯង។ ក្នុងន័យនេះ ការលើកស្ទួយតម្លៃស្ត្រីខ្មែរត្រូវចាប់ផ្តើមជាបឋមពីគ្រួសារនីមួយៗពោលគឺស្វាមី និងបងប្រុសទាំងឡាយត្រូវកាត់បន្ថយឥទ្ធិពលរបស់ខ្លួនទៅលើស្ត្រី ហើយផ្តល់តម្លៃនិងសិទ្ធិសេរីភាពដល់ភរិយា និងប្អូនស្ត្រីរបស់ខ្លួនឲ្យស្មើភាពជាមួយខ្លួន។ ចំណែករដ្ឋាភិបាលវិញក៏មានកាតព្វកិច្ចដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីឲ្យបានរួសរាន់ដើម្បីបង្កលក្ខណៈឱ្យស្ត្រីខ្មែររំដោះខ្លួនឲ្យបានឆាប់ចេញពីស្ថានភាព «**បង្វិលចង្ក្រានមិនជុំ**»។[៣]

### ១.២.២. ការផ្លាស់ប្តូរតួនាទីស្ត្រីនាពេលបច្ចុប្បន្ន

នៅក្នុងគ្រួសារមួយកាលពី១០មុន ស្ត្រីមានតួនាទីទុកដាក់លុយមើលថែកូនៗ ទុកដាក់ចង្ក្រាន មើលថែសុខទុក្ខស្វាមី និងមាតាបិតារបស់គាត់។ គាត់មានការទទួលខុសត្រូវ និងទំនួលខុសត្រូវធំ។ លើសពីនេះទៅទៀត កាលពី១០ឆ្នាំមុន ស្ត្រីមិនមានឱកាសក្នុងការចូលរៀនបានខ្ពង់ខ្ពស់នោះទេ។ នេះមានន័យថា ក្នុងគ្រួសារមួយប្រសិនបើមានកូនប្រុស និងកូនស្រី ឪពុកម្តាយតែងតែឱ្យកូនស្រីនៅផ្ទះ កូនប្រុសទៅរៀន។ កាលណាដែលមិនបានទៅរៀនសូត្រខ្ពង់ខ្ពស់នេះហើយទើបធ្វើឱ្យគាត់អត់មានឱកាស និងសមត្ថភាពនៅក្នុងការកាន់តួនាទីធំៗក្នុងស្ថាប័ននានា ឬក៏យើងអាចនិយាយបានថា គាត់មិនអាចចូលក្នុងសង្គមបានទេ ដោយសារតែពួកគាត់អត់មានចំណេះដឹង ហើយអ្នកខ្លះទៀតគឺអត់ចេះអក្សរតែម្តងដែលយើងហៅថា **អក្ខរកម្ម**។

ក្នុងប្រទេសកម្ពុជា ក្នុងចំណោមពលរដ្ឋសរុបទាំងអស់ជាង ១៧លាននាក់ គឺមានអត្រាស្ត្រីជាង ៥២% ហើយដែលស្ត្រីទាំងនោះភាគច្រើនជាមេគ្រួសារ ជាស្ត្រីមេម៉ាយដែលត្រូវរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមផ្គត់ផ្គង់ក្នុងគ្រួសារ។ ចំពោះគ្រួសារដែលមានប្តីប្រពន្ធរស់នៅជុំគ្នាវិញ គឺគេពុំដែលមានរបាយការណ៍ស្រាវជ្រាវណាមួយទាក់ទងនឹងបញ្ហាដែលកើតឡើងក្នុងគ្រួសារបណ្តាលមកពីរឿងលុយកាក់នោះទេ។ ប៉ុន្តែជាទូទៅ តាមការសាកសួរគឺថា ទម្លាប់របស់គ្រួសារខ្មែរ ប្តីដែលធ្វើការរកប្រាក់ចំណូលបានមកតែងប្រគល់ឱ្យភរិយាទុកដាក់សន្សំសំចៃ ហើយការចាយវាយផ្សេងៗគឺប្តីប្រពន្ធទាំងនោះតែងតែពិភាក្សាជាមួយគ្នាមុនសម្រេចធ្វើអ្វីមួយ ជាពិសេសគឺទាក់ទងនឹងការទិញដូរដែលត្រូវការចំណាយប្រាក់ច្រើន។ ស្ត្រីមានតួនាទីសំខាន់ណាស់ទាំងនៅក្នុងគ្រួសារ និងសង្គមជាតិ។ ពួកគាត់មានកាតព្វកិច្ចក្នុងការបំពេញភារកិច្ចរវាងគ្រួសារនិងសង្គមមិនមែនមានតែនៅក្នុងគ្រួសារទេ។ ចំពោះសង្គមជាតិវិញ ពួកគាត់មាននាទីក្នុងការចូលរួមចំណែកធ្វើឱ្យប្រទេសជាតិយើងរីកចម្រើនផ្នែកសេដ្ឋកិច្ចដូចសព្វថ្ងៃ។

[៣] គេហទំព័រ https://thmeythmey.com/?page=detail&id=៣៧២៦២, ដកស្រង់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

ប៉ុន្តែ បើសិនជាយើងមើលមកបច្ចុប្បន្នវិញ សព្វថ្ងៃនេះយើងមានសមភាពយេនឌ័របណ្តាលឱ្យផ្នត់គំនិតក្នុងគ្រួសារមានការផ្លាស់ប្តូរ។ ទោះបីមិនបាន១០០% តែបានមួយចំនួនធំ ហើយវាជំរុញឱ្យស្ត្រីមានកាតព្វកិច្ច និងទំនួលខុសត្រូវស្មើគ្នានៅក្នុងគ្រួសារមួយរវាងបុរស និងស្ត្រីដោយយើងប្តូរពីពាក្យ «**ស្ត្រី បង្វិលចង្រ្កានមិនជុំ**» ទៅជា «**ស្ត្រី ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ**»។ ឃ្លានេះធ្វើឱ្យស្ត្រីមានមុខមាត់ មានអំណាច លើកតម្កើងឱ្យក្លាយជាអ្នកដឹកនាំ។ ចំពោះការផ្សព្វផ្សាយ យើងផ្សាព្វផ្សាយទូលំទូលាយមកហើយ ប៉ុន្តែ ចំពោះឧបសគ្គវិញយើងនូវតែជួបឧបសគ្គផ្សេងទៀតដែរមិនទាក់ទង និងការផ្សព្វផ្សាយ។ ម្យ៉ាងវិញទៀត តួនាទីស្ត្រីខ្មែរនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នមានការផ្លាស់ប្តូរច្រើន មន្ត្រីអង្គការសង្គមស៊ីវិលនៅកម្ពុជា បានអះអាងថា ជាប្រពៃណី និងទំនៀមទម្លាប់ខ្មែរពីដើមមក ស្ត្រីរៀបការហើយគឺគ្រាន់តែក្លាយជាភរិយា ជាស្ត្រីមេផ្ទះ មើលថែរក្សាកូន រៀបចំទុកដាក់ផ្ទះសម្បែង ចម្អិនម្ហូបអាហារ និងចាត់ចែងសន្សំលុយកាក់ដែលប្តីរកបាន។ សព្វថ្ងៃនេះ ស្ត្រីត្រូវធ្វើការរកប្រាក់ចំណូលសម្រាប់ក្នុងគ្រួសារបន្ថែមទៅនឹងកិច្ចការទទួលខុសត្រូវនៅក្នុងផ្ទះ ទោះបីជាតួនាទីរបស់ស្ត្រីខ្មែរបច្ចុប្បន្នមានការផ្លាស់ប្តូរក្នុងគ្រួសារ ស្ត្រីត្រូវធ្វើការរកប្រាក់ចំណូល និងបំពេញការងារនៅក្នុងផ្ទះក៏ដោយ ក៏ប៉ុន្តែដោយសារតែប្រពៃណី និងទំនៀមទម្លាប់ក្នុងសង្គមគ្រួសារកន្លងមកគេនៅតែរំពឹងចង់បានឱ្យស្ត្រីមាន ឫកពាសុភាពរាបសា មានសេចក្តីថ្លៃថ្នូរដើម្បីផ្តល់កិត្តិយសដល់ក្រុមគ្រួសារ។

ស្ទើរតែប្រជាជនកម្ពុជាយើងទាំងអស់គ្នាទៅហើយនិយាយអំពី “**សមភាពយេនឌ័រ**”។ សមភាពយេនឌ័រសំដៅទៅលើការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងការសម្រេចចិត្តក្នុងការធ្វើទំនាក់ទំនង ក្នុងការទទួលទំនួលខុសត្រូវការងារ និងក្នុងការកែប្រែទៅលើគោលការណ៍នយោបាយមួយចំនួន។ ជារួមស្ត្រីមានសំឡេង តាំងពីខាងថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ជាតិ។ ពីមុនមក យើងធ្លាប់ធ្វើគោលនយោបាយសមភាពយេនឌ័រដែរ តែមិនមានប្រសិទ្ធភាពទេ ប៉ុន្តែដល់ពេលឥឡូវនេះវិញ គឺយើងមានទាំងប្រសិទ្ធភាពនិងប្រសិទ្ធផលល្អជាងមុនដោយយើងប្តូរពាក្យពី “**ស្ត្រីបង្វិលចង្រ្កានមិនជុំ**” ទៅជា “**ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ**”។ លើសពីនេះទៅទៀត ស្ត្រីប្រមាណជាង ៦១% ជាម្ចាស់សហគ្រាសខ្នាតតូចនិងខ្នាតមធ្យម នេះជាតួលេខយោងតាមការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងឆ្នាំ២០២២ ហើយសហគ្រាសខ្នាតតូចនិងខ្នាតមធ្យមទាំងនេះហើយជាកត្តាជំរុញកំណើនសេដ្ឋកិច្ចជាតិ និងចីរភាពនៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ ដូចនេះ ស្ត្រីប្រៀបបីបានដូចជា កម្លាំងចលករស្នូលមួយក្នុងការចូលរួមសេដ្ឋកិច្ចប្រទេស។[៤]

[៤] គេហទំព័រ https://ams.com.kh/central/detail/៩៣៧៧៨៦, ដកស្រង់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤

# ជំពូកទី២
# ការចូលរួមរបស់ស្ត្រីក្នុងវិស័យ
# សំខាន់ៗ

# ជំពូកទី២
# ការចូលរួមរបស់ស្ត្រីក្នុងវិស័យសំខាន់ៗ

## ២.១. ស្ត្រីក្នុងវិស័យសំខាន់ៗ

### ២.១.១ វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច

#### ២.១.១.១. វិស័យសេដ្ឋកិច្ច

ការសម្រេចបានសមភាពយេនឌ័រ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាលដំណាក់កាលទី៣ (២០១៤-២០១៨) ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ រាជរដ្ឋាភិបាល បានផ្តោតជាសំខាន់លើការបង្កើន ការចូលរួមរបស់ស្ត្រី ដើម្បីពន្លឿនការសម្រេចគោលដៅជាតិដូចជា ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងចំណែកស្មើភាពគ្នាសម្រាប់ស្ត្រី។ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីមានគោលបំណងបង្កើតឱកាសរកប្រាក់ចំណូលសម្រាប់ស្ត្រីតាមរយៈការលើកកម្ពស់ការងារដែលមានប្រាក់កម្រៃសមរម្យ និងការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម។ ការបង្កើតឱកាសសេដ្ឋកិច្ចប្រកបដោយនិរន្តភាពរួមទាំងកំណើនប្រាក់ចំណូល និងកម្មសិទ្ធលើទ្រព្យសម្បត្តិត្រូវបានរំពឹងទុកថានឹងកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ស្ត្រីដូចជា ការជួញដូរមនុស្ស ការធ្វើទេសន្តប្រវេសន៍មិនស្របច្បាប់ និងអំពើហិង្សាក្នុងគ្រួសារផងដែរ។ នៅពេលប្រាក់ចំណូលមានការកើនឡើងស្ត្រីអាចវិនិយោគទៅលើការអភិវឌ្ឍន៍ជីវភាពរស់នៅ និងចូលរួមលើការអភិវឌ្ឍភូមិឃុំប្រកបដោយនិរន្តភាព។

ដូចនេះ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតម្រូវឱ្យមានក្របខ័ណ្ឌគោលនយោបាយចំនួនបួនដែលទាក់ទងនឹងការងារមានប្រាក់កម្រៃ ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ការធ្វើទេសន្តប្រវេសន៍ និងការអភិវឌ្ឍជីវភាពរស់នៅទីជនបទ៖

- នៅប្រទេសកម្ពុជា ការអភិវឌ្ឍទីផ្សារពលកម្មគឺជាផ្នែកមួយនៃ យុទ្ធសាស្ត្រចតុកោណ ដែលចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ការងារមានប្រាក់កម្រៃ និងកិច្ចគាំពារសង្គមសម្រាប់កម្មករ កម្មការិនីត្រូវបានអនុវត្តយោងទៅតាមច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានា។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានតួនាទីក្នុងការអនុវត្តន៍ច្បាប់ការងារនេះ។
- ការលើកកំពស់ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម គឺជាភារកិច្ចរបស់ក្រសួងពាក់ព័ន្ធ។ កិច្ចសន្ទនារវាងវិស័យសាធារណៈ និងឯកជនគឺជាយុទ្ធសាស្ត្រមួយ ដើម្បីបង្កើតឱ្យមានបរិយាកាសសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ការងារមានប្រាក់កម្រៃ និងកិច្ចគាំពារសង្គមសម្រាប់កម្មករ

កម្មករិនី ត្រូវបានអនុវត្តយោងទៅតាមច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានា។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានតួនាទីក្នុងការអនុវត្តន៍ច្បាប់ការងារនេះ។

➢ ការលើកកម្ពស់ការអភិវឌ្ឍសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម គឺជាភារកិច្ចរបស់ក្រសួងពាក់ព័ន្ធ។ កិច្ចសន្ទនារវាងវិស័យសាធារណៈ និងឯកជនគឺជាយុទ្ធសាស្ត្រមួយដើម្បីបង្កើតឱ្យមានបរិយាកាសអាជីវកម្មដ៏មានលក្ខណៈអំណោយផលសម្រាប់សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងការផ្តល់សេវាហិរញ្ញវត្ថុ។

➢ មានច្បាប់ជាតិមួយចំនួនពាក់ព័ន្ធនឹងការធ្វើទេសន្តប្រវេសន៍ ដើម្បីស្វែងរកការងារ ហើយច្បាប់ទាំងនោះត្រូវបានកែសម្រួល និងផ្តល់ជាគោលការណ៍សម្រាប់ក្រុមហ៊ុន ជ្រើសរើសពលករ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងនីតិវិធីបណ្តឹង។ ការអភិវឌ្ឍជីវភាពរស់នៅពាក់ព័ន្ធភាគច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធនៅតាម មូលដ្ឋាន អាហារូបត្ថម្ភ អនាម័យ និងសកម្មភាពសេដ្ឋកិច្ចតូចៗ។ ការងារទាំងអស់នេះភាគច្រើនជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ។ គោលនយោបាយសម្រាប់ “ **កែលម្អជីវភាពរស់នៅតាម សហគមន៍ជនបទ ជាពិសេសសម្រាប់ស្ត្រីក្រីក្រ** “ ត្រូវបានបញ្ជាក់នៅក្នុងក្របខណ្ឌអាទិភាពជាតិរយៈពេលមធ្យមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យុទ្ធសាស្ត្រផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៃក្រសួងកិច្ចការនារីនឹងគាំទ្រ និងចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយខាងលើ ដោយផ្តោតការយកចិត្តទុកដាក់នានាពិសេសលើស្ត្រី។ ផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សំដៅលើ៖

- ការផ្តល់ឱកាសឱ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពកសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ ជីវភាពរស់នៅទីជនបទ ការអភិវឌ្ឍអាជីវកម្ម និងការងារមានប្រាក់កម្រៃ
- ស្ត្រីទទួលបានអត្ថប្រយោជន៍ពីឱកាសទាំងនេះតាមរយៈការផលិតប្រាក់ចំណូល និងបៀវត្សរ៍ពលកម្ម
- ការផ្តល់ឱកាសឱ្យស្ត្រីមានតួនាទីក្នុងការធ្វើសេចក្តីសម្រេច។ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចពុំទាន់អាចធានាឱ្យមានសមភាពយេនឌ័រឡើយ ប៉ុន្តែបានផ្តល់នូវយន្តការមួយដ៏សំខាន់សម្រាប់ស្ត្រីក្នុងការចរចាដើម្បីធ្វើឱ្យសុខុមាលភាពស្ត្រីមានភាពប្រសើរឡើង។ ការបន្តផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងកម្រិតទាបអាចបណ្តាលឱ្យសក្តានុពលកំណើនសេដ្ឋកិច្ចកម្ពុជាមានការធ្លាក់ចុះ។ ផ្ទុយទៅវិញ ការកើនឡើងនៃការចូលរួមការទទួលបានអត្ថប្រយោជន៍ និងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចនឹងកាត់បន្ថយវិសមភាពនិងជំរុញកំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា។

និន្នាការសំខាន់ៗនៅក្នុងការអភិវឌ្ឍវិស័យសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម និងកម្លាំងពលករ ទោះបីជាអត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រី ដែលមានអាយុពី១៥ ទៅ ៦៤ឆ្នាំ មានការកើនឡើងពី៧៦ ទៅ ៨០% នៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១២ក៏ដោយ ក៏វិសមភាពយេនឌ័រនៅក្នុងការងារមានប្រាក់កម្រៃនៅតែមានគម្លាត។ គម្លាតយេនឌ័រមាន ការកើនឡើងក្នុងការងារដែលងាយរងគ្រោះ និងការងារក្នុងវិស័យកសិកម្មនេះ បង្ហាញឱ្យឃើញថា ស្ត្រីមានឱកាសតិចតួចនៅក្នុងការងារដែលមានផលិតភាពខ្ពស់ និងការងារសមរម្យ។[៥]

### ២.១.១.២. វិស័យសង្គមកិច្ច

### ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្ដូរឥរិយាបថនៅក្នុងសង្គម

យុទ្ធសាស្ត្រស្តីពីការអប់រំស្ត្រី និងក្មេងស្រីនឹងជួយបំពេញ និងជាបុរេលក្ខខណ្ឌចាំបាច់ ដើម្បីធានាឱ្យមានភាពជោគជ័យសម្រាប់ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ខណៈដែលកម្ពុជាកំពុងបោះជំហានទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យម និងឆ្ពោះទៅរកការធ្វើសមាហរណកម្មក្នុងតំបន់ កត្តានេះតម្រូវឱ្យមានការបង្កើន លទ្ធភាពក្នុងការទទួលបានការអប់រំដោយស្មើភាព ដែលមានគុណភាពខ្ពស់ និងស្របតាមតម្រូវការទីផ្សារការងារ។ គម្លាតយេនឌ័រ ជាពិសេសក្នុងកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា ដែលបណ្ដាលមកពីកង្វះសម្ភារៈរូបវ័ន្ត ក៏ដូចជាផ្នត់គំនិតដែលមិនទាន់ផ្ដល់តម្លៃពេញលេញដល់ក្មេងស្រី និងស្ត្រីតម្រូវឱ្យមានការឆ្លើយតបឱ្យបានកាន់តែប្រសើរឡើង។

ក្នុងនីតិកាលទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តជំរុញការអនុវត្ត គោលការណ៍ការអប់រំសម្រាប់ទាំងអស់គ្នា សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ បន្តលើកកម្ពស់ គុណភាព និងប្រសិទ្ធភាពសេវាអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ។ ក្រសួងកិច្ចការនារី នឹងបន្តសហការ និងផ្ដល់ជំនួយបច្ចេកទេសដល់ក្រុមការងារយេនឌ័រនៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីវិភាគគម្លាតយេនឌ័រ គាំទ្រ និងជំរុញឱ្យមានការកែលំអ និងត្រួតពិនិត្យដំណើរការទាំងនេះ។ ក្រសួងកិច្ចការនារី ក៏ដើរតួទៅជាអ្នកបង្កើនគណនេយ្យភាពសង្គម និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានសេវា និងកិច្ចគាំពារសង្គមដល់ស្ត្រី និងក្មេងស្រី ព្រមទាំងពិនិត្យមើលលទ្ធភាពរបស់ពួកគេលើការទទួលបានសេវាទាំងនេះផងដែរ។ តាមរយៈកម្មវិធីលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្រសួងកិច្ចការនារី នឹងបន្តសម្របសម្រួលជាមួយនឹងដៃគូពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិលើកកម្ពស់សីល

---

[៥] គេហទំព័រ https://www.undp.org/sites/g/files/zskgke៣២៦/files/migration/kh/b៣១d៣c១៨២៧៥២d៩៦១៥៨៦០០ebbb៩a៦e២០a១៥៦d៤៨៥cc២៤f២៨cd៨fa២f៦៨៩fb២៥៩៣៣e.pdf, ដកស្រង់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤

ធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរក្នុងការអនុវត្តការងារតាមយុទ្ធសាស្ត្រពហុវិស័យក្នុងគោលបំណងអភិរក្ស និង អភិវឌ្ឍនូវវប្បធម៌ អហិង្សា ផ្ដល់តម្លៃដល់ស្ត្រី បណ្ដុះនូវឥរិយាបថ និងអាកប្បកិរិយាវិជ្ជមានក្នុងការលើកកម្ពស់ សមភាពយេនឌ័រ ដើម្បីធានាដល់ការគោរពសីលធម៌សង្គម និងសុភមង្គលនៅក្នុងគ្រួសារ និងសង្គមជាតិ។ ដូច្នេះការលើកកម្ពស់សម្រេចបាននូវសមភាពយេនឌ័រក្នុងវិស័យអប់រំ ជាពិសេសការបង្កើនការទទួលបាននូវ សេវាអប់រំដល់ស្ត្រី និងកុមារីក្នុងក្រុមដែលងាយរងគ្រោះតាមរយៈវិធានការបង្កើនការយល់ដឹងគណនេយ្យភាព សង្គម អាហារូបករណ៍ ជំនួយហិរញ្ញវត្ថុផ្សេងទៀត និងបង្កើនការចូលរួមរបស់ស្ត្រីដែលជាអ្នកផ្ដល់ និងគ្រប់គ្រង សេវាអប់រំនៅគ្រប់ផ្នែកព្រមទាំងលើកកម្ពស់សីលធម៌សុខមាលភាពសង្គមអាកប្បកិរិយា និងឥរិយាបថសង្គមដែលឆ្លើយតបនិងយេនឌ័រ។[៦]

## ២.១.២. វិស័យនយោបាយ

រដ្ឋាភិបាលដែលប្រកបដោយប្រជាធិបតេយ្យ និងមានលក្ខណៈជាតំណាងពិតប្រាកដមិនអាចបង្កើតឡើងដោយគ្មានការចូលរួមពីស្ត្រីនៅក្នុងដំណើរការនយោបាយបានឡើយ។ ស្ត្រីត្រូវបានមើលឃើញថាមានតួនាទីពិសេស និងសំខាន់នៅក្នុងនយោបាយតាមរយៈការបញ្ចេញមតិយោបល់ និងគំនិតដោះស្រាយបញ្ហាដែលកើត មានឡើង។ នៅប៉ុន្មានទសវត្សចុងក្រោយនេះ មានការកើនឡើងនូវការទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងគ្រប់វិស័យនៅក្នុងសង្គមដែលមានជម្លោះ និងក្រោយជម្លោះរួមទាំងការចរចាររកសន្តិភាពកសាងឡើងវិញនូវសង្គមដែលបំផ្លាញដោយសង្គ្រាមជាតំណាងនៅក្នុងសភា និងដោះស្រាយតម្រូវការផ្នែកសន្តិសុខដែលទាក់ទងជាក់លាក់នឹងយេនឌ័រ។ ប្រទេសកម្ពុជាយល់ឃើញថា បទពិសោធន៍របស់ស្ត្រីមានភាពខុសគ្នាពីបទពិសោធន៍របស់បុរស ទាំងនោះគួរតែត្រូវបានប្រើប្រាស់នៅក្នុងវិស័យនយោបាយ។ របាយការណ៍ប្រៀបធៀបមួយរបស់អង្គការសហប្រជាជាតិស្ដីពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិច (UNESCAP) បានបង្ហាញថាស្ត្រី៖

- មានសមត្ថភាពដោះស្រាយបញ្ហាសង្គម សុខុមាលភាពរបស់សហគមន៍ និងបញ្ចូលចំណុចទាំងនោះទៅក្នុងការសម្រេចចិត្ត
- លើកកម្ពស់គោលនយោបាយ និងសកម្មភាពដែលជួយដល់សហគមន៍
- ជួយអោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធកាន់តែច្រើន
- លើកឡើងពីសារៈសំខាន់ និងការអនុវត្តការប្រាស្រ័យទាក់ទងល្អជាមួយសហគមន៍
- មានវិធីសាស្ត្រផ្សេងៗចូលរួមជាមួយការងាររបស់អជ្ញាធរមូលដ្ឋាន

[៦] សៀនភៅ នារីរតនៈទី៤, ឆ្នាំ២០១៤-២០១៨, ទំព័រទី១៧

- បង្កើតវិធីសាស្ត្រធ្វើការងារជាមួយក្រុមការងារ
- កំណត់អាទិភាពផ្សេងៗគ្នា
- មានជំនាញសម្របសម្រួល កំណត់គោលដៅច្បាស់លាស់ ធ្វើការងារបានច្រើនប្រភេទ និងចេញលទ្ធផលជាក់ស្តែង
- មានការលះបង់ ទទួលខុសត្រូវ និងអនុវត្តន៍បាននូវអ្វីដែលបានផ្សព្វផ្សាយ និងមានស្មារតីល្អក្នុងការងារ
- ជម្រុញ និងលើកកម្ពស់ស្ត្រីផ្សេងៗទៀតអោយចូលរួមនៅក្នុងការអភិវឌ្ឍ។[៧]

### ២.១.៣. វិស័យសុខាភិបាល

លោកសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានថ្លែងថា មកទល់នឹងបច្ចុប្បន្ននេះ ស្ត្រីជាង៥២% ដែលបានបំពេញការងារក្នុងវិស័យសុខាភិបាល ដែលបង្ហាញឱ្យឃើញពីសមត្ថភាពក្នុងការចូលរួមចំណែកលើកកម្ពស់វិស័យសុខាភិបាល ពិសេសលើការងារសុខភាពមាតា ទារក និងកុមារ។ ការថ្លែងបែបនេះរបស់លោក រដ្ឋមន្ត្រីក្រសួងសុខាភិបាល ថ្លែងក្នុងពិធីអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ «**ស្ត្រីរួមគ្នា រក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍ ក្នុងយុគសម័យឌីជីថល**» នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣នេះ។

លោកសាស្ត្រាចារ្យ ម៉ម ប៊ុនហេង បានថ្លែងថា ការប្រារព្ធអបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា នៅថ្ងៃនេះ គឺជាការលើកទឹកដល់នារីក្នុងអង្គភាពផង និងនារីក្នុងវិស័យសុខាភិបាលផង។ យើងសង្កេតឃើញថា ស្ត្រីគឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ។ បើយើងគិតតែមួយផ្នែកលើវិស័យសុខាភិបាល គឺស្ត្រីបានចូលរួមជាច្រើន ដើម្បីលើកកម្ពស់សុខាភិបាល រួមទាំងការមើលថែសុខភាពអ្នកជំងឺ ពិសេសការផ្តល់ប្រឹក្សា ព្យាបាលដល់ស្ត្រីមុនពេលមានស្ត្រីផ្ទៃពោះកំពុងពរពោះ និងក្រោយសម្រាលកូន ដោយការពិនិត្យផ្ទៃពោះផង និងពេលសម្រាលកូនផង។ ដូចនេះខ្ញុំមានមោទនភាពណាស់ ដែលមានស្ត្រីដ៏រឹងមាំមានសមត្ថភាពសម្រាប់វិស័យសុខាភិបាល។ លើសពីនោះ សុខភាពរបស់ស្ត្រី គឺជាការងាររបស់គ្រួសារ ដែលទាមទារត្រូវមានការយកចិត្តទុកដាក់ពីគ្រួសារ ព្រោះបើស្ត្រីមានសុខភាពល្អ សុខភាពបន្តពូជល្អ ខណៈដែលប្តីមានសុខភាពផងដែរនោះ គឺបុត្រធីតានឹងមានសុខភាពល្អ ដែលជាទំពាំងស្នងឬស្សីដ៏រឹងមាំសម្រាប់ប្រទេសជាតិ។ ម្យ៉ាងវិញទៀតក្នុងការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ក្រសួងសុខាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការងាររបស់ស្ត្រី ដោយបានផ្តល់អាទិភាពដល់ស្ត្រី ដែលមានសមត្ថភាពឱ្យទទួលបាននូវមុខ

[៧] សៀវភៅ វឌ្ឍភាពស្ត្រីក្នុងវិស័យនយោបាយ, លោកស្រី គឹម កែវធីតា និងលោកស្រី ជា ម៉ាលីកា, ខែកញ្ញា ឆ្នា២០១៦,ទំព័រ២-៥

តំណែងសមស្របមួយក្នុងការងាររបស់ខ្លួន និងបានផ្តល់ឱកាសឱ្យទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលបន្ត ជំនាញផ្សេងៗក្នុង និងក្រៅប្រទេសទៀតផង។ ចំពោះការផ្តល់សេវាសុខភាព ក្រសួងបានផ្តោតការយកចិត្ត ទុកដាក់ខ្ពស់បំផុត ក្នុងការថែរក្សាសុខភាពដល់ស្ត្រីក្នុងវ័យបន្តពូជ និងជាពិសេសស្ត្រីជាមាតា ដើម្បីឈានទៅ កាត់បន្ថយអត្រាមរណភាពមាតា និងទារក។ ជាក់ស្តែងតាមរយៈតួលេខដែលបានមកពីការអង្កេតសុខភាព និង ប្រជាសាស្ត្រឃើញមនៅកម្ពុជាអត្រាពិនិត្យ និងថែទាំស្ត្រីនៅពេលមានគភ៌ និងពេលសម្រាលមានចំនួនកើនឡើង រីឯ អត្រាមរណភាពមាតា ទារក និងកុមារមានការថយចុះគួរឱ្យកត់សម្គាល់។

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលផងនោះ បាននឹង កំពុងផ្សព្វផ្សាយពីការងារ យេនឌ័រយ៉ាងទូលំទូលាយលើគ្រប់វិស័យនៅទូទាំងប្រទេស ដើម្បីឱ្យប្រជាពលរដ្ឋទាំង អស់ ជាពិសេសគឺស្ត្រីខ្លួនឯងយល់ពីតួនាទី និងសិទ្ធិរបស់ខ្លួន និងរួមគ្នារក្សាសន្តិភាពដើម្បីអភិវឌ្ឍជាតិ ព្រមទាំង ការប្រើប្រាស់សិទ្ធិនេះឱ្យបានសមស្របផងដែរ។ ដូច្នេះប្រធានបទឆ្នាំនេះ គឺចង់បង្ហាញឱ្យយើងទាំងអស់គ្នាបាន ដឹងពីសមត្ថភាពពិតប្រាកដរបស់ស្ត្រី និងទទួលស្គាល់ថា ស្ត្រីជាភ្នាក់ងារដ៏សំខាន់ ដែលមានតួនាទីចម្បងចូល រួមធ្វើឱ្យសង្គមមានស្ថេរភាព និងការអភិវឌ្ឍក្នុងយុគសម័យឌីជីថលនេះ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំ ដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** កម្ពុជាបានផ្តោតការយក ចិត្តទុកដាក់ ជាពិសេសទៅលើសុខភាពរបស់មាតា ទារក និងកុមារដោយបានចេញអនុក្រឹត្យកំណត់យកថ្ងៃទី២១ ខែកុម្ភៈ ជាទិវាជាតិសុខភាពមាតា ទារក និងកុមារផងដែរ។ លើការងាររបស់ស្ត្រី ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គមជាតិនោះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឱកាស និងលើកទឹកចិត្តឱ្យស្ត្រីមានតួនាទី និងមុខ តំណែងជាអ្នកគ្រប់គ្រង និងដឹកនាំចាប់តាំងពីថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ដឹកនាំកំពូល ជាក់ស្តែងសមាស ភាពជានារីនៅក្នុងជួរថ្នាក់ដឹកនាំឃុំ-សង្កាត់ ស្រុក-ខណ្ឌ រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន ជាងនេះទៅទៀតក្នុងជួរ រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា។ ប្រសិនបើស្ត្រីជាមាតាមានសុខភាពល្អ កូន ប្តី និងគ្រួសារទាំងមូល ក៏ មានសុខភាពល្អ មានសុភមង្គល និងមានឱកាសចូលរួមសង្គមយ៉ាងពេញលេញក្នុងកិច្ចអភិវឌ្ឍសង្គមជាតិដែរ។[៨]

### ២.១.៤. វិស័យបច្ចេកវិទ្យា និងឌីជីថល

សព្វថ្ងៃនេះ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យបច្ចេកវិទ្យានៅមានកម្រិត នៅឡើយ បើធៀបជាមួយ បុរសខណៈដែលស្ត្រីក៏មានទេពកោសល្យ និង សក្តានុពលសំខាន់ក្នុងការចូលរួមដល់ការអភិវឌ្ឍលើផ្នែក

[៨] គេហទំព័រ https://freshnewsasia.com/index.php/en/, ដកស្រង់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

បច្ចេកវិទ្យា នៅក្នុង សកម្មភាពសេដ្ឋកិច្ច សង្គម។ ក្នុងន័យនេះ យើងគួរពិនិត្យមើលលើទិដ្ឋភាព មួយចំនួន ដែលឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុង វិស័យបច្ចេកវិទ្យាដូចខាងក្រោម៖

- បង្កើនធនធានមនុស្ស៖ វិស័យបច្ចេកវិទ្យាបានរីកចម្រើនជាលំដាប់ ដែល ធ្វើឱ្យមានកំណើនតម្រូវការអ្នកជំនាញក្នុងវិស័យនេះកាន់តែខ្លាំងឡើង។ ជាក់ស្តែង យោងតាមគេហទំព័រ DAXX នៅឆ្នាំ ២០២១ ៦៩% នៃនិយោជក នៅសហរដ្ឋអាមេរិកបានជួបប្រទះកង្វះនិយោជិត ពិសេសអ្នកជំនាញផ្នែក បច្ចេកវិទ្យា។ លើសពីនេះទៀត យោងតាមគេហទំព័រ IMF គិតត្រឹមឆ្នាំ ២០៣០ ពិភពលោកនឹងជួបប្រទះនូវកង្វះអ្នកជំនាញក្នុងវិស័យបច្ចេកវិទ្យាប្រមាណ ៨៥លាននាក់ ដែលអាចធ្វើឱ្យបាត់បង់ចំណូលប្រមាណ ៨,៥ពាន់លានដុល្លារ។ ដូច្នេះការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យាពិតជាមានសារៈ សំខាន់ណាស់ក្នុងការជួយកាត់បន្ថយកង្វះអ្នកជំនាញក្នុងវិស័យដ៏សំខាន់នេះ។
- បង្កើនប្រាក់ចំណូល៖ ការចូលរួមរបស់ស្ត្រីក្នុងក្រុមហ៊ុនបច្ចេកវិទ្យាក៏អាច ជួយបង្កើនផលិតភាពការងារព្រមទាំងគំនិតនវានុវត្តន៍ និងភាពច្នៃប្រឌិត ដែលអាចជួយឱ្យផលិតផល ឬសេវាកម្មបច្ចេកវិទ្យារបស់ក្រុមហ៊ុនកាន់តែ មានភាពទាក់ទាញ។ ការណ៍នេះ អាចជួយបង្កើនប្រាក់ចំណូលរបស់ក្រុមហ៊ុនបាន។ ជាក់ស្តែង យោងតាមគេហទំព័រ WomenTech នៅឆ្នាំ២០២០ ក្រុមហ៊ុនបច្ចេកវិទ្យាដែលមានអ្នកដឹកនាំ ៣០% ជាស្ត្រី អាចបង្កើនប្រាក់ ចំណូលបន្ថែមប្រមាណ ១៥%។
- ជួយដល់ការអភិវឌ្ឍបច្ចេកវិទ្យា៖ ការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យា ពិតជាមានសារៈសំខាន់ណាស់ ព្រោះពួកគេអាចចូលរួមផ្តល់ជាគំនិត និង ដំណោះស្រាយថ្មីៗ ដែលធ្វើឱ្យការអភិវឌ្ឍបច្ចេកវិទ្យាកាន់តែប្រសើរ។ បើសិន ជាមិនមានវត្តមានស្ត្រីក្នុងវិស័យបច្ចេកវិទ្យា យើងក៏មិនអាចឃើញពីវត្តមាន បច្ចេកវិទ្យាមួយចំនួនដែរ។ ជាឧទាហរណ៍ ភាសាសរសេរកម្មវិធីកុំព្យូទ័រ ដំបូងគេបង្អស់នៅលើពិភពលោកត្រូវបានបង្កើតឡើងដោយលោកស្រី Ada Lovelace ដែលជាគណិតវិទូនៅអំឡុងឆ្នាំ១៨៤០។ ភាសានេះត្រូវបានគេស្គាល់ថាជា Ada Programming Language។
- អភិវឌ្ឍន៍បច្ចេកវិទ្យាឆ្លើយតបទៅនឹងតម្រូវការមនុស្សគ្រប់គ្នា៖ បច្ចេកវិទ្យា ត្រូវបានបង្កើតឡើងសម្រាប់បំពេញតម្រូវការ និងដោះស្រាយនូវបញ្ហានានា របស់មនុស្ស ដែលធ្វើឱ្យការរស់នៅកាន់តែប្រសើរ។ ស្ត្រីជាអ្នកយល់ច្បាស់ នូវអ្វីដែលពួកគេត្រូវការ ដូច្នេះស្ត្រីគួរចូលរួមនៅក្នុងការរចនា និងអភិវឌ្ឍន៍ បច្ចេកវិទ្យាដូចបុរសដែរ។ វត្តមានទាំងស្ត្រី និងបុរសក្នុងវិស័យបច្ចេកវិទ្យា មានសារៈសំខាន់ដូចគ្នាក្នុងការអភិវឌ្ឍផលិតផល ឬសេវាកម្មបច្ចេកវិទ្យា នានាឱ្យស្របតាមតម្រូវការមនុស្សគ្រប់គ្នា។
- ជួយដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍៖ ស្ត្រី និងបុរសមានគំនិតខុសគ្នាច្រើន ដូច្នេះការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យាអាចជួយបំពេញបន្ថែមនូវ គំនិត និងទស្សនៈថ្មីៗក្នុងការស្រាវជ្រាវ ដែលអាចជួយ

ដល់ការអភិវឌ្ឍ ចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ។ ចំណេះដឹង និងបច្ចេកវិទ្យាទាំងនេះអាចជួយបង្កើន ស័ក្តិសិទ្ធិភាព និងផលិតភាពការងារក្នុងគ្រប់វិស័យ ដែលអាចជួយឱ្យសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើន។ ជាក់ស្តែង យោងតាមគេហទំព័រ R&D World គិតត្រឹម ២០១៩ ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុង វិស័យវិទ្យាសាស្ត្រ, បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា (STEM) បានជួយ ឱ្យមានការកើនឡើងនៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GDP per capita) ក្នុងចន្លោះប្រមាណពី ២,២% ទៅ ៣% នៅសហភាពអឺរ៉ុប។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ចំនួនសិស្សស្រីដែលជ្រើសរើសសិក្សាមុខជំនាញទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មានចំនួនតិចបើធៀបនឹងសិស្សប្រុស ដែលបណ្តាលឱ្យការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យានៅជុំវិញពិភពលោកមិនថានៅក្នុងប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍មានចំនួនតិចនៅឡើយ។ ជាក់ស្តែង យោងតាម គេហទំព័រ Statista នៅឆ្នាំ២០២១ ចំនួនស្ត្រីដែលបម្រើការងារក្នុងផ្នែកបច្ចេកវិទ្យានៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យាធំៗដូចជា **Facebook Apple Google** និង **Microsoft** ស្ថិតក្នុងរង្វង់ប្រមាណ២០% ប៉ុណ្ណោះ។ ការណ៍នេះបានបង្កជាបញ្ហាកង្វះធនធានមនុស្សផ្នែកបច្ចេកវិទ្យា ហើយបើយោងតាម គេហទំព័រ IMF គិតត្រឹមឆ្នាំ២០៣០ ពិភពលោកនឹងជួបប្រទះនូវកង្វះអ្នកជំនាញក្នុងវិស័យបច្ចេកវិទ្យាប្រមាណ ៨៥លាននាក់។ ដូច្នេះ ការចូលរួមរបស់ស្ត្រីក្នុងវិស័យដ៏សំខាន់នេះ អាចជួយបង្កើនធនធានមនុស្ស ព្រមទាំងបង្កើនប្រសិទ្ធភាព និងផលិតភាពការងារ ដែលជួយដល់កំណើនសេដ្ឋកិច្ចជាតិទាំងមូល។

ដូចគ្នានេះដែរ នៅប្រទេសកម្ពុជា ក្មេងស្រីដែលចាប់អារម្មណ៍នឹងមុខវិជ្ជា STEM មានចំនួនតិចនៅឡើយ។ ជាក់ស្តែង យោងតាមរបាយការណ៍របស់ CDRI នៅឆ្នាំ២០២១ ក្មេងស្រីដែលជ្រើសយកជំនាញព័ត៌មានវិទ្យា និងជំនាញទាក់ទងនឹងមុខវិជ្ជា STEM ផ្សេងទៀតនៅកម្រិតឧត្តមសិក្សាមានចំនួនប្រមាណ ១៦% នៃការចុះឈ្មោះចូលរៀនសរុបប៉ុណ្ណោះ។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ នៅឆ្នាំ២០១៩ ស្ត្រីមានចំនួនប្រមាណ ៨លាននាក់ ស្មើនឹងប្រមាណ ៥១,៣% នៃប្រជាជនសរុបនៅកម្ពុជា។ នៅក្នុងបរិបទនៃបដិវត្តឧស្សាហកម្ម ៤.០ នេះ ប្រទេសកម្ពុជាពិតជាមិនអាចមើលរំលងស្ត្រីបានឡើយ ព្រោះថាកង្វះការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យាបានធ្វើឱ្យបាត់បង់ធនធានមនុស្ស យ៉ាងច្រើនក្នុងវិស័យនេះ។ ហេតុនេះហើយ នៅក្នុងសម័យប្រជុំពិសេសរបស់ថ្នាក់ដឹកនាំអាស៊ាន នៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៦ **ស្តីពី ការលើកកម្ពស់តួនាទីស្ត្រីក្នុងយុគសម័យឌីជីថល** តាមរយៈប្រព័ន្ធវីដេអូ នារសៀលថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា «ការលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលត្រូវបានចាត់ទុកថាជាកាលានុវត្តភាព និងកាតាលីករថ្មីមួយសម្រាប់ពន្លឿនការសម្រេចបាន

នូវសមភាពយេនឌ័រ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយបរិយាបន្ន។ ហេតុនេះ រដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធ ជាពិសេស វិស័យឯកជនត្រូវរួមគ្នាបង្កើតបរិយាកាសមួយអំណោយផលដែលអាចឱ្យស្ត្រីមានភាពងាយស្រួលក្នុងការចាប់យកកាលានុវត្តភាព និងសក្តានុពលថ្មីទាំងនេះ»។

ស្ត្រីជាធនធានមនុស្សដ៏សំខាន់ដូចបុរសដែរ ដែលអាចជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម កម្ពុជា ប៉ុន្តែ បច្ចុប្បន្ននេះ ដោយសារឧបសគ្គមួយចំនួនបានធ្វើឱ្យក្មេងស្រីដែលចាប់អារម្មណ៍នឹងមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មានចំនួនតិចដែលធ្វើឱ្យប្រទេសខាតបង់អ្នកជំនាញផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាច្រើន។ ខាងក្រោមនេះជាសារៈសំខាន់មួយចំនួននៃ ការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យានៅកម្ពុជាដូចជា៖

- ជួយជំរុញដល់ការត្រៀមខ្លួនសម្រាប់បដិវត្តន៍ឧស្សាហកម្ម ៤.០ បច្ចេកវិទ្យាទំនើបនៃឧស្សាហកម្ម ៤.០ បានផ្លាស់ប្តូរការងារបច្ចុប្បន្ននៅក្នុងស្ទើរគ្រប់វិស័យ ហើយនឹងផ្លាស់ប្តូរ និងបង្កើតការងារថ្មីៗនៅថ្ងៃអនាគត ប៉ុន្តែវាពិបាកនឹងទស្សន៍ទាយថានៅកន្លែងណា និងមានចំនួនប៉ុន្មាន។ បដិវត្តន៍ឧស្សាហកម្ម ៤.០ មិនត្រឹមតែផ្លាស់ប្តូររចនាសម្ព័ន្ធការងារប៉ុណ្ណោះទេ តែក៏នឹងផ្លាស់ប្តូរនូវរាល់សកម្មភាពសេដ្ឋកិច្ច សង្គម។ ដើម្បីអាចឱ្យកម្ពុជាទាញយកសក្តានុពលពេញលេញពីបដិវត្តន៍ឧស្សាហកម្ម ៤.០ និងដោះស្រាយ នូវបញ្ហាប្រឈមនានាដែលកើតមានឡើងដោយសារបដិវត្តកម្មឌីជីថលនេះ កម្ពុជាពិតជាត្រូវការធនធាន មនុស្សក្នុងវិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែច្រើន។ យោងតាមគេហទំព័រ CambojaNews នៅឆ្នាំ២០១៩ ក្នុងចំណោមការចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សាមានតែ ៧% ប៉ុណ្ណោះដែលរៀនផ្នែកព័ត៌មានវិទ្យា និង២៥,៥% ដែលរៀនជំនាញទាក់ទីងនឹងមុខវិជ្ជា STEM ផ្សេងទៀត ហើយពួកគេភាគច្រើនជាសិស្សប្រុស។ ដូច្នេះ ការលើកទឹកចិត្តឱ្យក្មេងស្រីចាប់ជំនាញក្នុងផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រពិតជាមានសារៈសំខាន់ណាស់ក្នុងការបង្កើនធនធានមនុស្សក្នុងវិស័យនេះ ដើម្បីអាចឱ្យ កម្ពុជាត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងសម័យកាលបដិវត្តន៍ឧស្សាហកម្ម ៤.០ នេះ។
- ជួយដោះស្រាយបញ្ហានានានៅក្នុងសង្គម ការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យាពិតជាមានសារៈសំខាន់ណាស់ ព្រោះថាពួកគេអាចផ្តល់នូវគំនិតថ្មីៗក្នុងការដោះស្រាយបញ្ហានានានៅក្នុងសង្គម។ ជាក់ស្តែង ក្រុមកុមារីកម្ពុជាដែលជាស្ថាបនិកកម្មវិធីទូរស័ព្ទដៃ «**Cambodia Identity Product**» បាន ចូលរួមក្នុងការប្រកួត Technovation World Submit នៅទីស្នាក់ការកណ្តាលក្រុមហ៊ុន Google ដោយ បានបង្កើតជាកម្មវិធីទូរស័ព្ទ ដើម្បីជួយដល់សិប្បករកម្ពុជាឱ្យមានឱកាសលក់ផលិតផលរបស់

ពួកគេទៅកាន់ទីផ្សារអន្តរជាតិ ដែលគំនិតនេះអាចជួយពង្រីកទីផ្សារកម្ពុជា និងចូលរួមកាត់បន្ថយភាពក្រីក្រ។

➢ ជួយដល់កំណើនសេដ្ឋកិច្ច យោងតាមរបាយការណ៍ស្តីពី «**ទស្សនៈវិស័យការងារកម្ពុជា**» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត នៅឆ្នាំ២០១៨ បានបង្ហាញថាវិស័យព័ត៌មានវិទ្យាជាវិស័យមួយដែលកំពុងខ្វះខាតអ្នកជំនាញ។ កង្វះខាតអ្នកជំនាញផ្នែកបច្ចេកវិទ្យាអាចគំរាមកំហែងដល់សមត្ថភាពរបស់ប្រទេសក្នុងការកសាងសេដ្ឋកិច្ចឌីជីថល ដែលជាមាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចក្នុងសតវត្សរ៍ទី២១នេះ។ ការចូលរួមរបស់ស្ត្រី ក្នុងវិស័យបច្ចេកវិទ្យាអាចជួយបំពេញបន្ថែមនូវកង្វះធនធានមនុស្ស ព្រមទាំងបង្កើនផលិតភាពស្មើរ គ្រប់វិស័យមិនថាវិស័យឧស្សាហកម្ម ឬសេវាកម្ម ដែលអាចជួយជំរុញដល់ការសម្រេចបាននូវចក្ខុវិស័យក្នុងការអភិវឌ្ឍកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។[៩]

### ២.១.៥. វិស័យអប់រំ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីសិទ្ធិស្មើគ្នាសម្រាប់ស្ត្រីនៅគ្រប់បែបផែននៃការអប់រំ និងអាជីពទាំងឡាយក្នុងមាត្រា ៤៨-៦៣-៦៥-៦៦-៦៧ និង៦៨។ រាជរដ្ឋាភិបាលកម្ពុជា ក៏ជាហត្ថលេខីនៃសេចក្តីប្រកាសការអប់រំសម្រាប់ទាំងអស់គ្នា ហើយថែមទាំងបានសន្យាថាជាមួយនឹងគោលដៅសហសវត្ស អង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់បទដ្ឋានអប់រំផងដែរ។ ប៉ុន្តែ គម្លាតរវាងទ្រឹស្តី និងការអនុវត្តន៍ក៏នៅតែឆ្ងាយពីគ្នានៅឡើយ ។ នៅឆ្នាំ១៩៩០ អត្រាអក្ខរភាពមនុស្សចាស់បុរស គឺ៧៨% និងស្ត្រី ៤៩%។ អត្រាទាំងនេះបានកើនដល់ ៨០% ចំពោះបុរស និងស្ត្រីដល់ ៥៧% នៅឆ្នាំ២០០០ ប៉ុន្តែ ទោះជាមានការ កើនឡើងយ៉ាងនេះក្តី ក៏អត្រាអក្ខរភាពស្ត្រីកម្ពុជានៅតែទាបនៅឡើយ បើប្រៀបធៀបទៅនឹងអត្រានៃ ប្រទេសអាស៊ីផ្សេងៗទៀត។ នៅឆ្នាំ២០០៣ Oxfam GB បានអះអាងថា ស្ត្រីកម្ពុជាតែ២២% ប៉ុណ្ណោះ ដែលចេះអានកាសែតនឹងចេះសរសេរលិខិតសាមញ្ញ។ ប្រភពនានាបានបង្ហាញអត្រាអក្ខរភាពសុទ្ធតែមានសុច្ចនៈករខុសៗគ្នាទាំងអស់ ប៉ុន្តែចំណុចស្របគ្នាទូទៅមួយ គឺស្ត្រីខ្វះការយល់ដឹងជាបញ្ហាមួយធ្ងន់ធ្ងរបំផុត។

#### ២.១.៥.១. ការអប់រំនៅបឋមសិក្សា

រដ្ឋធម្មនុញ្ញបានចែងថាកុមារ ដែលមានអាយុចន្លោះពី ៦ ទៅ ១៦ឆ្នាំ នឹងត្រូវបានទទួលការអប់រំ ដោយបង្ខិតបង្ខំរយៈពេល ៩ឆ្នាំ។ ប៉ុន្តែ កុមារីជាច្រើន ហើយជាពិសេសកុមាររស់នៅជនបទមួយចំនួនមិន ដែលបានចូលរៀនសោះ ហើយខ្លះទៀតមិនបានចប់មធ្យមសិក្សាផង។ មានកត្តាបីយ៉ាង ដែលអាចបំភ្លឺឱ្យយល់អំពីបញ្ហា

[៩] គេហទំព័រ https://www.cambodia៤point0.org/kh/women-and-tech, ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៤

ចំនួនកុមារីបានរៀនបឋមសិក្សាទាបនេះ។ កត្តាទី១ ជាបញ្ហាដែលបានចាក់ឫសទៅក្នុងប្រពៃណីមួយបែបរបស់ស្ត្រី។ នៅជនបទគេគិតថាស្ត្រីជាមនុស្សសម្រាប់តែធ្វើការងារផ្ទះតែប៉ុណ្ណោះ ហេតុនេះគេមិនយល់ហើយថែមទាំងមិនទទួលស្គាល់នូវប្រសិទ្ធិភាពនៃការអប់រំកុមារីទៀតផង។ នៅក្នុងខណៈខ្លះការអប់រំត្រូវបានគេយល់ឃើញថាជាឧបសគ្គចំពោះស្ត្រី ដោយបុរសមួយចំនួនមិនចង់រៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីដែលមានការអប់រំ។ ដូច្នេះនៅក្នុងគ្រួសារក្រីក្រគេបានអោយអាទិភាពដល់កូនប្រុសទៅសាលារៀនជាជាងអោយកូនស្រី ហើយទុកកូនស្រីសម្រាប់ជួយការងារផ្ទះទៅវិញ។ កត្តាទី២ គឺបញ្ហាសាលារៀន លោកគ្រូ អ្នកគ្រូដែលមានប្រាក់បៀវត្សតិចតួច និងខ្វះធនធានបានសុំអោយកុមារបង់ថ្លៃសាលាក្រៅផ្លូវការដើម្បីទំនុកបំរុងដល់សាលា និងបុគ្គលិក។ ក្រៅពីការបង់ថ្លៃនេះនៅមានការចំណាយផ្សេងៗទៀតដូចជា ប៊ិច សៀវភៅជាដើម។ ដូច្នេះ តាមការជាក់ស្តែងការសិក្សាអប់រំជាបន្ទុកមួយដ៏ធ្ងន់ចំពោះ គ្រួសារក្រីក្រ ដែលពេលខ្លះមិនអាចដោះស្រាយបាន។ យោងតាមអង្គការ UNICEF បានលើកឡើងថា នៅពេលកុមារចុះឈ្មោះចូលរៀនដំបូងកុមារា និងកុមារីមានចំនួនស្មើៗគ្នា ហើយកត្តាដែលបានលើកឡើងរួចមកហើយ គឺជាកត្តាដែលបណ្តាលអោយកុមារីឈប់រៀនច្រើនបំផុតនៅបឋមសិក្សា" ។ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) បានធ្វើការប៉ាន់ប្រមាណថានៅឆ្នាំ២០០៣ មានសិស្សានុសិស្សត្រឹមតែ ៦០% ប៉ុណ្ណោះដែលបានរៀនចប់បឋមសិក្សា ហើយភាគច្រើនជាកុមារា"។

### ២.១.៥.២ ការអប់រំនៅមធ្យមសិក្សា និងកំរិតឧត្តមសិក្សា

នៅឆ្នាំ២០០២ ភាគរយជាមធ្យមនៃកុមារីដែលបានរៀននៅសាលាមធ្យមសិក្សា និងកម្រិតសិក្សាជាន់ខ្ពស់បានកើនដល់ ៣៦% និង៣១% ដោយនៅតាមជនបទមានអត្រាសិស្សចូលរៀនខ្ពស់ជាងមុន។ ការសិក្សានៅកម្រិតនេះក៏មានឧបសគ្គប្រហែលនឹងកត្តាជាឧបសគ្គដល់ស្ត្រីនៅក្នុងការអប់រំជាទូទៅដែរ។ ប៉ុន្តែ គេបានចាប់ផ្តើមជំហានជាវិជ្ជមានរួចហើយ ដើម្បីដោះស្រាយបញ្ហាអតុល្យភាពនេះ ហើយថែមទាំងបានធ្វើការបញ្ជាបយែនឌ័រនៅក្នុងវិស័យអប់រំនេះទៀតផង។ នៅឆ្នាំ២០០២ ក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយផ្តល់អាទិភាពមួយ ដើម្បីអោយស្ត្រីបានរៀនដល់កម្រិតសិក្សាជាន់ខ្ពស់ដែលលទ្ធផលប្រលងរបស់បេក្ខនារីថ្នាក់ទី១២ ត្រូវបានផ្តល់អាទិភាពច្រើនជាងសិស្សប្រុស។ រដ្ឋាភិបាលក៏បានបង្ហាញថា ខ្លួនមានចេតនាក្នុងការបង្កើតអោយមានគោលនយោបាយផ្តល់អាទិភាពនេះនៅក្នុងមន្ត្រីរាជការផងដែរ ជាពិសេសនៅក្នុងក្រសួងអប់រំយុវជន និងកីឡាដើម្បីបង្កើនចំនួនអ្នកគ្រូ។ សមាគមគ្រូបង្រៀនឯករាជ្យ CITA បានស្នើសុំអោយរដ្ឋាភិបាលដំឡើងប្រាក់បៀវត្សដល់លោកគ្រូ អ្នកគ្រូជាច្រើនលើកច្រើនសារព្រមទាំងសុំអោយបង្កើនមូលនិធិ ដើម្បីធានាឱ្យការសិក្សាត្រូវបានធ្វើឡើងតាមមូលដ្ឋានឥតគិតថ្លៃ ហើយធ្វើដូច្នេះទើបអាចកែលំអស្តង់ដា និងវិជ្ជាជីវៈជំនាញទូទៅបាន។ ប៉ុន្តែ សមាគមគ្រូបង្រៀនឯករាជ្យ និងសហជីពអប់រំបានជួបប្រទះនូវការបំភិតបំភ័យកាន់តែច្រើនឡើងៗនៅពេលដែលពួកគេចង់អោយមានការកែលំអតម្លាភាពប្រាក់បៀវត្ស និងស្ថានភាពប្រសើរជាងមុន។

#### ២.១.៥.៣. ការហ្វឹកហ្វឺនជំនាញ និងវិជ្ជាជីវៈ

ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនទទួលស្គាល់សារសំខាន់ នៃវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈដល់ស្ត្រីកាន់តែខ្លាំងឡើងៗតែខ្លាំងឡើង។ វគ្គហ្វឹកហ្វឺននេះ អាចជួយអោយស្ត្រីមានជំនាញច្រើនហើយមានសារៈប្រយោជន៍បំផុតក្នុងការជួយដល់ស្ត្រីក្រីក្រ និងស្ត្រីនៅតំបន់ដាច់ស្រយាលដែលងាយរងគ្រោះដោយសារការកេងប្រវ័ញ្ច។ សារៈប្រយោជន៍នៃវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈ គឺដោយវាមានរយៈពេលខ្លីជាងការរៀនសូត្រតាមបែបបុរាណ ហើយអាចផ្តល់នូវការអនុវត្តន៍ជាក់ស្តែងដល់ស្ត្រីក្នុងការជួយខ្លួនឯង។[១០]

## ២.២. ស្ត្រីខ្លាំងកម្ពុជា

### ២.២.១. លោកយាយដូនពេញ

ប្រវត្តិដើមដំបូងបង្អស់នៃ «**វត្តភ្នំ**» និងក្លាយមកជាទីក្រុង «**ភ្នំពេញ**» រហូតមកទល់សព្វថ្ងៃ។ រាជធានីភ្នំពេញត្រូវបានសាងសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៤៣៤ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត។ ភ្នំពេញ គឺមានកំណើតដំបូងពីដូនចាស់ម្នាក់ឈ្មោះពេញ។ ដូនពេញ គឺជាមនុស្សគួរឱ្យគោរពស្រឡាញ់ពីអ្នកផងទាំងពួង និងប្រកបដោយសន្តានចិត្តសប្បុរសធម៌ បានមកតាំងទីលំនៅត្រង់មុំមាត់ទន្លេ «**ចតុមុខ**» ដែលជាទីប្រសព្វនៃទន្លេមេគង្គលើ មេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់។ ថ្ងៃមួយក្នុង គ.ស ១៣៧២ ភ្លៀងបានបង្អុរចុះមួយមេយ៉ាងធំ ធ្វើឱ្យទឹកទន្លេជន់លិចលួលួច។ ពេលនោះ ដូនពេញដែលបានចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីរដ៏ធំមួយដើម ត្រូវបានទឹកទន្លេកួចអណ្តែតវិលវល់នៅក្បែរច្រាំង។ ឃើញដូច្នេះ ដូនពេញក៏ហៅអ្នកជិតខាងឱ្យមកជួយទាញយកដើមគគីរនោះមកលើគោក។ ពេលស្រង់ដើមគគីរចេញពីក្នុងទឹកបានហើយ ដូនពេញក៏ប្រទះឃើញព្រះពុទ្ធរូប ៤ព្រះអង្គតូចៗ ធ្វើពីសំរឹទ្ធិ និងទេវរូបមួយអង្គទៀតធ្វើពីថ្មស្ថិតនៅក្នុងប្រហោងឈើគគីរនោះ។ ដូនពេញ មានសេចក្តីត្រេកអរឥតឧបមា ហើយក៏បានចាត់ការសង់ខ្ទមតូចមួយសម្រាប់តម្កល់វត្ថុជាទីសក្ការៈទាំងនោះទុកជាបណ្តោះអាសន្ន។ ក្រោយមក ដូនពេញក៏អំពាវនាវឱ្យអ្នកជិតខាងជួយលើកដីពូនជាកូនភ្នំមួយហើយបន្តិចម្តងៗ កូនភ្នំនោះក៏បានក្លាយទៅជាភ្នំដ៏ធំមួយ។ ដូនពេញក៏ចាត់ឱ្យគេសង់ព្រះវិហារមួយ ដើម្បីតម្កល់ព្រះពុទ្ធរូបសំរឹទ្ធិទាំង ៤អង្គ។ ចំណែកឯព្រះពុទ្ធរូបមួយអង្គទៀតដែលធ្វើពីថ្ម ក៏ត្រូវបានគេដង្ហែយកទៅតម្កល់ក្នុងអាសនៈមួយ នៅឯជើងភ្នំប៉ែកខាងកើត នៃព្រះវិហារ។ បន្ទាប់ពីសាងសង់ព្រះវិហាររួចហើយ ដូនពេញក៏បាននិមន្តព្រះសង្ឃឱ្យមកគង់នៅលើជើងភ្នំនោះដែរ។ គឺចាប់តាំងពីពេលនោះហើយ ដែលទីតាំងនោះត្រូវបានគេហៅឈ្មោះថា « **វត្តភ្នំដូនពេញ**» ហើយដែលក្រោយមកត្រូវគេហៅកាត់ថា «**វត្តភ្នំ**» រហូតមកដល់សព្វថ្ងៃ។ ឈ្មោះ

---

[១០] សៀវភៅ ស្ថានភាពស្ត្រីនៅកម្ពុជា, Natalie Hacks, ខែកក្កដា ឆ្នាំ២០០៤, ទំព័រទី៦៥-៦៧

លោកយាយពេញ ដែលជាអ្នកសាងសង់ទីក្រុងនេះ ក៏ត្រូវគេយកទៅប្រើជាឈ្មោះទីក្រុង «**ភ្នំពេញ**» ជារៀងរហូតមក។ ចំណែកឯចេតិយនៅលើកំពូលវត្តភ្នំ ក៏ត្រូវគេប្រើសម្រាប់តម្កល់អដ្ឋិធាតុរបស់ព្រះបាទពញាយ៉ាត និងគ្រួសារព្រះរាជវង្ស។

កាលពីដើមឡើយ ភ្នំពេញគ្រាន់តែជាភូមិអ្នកនេសាទតូចមួយដ៏ស្ងៀមស្ងាត់ ដែលប្រជុំដោយផ្ទះសង់ពីស្បូវ ពីឬស្សី ឬក៏ពីឈើខ្ពស់ផុតពីដី។ រយៈកាលក្រោយមក ទីក្រុងនេះក៏បានស្គាល់អភិវឌ្ឍន៍ភាពជាបន្តបន្ទាប់។ នៅចុងសតវត្សរ៍ទី១៩ អាណាព្យាបាលបារាំង បានធ្វើកិច្ចការជាច្រើនដូចជាការជីកទំនប់ធ្វើវិថី និងសាងសង់ស្ពានតូចៗ ដែលធ្វើឱ្យភ្នំពេញក្លាយជាទីក្រុងដ៏ស្រស់ស្អាតជាងគេនៅក្នុងតំបន់។ សង្កាត់មួយត្រូវបានសាងសង់ឡើងនៅប៉ែកខាងជើងទីក្រុង ដោយយកលំនាំតាមស្ថាបត្យកម្មអាណានិគមន៍បារាំង។ ផ្ទះត្រូវបានសាងសង់ជាជួរៗ ដែលមានផ្លូវខ្វាត់ខ្វែងអមដោយរុក្ខជាតិសងខាងផ្លូវ។ គឺក្នុងសម័យកាលនោះហើយ ដែលទីក្រុងភ្នំពេញបានក្លាយជា «**ទីក្រុងគុជនៅអាស៊ី**»។ នៅដើមសតវត្សរ៍ទី២០ ភ្នំពេញក៏កាន់តែរីកធំឡើងជាលំដាប់ ដោយបន្តិចម្តងៗ ប្រឡាយ និងស្ពានទាំងឡាយត្រូវបានជំនួសដោយសួនច្បារវិញ។ នៅឆ្នាំ១៩៣៥ ការដ្ឋានសំណង់ផ្សារថ្មីក៏ត្រូវបានចាប់ផ្តើមឡើង។ សំណង់ស្ថាបត្យកម្មបេតុងដ៏មហិមា និងប្រកបដោយមហិច្ឆតា ហើយដែលត្រូវបានសារព័ត៌មានអន្តរជាតិកោតស្ញប់ស្ញែងចំពោះភាពទំនើបទាំងនោះ គឺជាជំហានថ្មីដ៏សំខាន់មួយទៀតនៃដំណើរការអភិវឌ្ឍរបស់រាជធានីភ្នំពេញ។ ក្រោយការទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ **សម្តេច នរោត្តម សីហនុ** ព្រះប្រធានសង្គមរាស្ត្រនិយម យុវស្ថាបត្យករខ្មែរក៏បានបង្កើតស្នាដៃស្ថាបត្យកម្មឯកជាច្រើនដោយការលាយបញ្ចូលគ្នារវាងស្ថាបត្យកម្មបែបថ្មី ដែលសម្របតាមនិន្នាការពិភពលោក ជាមួយនឹងស្ថាបត្យកម្មខ្មែរសុទ្ធសាធ។ សំណង់ស្ថាបត្យកម្មចម្រុះទាំងនេះហើយ ដែលផ្តល់ឱ្យទីក្រុងភ្នំពេញនូវរូបភាពជាទីក្រុងដ៏ទំនើបមួយ។ សំណង់អាកាសយានដ្ឋានខ្នាតអន្តរជាតិ និងការតភ្ជាប់ភ្នំពេញ ទៅទីក្រុងព្រះសីហនុ តាមរយៈផ្លូវរថភ្លើង បានធ្វើឱ្យភ្នំពេញក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងពាណិជ្ជកម្មដ៏សំខាន់បំផុតមួយ។

ថ្ងៃ៧ មករា ១៩៧៩ ភ្នំពេញ ត្រូវបានរំដោះចេញពីស្ថានភាពគួរឱ្យភ័យខ្លាចនេះ។ ភ្នំពេញ ក៏បានចាប់ផ្តើមមានជីវិតរស់រវើកឡើងវិញ។ ដោយការប្តេជ្ញាថានឹងមិនអនុញ្ញាតឱ្យទីក្រុងនេះធ្លាក់ក្នុងរបបប្រល័យពូជសាសន៍សារជាថ្មីម្តងទៀតនោះ អាជ្ញាធរ និងប្រជាពលរដ្ឋបានផ្តើមស្តារ និងកសាងប្រទេសឡើងវិញយ៉ាងសកម្ម។ ប៉ុន្តែកាលណោះ ពួកគេបានប្រឈមមុខនឹងបញ្ហាលំបាកជាច្រើនក្នុងដំណើរការអភិវឌ្ឍទីក្រុងនេះ។ សន្តិភាពពេញលេញទូទាំងប្រទេស និងការបង្រួបបង្រួមផ្សះផ្សារជាតិទើបតែបានទទួលនៅចុងទសវត្សរ៍១៩៩០ ប៉ុណ្ណោះ ដោយសារនយោបាយឈ្នះៗ របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ហើយចាប់តាំងពីពេលនោះមក ការស្តារទីក្រុងភ្នំពេញឡើងវិញបានស្គាល់សន្ទុះយ៉ាងលឿន ដែលធ្វើឱ្យទីក្រុងនេះផ្លាស់ប្តូរមុខមាត់ថ្មីជាបន្ត

បន្ទាប់ តាមរយៈសកម្មភាពដ៏គគ្រឹកគគ្រេងនៃការដ្ឋានសំណង់នានា។ ភ្នំពេញ ក៏បានក្លាយជាទីចាប់អារម្មណ៍របស់អ្នកវិនិយោគទុន ក៏ដូចជាអ្នកទេសចរដែរ។[១១]

### ២.២.២ ព្រះនាងឥន្ទ្រទេវី

ព្រះនាងឥន្ទ្រទេវី ត្រូវជាចៅរបស់ព្រាហ្មណ៍វុទ្រវរ្ម័ន និងមានព្រះកន្និដ្ឋាបង្កើតព្រះនាមជ័យរាជទេវី ហើយនឹងព្រះអនុជព្រះនាមឥន្ទ។ គេមិនបានដឹងពីកាលបរិច្ឆេទប្រសូត និងចូលព្រះទិវង្គតពិតប្រាកដរបស់ព្រះនាងឥន្ទ្រទេវីឡើយ។ ព្រះនាងឥន្ទ្រទេវី ជាស្ត្រីខ្មែរមួយរូបដែលមានមោទនៈចំពោះភាពរុងរឿងនៃប្រទេសកម្ពុជាសម័យអង្គរ និងសរសើរប្រទេសកម្ពុជាថា «**ស្មើមេឃ**»។ ព្រះនាងឥន្ទ្រទេវីជាមហាកវីនិពន្ធខ្មែរដ៏ល្បីនៅសតវត្សទី១៣ ដែលបានបង្ហាញឱ្យបច្ឆាជនយល់ច្បាស់នូវការរីកចម្រើននៃភាសាសំស្ក្រឹតនាសម័យនោះ ហើយនឹងប្រវត្តិនៃប្រទេសកម្ពុជា និងបានក្លាយជានិមិត្តរូបនៃអក្សរសាស្ត្រខ្មែររហូតមកទល់សព្វថ្ងៃនេះ។ ដោយសារតែកិត្តិនាមដ៏ល្បីសុះសាយរបស់ព្រះនាងនេះហើយ ទើបបច្ចុប្បន្នត្រូវបានគេយកទៅដាក់ជាឈ្មោះសាលា ឈ្មោះ បណ្ណាគារ ជាឈ្មោះរង្វាន់អក្សរសាស្ត្រជាហូរហែរ។ ព្រះនាងឥន្ទ្រទេវី បានរៀបអភិសេកក្លាយជាព្រះអគ្គមហេសីទី២ របស់ព្រះបាទជ័យវរ្ម័នទី៧ ក្រោយពេលដែលព្រះនាងជ័យរាជទេវី ដែលជាព្រះកន្និដ្ឋាបង្កើតបានយាងសោយព្រះទិវង្គតទៅ។

ព្រះនាងឥន្ទ្រទេវីជាវីរក្សត្រីខ្មែរមួយអង្គនាសម័យអង្គរ ដែលមិនត្រឹមតែមានព្រះរូបឆោមលោមពណ៌ល្អឥតមាននរណាផ្ទឹមបានប៉ុណ្ណោះទេ ព្រះនាងថែមទាំងមានវិជ្ជាសម្បត្តិខ្ពង់ខ្ពស់ឈ្លាសវៃក្នុងការសិក្សា និងចេះដឹងនូវក្បួនច្បាប់ទាំងឡាយយ៉ាងជ្រៅជ្រះទៀតផង។ មានសេចក្តីដំណាលនៅក្នុងសិលាចារឹក វិមានអាកាសថា ព្រះនាងឥន្ទ្រទេវី គឺជាក្សត្រីខ្មែរដ៏ពូកែលើសលប់ឥតមាននរណាប្រៀបផ្ទឹមបាននៅសម័យអង្គរក្នុងផ្នែកភាសាសំស្ក្រឹត និងបរមត្ថវិជ្ជា។ សិលាចារឹកដែលគេរកឃើញនៅប្រាសាទវិមានអាកាសនោះ សរសេរជាភាសាសំស្ក្រឹត ដោយស្នាមព្រះហស្ថផ្ទាល់របស់ព្រះនាងបញ្ជាក់ថា ព្រះនាងគង់នៅក្នុងនរេន្ទ្រាស្រមដែលជាមហាវិទ្យាល័យមួយនាសម័យនោះ ហើយព្រះនាងក៏ល្បីឈ្មោះក្នុងទីនោះដោយសារការងារទាំងឡាយរបស់ព្រះនាងចំពោះនារីភេទដែរ។ ប្រជានុរាស្ត្រ បានគោរពស្រឡាញ់ព្រះនាងទុកដូចជាទេពធីតា ឈ្មោះ សរស្វតី មហេសីរបស់ព្រះព្រហ្មបែងភាគមក។ ព្រះនាងឥន្ទ្រទេវី គឺជាអ្នកអប់រំដ៏ប្រពៃចំពោះព្រះកន្និដ្ឋាដើម្បីកសាងបុគ្គលិកលក្ខណៈសម្បត្តិឱ្យស័ក្តិសមជាព្រះរាជអគ្គមហេសី។ ព្រះនាងឥន្ទ្រទេវីមានចិត្តជ្រះថ្លានៅក្នុងព្រះពុទ្ធសាសនា និងក្រើនរំលឹកព្រះស្វាមីឱ្យប្រកាន់យកទសពិធរាជធម៌ក្នុងការគ្រប់គ្រងអាណាចក្រនិងប្រជានុរាស្ត្រជាដើម។ ជាមួយនេះដែរ ព្រះនាងឥន្ទ្រទេវីបានចារឹកទុកនៅក្នុងសិលាចារឹក ដែលគេបានរកឃើញនៅឯប្រាសាទវិមានអាកាសនូវទុក្ខសោកនៃ

[១១] គេហទំព័រ https://cam.kasenpost.com/?p=៤១៩១, ដកស្រង់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤

ព្រះកន្និដ្ឋារបស់ព្រះនាង នៅពេលដែលព្រះស្វាមីចេញទៅធ្វើសង្គ្រាមជាមួយពួកចាម្ប៉ា។ ចារឹកនោះពោលថា ព្រះនាងមានទឹកព្រះនេត្រជោរជន់ស្រោចព្រះកាយ ទ្រង់ព្រះកន្សែងសោយសោកដូចនាងសីតារលឹកអាល័យព្រះស្វាមីដែលឃ្លាតព្រាត់ចាកទៅថា ព្រះនាងទ្រង់សុបិន្តឃើញព្រះភក្ត្រព្រះស្វាមី ហើយថាទ្រង់យល់ឃើញនូវសេចក្តីត្រេកអរផង សេចក្តីទុក្ខផង។ ព្រះនាងតែងតែបែរបន់សូមឱ្យព្រះស្វាមីឆាប់បានយាងត្រឡប់មកវិញ ព្រះនាងទ្រង់រកឱសថរំងាប់នូវសេចក្តីទុក្ខសោកសង្រេងតាមរយៈព្រះពុទ្ធសាសនា និងការកាន់ក្រឹត្យ។ ព្រះនាងឥន្ទ្រទេវីបានបិតនៅផ្ទាល់ជាមួយព្រះស្វាមី ក្នុងការកសាងក្រុងយសោធបុរៈ ឬក្រុងអង្គរជាថ្មីឡើងវិញបន្ទាប់ពីក្រុងយសោធបុរៈនេះត្រូវពួកចាមចូលលុកលុយនៅឆ្នាំ១១៧៧។ មិនតែប៉ុណ្ណោះ ព្រះនាងបានជួយកិច្ចការព្រះនគរដល់ព្រះមហាក្សត្រ ពិសេសនៅក្នុងវិស័យអប់រំបណ្តុះបណ្តាលឱ្យប្រទេសជាតិសម្បូណ៌ទៅដោយ អ្នកប្រាជ្ញរាជបណ្ឌិតសំរាប់ជាការរៀបចំព្រះនគរនាសម័យនោះឱ្យបានចំរុងចំរើនភិយ្យោភាព។ ហេតុដូច្នេះហើយ បានជានៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ដែល មានព្រះនាងឥន្ទ្រទេវី ជាព្រះរាជអគ្គមហេសី គេសង្កេតឃើញមានសាលារៀន រោងព្យាបាលជំងឺជាច្រើន តួយ៉ាងភស្តុតាងមានប្រាសាទនាគព័ន្ធ ដែលជាមន្ទីរពេទ្យមួយដ៏មហាអស្ចារ្យនាសម័យអង្គរ និងសំណង់ជាប្រយោជន៍សាធារណៈដទៃទៀតជាច្រើនស្អេកស្កះ។ ចំណែកប្រជារាស្ត្រវិញគឺរស់នៅក្នុងសេចក្តីសុខក្សេមក្សាន្តចំរើនរុងរឿងក្នុងភាពស្តុកស្តម្ភនៃសេដ្ឋកិច្ច អរិយធម៌ដ៏ខ្ពង់ខ្ពស់ និងទទួលបាននូវមនុញ្ញផលពីសំណង់សាធារណៈនោះគ្រប់ៗគ្នា។ ព្រះនាងឥន្ទ្រទេវី និងព្រះស្វាមី ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម «**ព្រះស្រីវីរកុមារ**»។ ព្រះរាជកុមារអង្គនេះហើយ ដែលជាព្រះនិពន្ធនៃសិលាចារឹកតាព្រហ្ម និងជាអ្នកប្រាជ្ញខ្មែរដ៏ឆ្នើមម្នាក់ផងដែរ។[១២]

### ២.២.៣. លោកជំទាវបណ្ឌិត ពេជ ចន្ទមន្នី

លោកជំទាវ បណ្ឌិតពេជ ចន្ទមុន្នី គឺស្ត្រីទី១ ដែលមានប្រវត្តិការសិក្សាខ្ពស់មកពីប្រទេសលោកសេរីជាអ្នកជំនាញធ្វើការងារផ្នែកមនុស្សធម៌ និងសុខាភិបាល។

សៀវភៅ «**កូនប្រុសច្បងដ៏មានឥទ្ធិពល**» របស់អ្នកនិពន្ធ ពៅ សុខ រៀបរាប់ថា អ្នកស្រី ពេជ ចន្ទមុន្នី ជាកូនរបស់លោក ពេជ សោភ័ន មន្ត្រីសំខាន់មួយរូបនៃគណបក្សប្រជាជនកម្ពុជា ជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងម្តាយឈ្មោះ ម៉ុក ប៉ូប៉ុនរិទ្ធិ។ អ្នកស្រីបានរៀនចប់បរិញ្ញាបត្រផ្នែកឱសថសាស្ត្រនៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសុខភាពសាធារណៈនៅសហរដ្ឋអាមេរិក និងថ្នាក់បណ្ឌិតផ្នែកនេះដែរនៅប្រទេសអង់គ្លេស។ បន្ថែមពីនេះ **អ្នកស្រី ពេជ ចន្ទមុន្នី** ក៏មានតួនាទីនៅក្នុងអង្គការសមាគមមនុស្សធម៌មួយចំនួនទៀតដូចជា ប្រធានកិត្តិយស

[១២] គេហទំព័រ https://vayofm.com/news/detail/១២១៣៧៧-៨០១.html, ដកស្រង់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤

មូលនិធិគន្ធបុប្ផាកម្ពុជា និងជាអគ្គស្នងការសមាគមកាយឬទ្ធិនារីកម្ពុជា។ បច្ចុប្បន្នអ្នកស្រីជាអនុប្រធានអចិន្ត្រៃយ៍នៃកាកបាទក្រហមកម្ពុជា ដែលតាមទម្លាប់ទៅថ្ងៃមុខអ្នកស្រីនឹងស្នងតំណែងនេះពីម្ដាយក្មេក **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី**។ អ្នកស្រី **ពេជ ចន្ទមុន្នី** ជាអនុប្រធានអចិន្ត្រៃយ៍នៃកាកបាទក្រហមកម្ពុជា និងស្ដាំជាអគ្គស្នងការសមាគមកាយឬទ្ធិនារីកម្ពុជា។

កាលពីទិវាសិទ្ធិនារីអន្តរជាតិ ៨មីនា កន្លងទៅនេះ ស្ត្រីទី១ បានថ្លែងពីការលើកកម្ពស់ការអប់រំសម្រាប់ស្ត្រី និងកុមារីលើគ្រប់វិស័យ ពិសេសក្នុងផ្នែកបច្ចេកវិទ្យាឌីជីថល។ «យើងទាំងអស់គ្នាលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងវិស័យឌីជីថលការប្រើប្រាស់បច្ចេកវិទ្យា ការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មសិល្បៈ ថ្នៃប្រឌិត និងគណិតវិទ្យា»។

សមាគមកាយឫទ្ធិនារីកម្ពុជា ដែលដឹកនាំលោកស្រីបណ្ឌិត ពេជ ចន្ទមុន្នី បានដឹកនាំគណៈប្រតិភូទៅចូលរួមអង្គសន្និបាតលើកទី៣៨ របស់សមាគមកាយឫទ្ធិនារីពិភពលោកដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ នៅសាធារណរដ្ឋ និងបានព្យាយាមយ៉ាងស្វិតស្វាញ និងសកម្មដើម្បីស្នើបេក្ខភាពកម្ពុជាឱ្យបានចូលរួមបោះឆ្នោតជ្រើសរើសប្រទេសធ្វើជាម្ចាស់ផ្ទះសម្រាប់រៀបចំសន្និបាតពិភពលោកលើកទី៣៩ ឆ្នាំ២០២៦។

កម្ពុជាត្រូវបានជាប់ក្នុងចំណោម០៣ ប្រទេសចុងក្រោយរួមមានកម្ពុជា ហ្គាណា និងទុយនេស៊ី ក្រោយពីគណៈកម្មាធិការបានវាយតម្លៃយ៉ាងល្អិតល្អន់សម្រាប់ឈានទៅបោះឆ្នោតវគ្គបន្ត។ បន្ទាប់មកកម្ពុជាយើងក៏បានបន្តជាប់ក្នុងចំណោម២ ប្រទេសចុងក្រោយ គឺកម្ពុជា និងហ្គាណាដើម្បីឈានទៅបោះឆ្នោតសម្រេចផ្ដាច់ព្រ័ត្រហើយនៅទីបំផុត និងជាលទ្ធផលប្រវត្តិសាស្ត្រ និងមហាកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតដែលព្រះរាជាណាចក្រកម្ពុជាយើងត្រូវបានជ្រើសរើសឱ្យធ្វើជាម្ចាស់ផ្ទះរៀបចំសន្និបាតពិភពលោកលើកទី៣៩ ឆ្នាំ២០២៦ របស់សមាគមកាយឫទ្ធិនារីពិភពលោក (39th WAGGGS Conference)។ សូមបញ្ជាក់ថា សមាគមកាយឬទ្ធិនារីពិភពលោកមានសមាជិកមកពី ១៦៩ប្រទេសមកពីគ្រប់ទ្វីបលើពិភពលោក។[១៣]

### ២.២.៤. អ្នកនាង រស់ រតនៈ (Chef Nak)

អ្នកនាង **រស់ រតនៈ** ទាំងឆ្លាតស្អាតពូកែ ប្រវត្តិ **Chef Nak** មុនក្លាយជាចុងភៅផ្ដើមបង្កើតសៀវភៅធ្វើម្ហូបខ្មែររហូតឈ្នះពានរង្វាន់អូស្ការលំដាប់ពិភពលោក។ មានភក្តីភាពទៅលើម្ហូបខ្មែរ និងមហិច្ឆតាផ្សព្វផ្សាយវប្បធម៌ខ្មែរតាមរយៈម្ហូបជាតិរបស់ខ្លួន ចុងភៅ រស់ រតនៈ ដែលត្រូវបានគេស្គាល់ថាចុងភៅណាក់ ឬ Chef Nak បាន

[១៣] គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/៣០២៨២៩-២០២៣-០៨-០៣-១០-១០-២៥.html. ដកស្រង់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

ចាប់ផ្តើមអាជីពចុងភៅជាមួយបេសកកម្មរបស់ខ្លួនគឺដើម្បីអភិរក្ស និងលើកកម្ពស់ម្ហូបខ្មែរនៅក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក ព្រមទាំងបំផុសគំនិត និងកត់ចំណាំជាមួយការច្នៃប្រឌិតថ្មីបន្ថែមនៅក្នុងសិល្បៈធ្វើម្ហូប។

ដំណើរដើមទងមុនក្លាយជាចុងភៅអាជីព ក្រោយលាលែង ការងារពីអង្គការមួយនៅក្នុងឆ្នាំ២០១៧ អ្នកនាង រស់ រតនៈ បានចាប់ផ្តើមទៅលើការចម្អិនម្ហូបខ្មែរ និងបើកកន្លែងផ្តល់សេវាកម្មអាហារលក្ខណៈជាក្រុមបែបប្រណិតនៅផ្ទះឈើ របស់អ្នកនាងហៅថា «Chef Nak Luxury Home Dining» មានទីតាំងនៅក្បែរទន្លេមេគង្គភាគខាងជើងនៃរាជធានីភ្នំពេញ។ គ្រានោះអ្នកនាងបានចាប់ផ្តើមទន្ទឹមគ្នានឹងការ ចងក្រងសៀវភៅធ្វើម្ហូប ដោយបានធ្វើដំណើរទៅតាមទីជនបទនានាក្នុងប្រទេសកម្ពុជាដើម្បីសិក្សាស្វែងយល់ កត់ត្រាគ្រឿងផ្សំ និងរបៀបធ្វើម្ហូបខ្មែរ រហូតបានបោះពុម្ពផ្សាយសៀវភៅធ្វើម្ហូបដំបូងរបស់ខ្លួននៅក្នុងឆ្នាំ២០១៩ ក្រោមចំណងជើង «**ញ៉ាំ**» មានជាភាសាខ្មែរ និងអង់គ្លេស។ មកដល់ឆ្នាំ២០២៣ ចុងភៅដែលជាភរិយាពោរពេញទៅដោយក្តីស្រឡាញ់ និងជាអ្នកម្តាយនៃកូនប្រុសពីរនាក់រូបបានអភិវឌ្ឍន៍ផ្ទះដែលជាកន្លែងផ្តល់សេវាកម្មទទួលទានអាហាររបស់ខ្លួនកាន់តែធំជាងមុន ដោយនាំយកផ្ទះខ្មែរបុរាណចំនួនពីរ មួយមកពីខេត្តបាត់ដំបង និងមួយទៀតមកពីខេត្តសៀមរាបរៀបចំសាងសង់ឡើងវិញនៅក្នុងទីតាំងរបស់ខ្លួនដើម្បីផ្តល់បទពិសោធន៍ដល់ភ្ញៀវកាន់តែពិសេសឡើង។

ចំណែកឯសៀវភៅធ្វើម្ហូបវិញ បន្ទាប់ពីដាក់លក់នៅតាមបណ្តា៤០ ប្រទេសប្រកបដោយភាពជោគជ័យ អ្នកនាងបានបញ្ចេញសៀវភៅថ្មីមួយទៀតកាលពីខែមិថុនាក្រោមចំណងជើង «**សោយ**» ឬ «**SAOY-Royal Cambodian Home Cuisine**» ដែលទទួលបានការគាំទ្រគួរឱ្យកត់សម្គាល់។ ចក្ខុវិស័យរបស់អ្នកនាង រស់ រតនៈ ក្នុងនាមជាចុងភៅគឺសិល្បៈធ្វើម្ហូបខ្មែរមានការទទួលស្គាល់ និងល្បីល្បាញពាសពេញពិភពលោក។ ជាស្ត្រីមែនពិត តែអ្នកនាង រស់ រតនៈ ហាក់បំពេញតួនាទីច្រើនជាភរិយាផង ជាម្តាយផង និងមានអាជីពជាចុងភៅផងដែលនេះអាចថាខ្លាំងជាងបុរសទៅទៀត។ អ្នកនាងត្រូវ បានគេចាត់ទុកជាមេចុងភៅស្រីល្បីឈ្មោះដំបូងគេនៅកម្ពុជាដែលមានបេសកកម្មអភិរក្សម្ហូបខ្មែរ និងនាំយកម្ហូបខ្មែរទៅកាន់ឆាកពិភពលោក រហូតកាលពីថ្មីៗនេះ សៀវភៅធ្វើម្ហូបមានចំណងជើង «**សោយ**» ដែលបង្កើតឡើងដោយចុងភៅស្រីរូបនេះបានឈ្នះរង្វាន់ Gourmand Award ជាសៀវភៅធ្វើម្ហូបល្អបំផុតនៅលើពិភពលោក ដែលសារព័ត៌មានអន្តរជាតិដាក់រហស្សនាមថាជា «**ពានរង្វាន់អូស្ការ**» ក្នុងវិស័យពានរង្វាន់ធ្វើម្ហូបអាហារ។ ខណៈចុងភៅនៅផ្ទះភាគច្រើនជាស្ត្រី រីឯចុងភៅអាជីព ក្នុងវិស័យភោជនាហារភាគច្រើនជ្រើសរើសជាបុរស អ្នកនាង រស់ រតនៈ បានលើកឡើងថា «ខ្ញុំដឹងថាវាអាចមានភាពលម្អៀងដែលស្ត្រីយើងប្រឈមនៅក្នុងឧស្សាហកម្មនេះប៉ុន្តែវាជារឿងដ៏សំខាន់ដែលយើងទាំងអស់គ្នាត្រូវក្រោកឈរឡើងដើម្បីលើកកម្ពស់ភាពស្មើគ្នា និងផ្តល់ឱកាសដល់ស្ត្រីដែលមានបំណងចង់ក្លាយជាចុងភៅអាជីពឱ្យរីកចម្រើន»។

អ្នកនាងបន្ថែមទៀតថា «អ្នកគ្រប់គ្នាគួរតែមានសេរីភាព ក្នុងការជ្រើសរើសវិថីអាជីពរបស់ខ្លួនទៅតាមមហិច្ឆតា ជំនាញ ចំណង់ចំណូលចិត្ត និងការស្រឡាញ់របស់ពួកគេដោយមិនគិតទៅលើភេទ។ ស្ត្រីដែលជ្រើសរើសអាជីពក្លាយជាចុងភៅពួកគេនឹងនាំយកនូវទស្សនៈពិសេសដោយឡែកភាពច្នៃប្រឌិត និងទេពកោសល្យមកកាន់តុអាហារ រួមជាមួយមុខម្ហូបទៅតាមបទពិសោធន៍រៀងៗខ្លួន។[១៤]

[១៤] គេហទំព័រ https://www.popular.com.kh/social/៧៩២១២២.html/, ដកស្រង់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

# ជំពូកទី៣

# ផលវិបាក និងដំណោះស្រាយ

# ជំពូកទី៣

# ផលវិបាក និងដំណោះស្រាយ

## ៣.១. ផលវិបាក

ឧបសគ្គរបស់ស្ត្រីក្នុងមុខដំណែងដឹកនាំមានឫសគល់ពីសង្គមមួយដែលមានបុរសច្រើនជាងស្ត្រីនៅក្នុងតួនាទីដឹកនាំ ទន្ទឹមនឹងនោះស្ត្រីជួបប្រទះនូវកត្តាប្រឈមច្រើនជាងបុរសនៅក្នុងការឈោងចាប់យកនូវមុខតំណែងខ្ពស់។ អាចយល់បានថាបរិយាកាសការងារហាក់បីដូច ជាអំណោយផលសម្រាប់បុរសជាងស្ត្រី។ ម្យ៉ាងវិញទៀត ការចាប់យកមុខតំណែងជាអ្នកគ្រប់គ្រង ក៏អាចជាបញ្ហានៃការធ្វើឱ្យមានតុល្យភាពជីវិត និងតុល្យភាពការងាររបស់ស្ត្រីផងដែរ ពីព្រោះពួកគាត់ត្រូវបានផ្ទត់គំនិតរបស់សង្គមគិតថាពួកគាត់ជាអ្នកមើលថែទាំគ្រួសារប្រសើរជាងបុរស។ យើងបានមើលឃើញស្ថានភាពស្ត្រីនៅក្នុងនយោបាយ និងការធ្វើសេចក្តីសម្រេចដែលស្ត្រីក្នុងតួនាទីដឹកនាំមានតិចជាងបុរសគ្រប់មុខតំណែងរាប់ចាប់ពីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ រហូតដល់មុខតំណែងនៅក្នុងសភា និងនៅក្នុងគណៈរដ្ឋមន្ត្រីជាដើម។

ស្ត្រីមានទំនោររៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងបើប្រៀបធៀបនឹងបុរស។ ដូចដែលបានបង្ហាញនៅក្នុងជំពូកផ្នែកអប់រំស្ត្រីដែលបានបញ្ចប់ការសិក្សានៅកម្រិតឧត្តមសិក្សាមានតែ៤ភាគរយប៉ុណ្ណោះនៅក្នុង ចំណោមស្ត្រីទាំងអស់ រីឯបុរសបានបញ្ចប់ការសិក្សាក្នុងកម្រិតដូចគ្នាមានចំនួនទ្វេដងនៃចំនួនស្ត្រី។ ផ្នត់គំនិតសង្គមអាចចាត់ទុកជាឫសគល់មួយទៀតដែលចូលរួមនៅក្នុងការធ្វើឱ្យមានចំនួនស្ត្រីទាបនៅក្នុងតំណែងជាអ្នកដឹកនាំជាទូទៅ។ ផ្អែកទៅលើការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០១៤ ឧបសគ្គសម្រាប់ស្ត្រីនៅក្នុងការចូលរួមជាតំណាងនៅក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈមានដូចជា៖

- **កត្តាវប្បធម៌សង្គម** តួនាទីបុរសនិងស្ត្រីនៅក្នុងសង្គម និងផ្នត់គំនិតយេនឌ័រអវិជ្ជមានដែលរាំងស្ទះការចូលរួមរបស់ស្ត្រី។ តួនាទីយេនឌ័របានបង្កើតឧបសគ្គ និងការរើសអើងទៅលើស្ត្រី ដែលជាលទ្ធផលធ្វើឱ្យមានវិសមភាពរវាងស្ត្រីនិងបុរសនៅក្នុងសង្គមកម្ពុជា។ លើសពីនេះទៅទៀត ធ្វើឱ្យស្ត្រីមានទំនួលខុសត្រូវមានសំពាធដោយសារតែកិច្ចការងារផ្ទះ និងកាតព្វកិច្ចការងារ ដែលបង្កការលំបាកសម្រាប់ស្ត្រីនៅក្នុងជីវិតសាធារណៈ និងនយោបាយ។ ទស្សនៈមួយនេះអាចនឹងឆ្លុះបញ្ចាំងកាន់តែច្បាស់តាមរយៈអង្កេតការប្រើប្រាស់ពេលវេលា( Time-use Survey ) ដើម្បីអាចមើលឃើញថា ស្ត្រី និងបុរសចំណាយពេល ២៤ម៉ោងក្នុង១ថ្ងៃទៅលើសកម្មភាពអ្វីខ្លះ។ ប៉ុន្តែការអង្កេត ការប្រើប្រាស់ពេលវេលាចុងក្រោយដែលបានបញ្ចូលនៅក្នុងអង្កេតសង្គមកិច្ច និងសេដ្ឋកិច្ចកម្ពុជា២០០៤ ជាទិន្នន័យចាស់ពេកដូច្នេះមិនអាចយកមកសិក្សានៅក្នុងរបាយការណ៍ស្ថិតិនេះបានទេ។

- **កត្តាស្ថាប័ន** ទាក់ទងនឹងការរើសអើងដែលជះឥទ្ធិពលលើ សមត្ថភាពស្ត្រីប្រសិនបើពួកគេត្រូវ ឬមិនត្រូវបានតំឡើងមុខតំណែង។ ស្ត្រីភាគច្រើនត្រូវបានគេផ្តោតឱ្យចូលរួមធ្វើការងារ ក្នុងវិស័យដែលជាប្រពៃណីគឺសម្រាប់តែស្ត្រី ហើយបិតនៅក្នុងមុខតំណែងទាបក្នុងជួររដ្ឋាភិបាល។ នៅក្នុងវិស័យដូចជាសេដ្ឋកិច្ច ការគ្រប់គ្រងទីក្រុង ឬឧស្សាហកម្មស្ត្រីនៅតែមានកង្វះខាតនូវឱកាសក្នុងការចូលរួមដំណើរការនៃការធ្វើសេចក្តីសម្រេច។ កត្តានយោបាយ កង្វះខាតនៃវិធានការបណ្តោះអាសន្នដើម្បីជំរុញល្បឿននៃការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចជាសាធារណៈ និងនយោបាយ។ វាជាវិធានការមួយដ៏ មានសារៈសំខាន់ដើម្បីសម្រេចបានសមភាពយេនឌ័រតាមរយៈការធ្វើសមធម៌យេនឌ័រ។

## ៣.១.១. បញ្ហាប្រឈមរបស់ស្ត្រីក្នុងការចូលរួមវិស័យនយោបាយ

ស្ត្រីនៅក្នុងប្រទេសកម្ពុជានៅគ្រប់សង្គមនយោបាយ នៅតែមានសមាសភាពតិចតួចនៅឡើយក្នុងសភា និងត្រូវដកចេញឆ្ងាយពីការធ្វើក្តីសម្រេចចិត្តទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ទោះបីជា មានការរីកចម្រើនក្នុងការធ្វើឱ្យប្រសើឡើងនូវការចូលរួមរបស់ស្ត្រីក្នុងផ្នែកនយោបាយ ប៉ុន្តែការរើសអើងនៅតែមានដែលផ្តល់ផលអវិជ្ជមានដល់សមត្ថភាពស្ត្រីក្នុងការឡើងឋានៈ។ ស្ត្រីនៅតែប្រមូលផ្តុំនៅក្នុងវិស័យដែលជាប្រពៃណីដោយបានភ្ជាប់ទៅនឹងបញ្ហាយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ មានបញ្ហាប្រឈមមួយចំនួនដែលស្ត្រីនៅតែប្រឈមក្នុងការចូលរួមក្នុងនយោបាយមាន។

### ៣.១.១.១. បុរសជាគំរូនៃវិស័យនយោបាយ

ទោះបីជា ស្ត្រីនៅប្រទេសកម្ពុជាត្រូវបានធានាថាមានសិទ្ធិស្មើគ្នា ដោយរដ្ឋធម្មនុញ្ញកម្ពុជាក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែងស្ត្រីនៅតែមានការរើសអើងនៅក្នុងវិស័យនយោបាយ។ ដោយសារតែបទដ្ឋានប្រពៃណីកម្ពុជា បុរសគឺជាអ្នកគ្រប់គ្រងលើវិស័យនយោបាយបុរសជាអ្នកបង្កើតច្បាប់នៃការប្រកួតប្រជែងផ្នែកនយោបាយ និងបុរសជាអ្នកកំណត់ស្តង់ដារសម្រាប់ការវាយតម្លៃ។ ស្ត្រីទំនងជាផ្តល់អាទិភាពដល់បញ្ហាសង្គមជាងដូចជាសន្តិសុខសង្គម ការថែទាំសុខភាព បញ្ហាកុមារ និងការងារក្នុងផ្ទះ។ ហេតុដូច្នេះហើយ ផលប៉ះពាល់ផ្នែកប្រពៃណីលើតួនាទីយេនឌ័រនេះ មានឥទ្ធិពលយ៉ាងខ្លាំងលើរបៀបដែលគេមើលមកលើអ្នកនយោបាយជាស្ត្រី និងអត្តិភាពដែលបុរសជាគំរូក្នុងការគ្រប់គ្រង ដែលបណ្តាលឱ្យស្ត្រីបដិសេធក្នុងការចូលរួមក្នុងវិស័យនយោបាយ។

### ៣.១.១.២. ឧបសគ្គក្នុងសង្គម-សេដ្ឋកិច្ច

លក្ខខណ្ឌសេដ្ឋកិច្ច សង្គមដើរតួនាទីយ៉ាងសំខាន់ក្នុងការជ្រើសរើសស្ត្រីក្នុង ស្ថាប័ននីតិប្បញ្ញត្តិនៅកម្ពុជា។ ស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងសង្គមមានឥទ្ធិពល ដោយផ្ទាល់ទៅលើការចូលរួមរបស់ពួកគេក្នុងផ្នែកនយោបាយ និងការធ្វើសម្រេចដោយសារតែបទដ្ឋានវប្បធម៌ និងផ្នត់គំនិតយេនឌ័រធ្វើឱ្យមានផល

វិបាកយ៉ាងខ្លាំងសម្រាប់ស្ថានភាពសេដ្ឋកិច្ចសង្គម របស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។ ការព្រួយបារម្ភទាំងនេះ គឺកើតឡើងនៅគ្រប់ដំណាក់កាលនៃជីវិតរបស់ស្ត្រីម្នាក់ៗចាប់ផ្តើមតាំងពីពួកគេនៅក្មេងវ័យ។ ទោះបីជា សមភាពយេនឌ័រក្នុងវិស័យអប់រំមានការប្រសើរឡើង ប៉ុន្តែ គម្លាតនៅតែមាន ដោយសារតែបុរសនៅតែត្រូវបានបន្តផ្តល់អាទិភាពក្នុងការ អប់រំនៅគ្រប់កម្រិតប្រាក់ចំណូលទាំងអស់។ ជាឧទាហរណ៍ អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រី និងក្មេងប្រុសនៅថ្នាក់បឋមសិក្សាគឺ ៤៨ភាគរយ និង៥២ភាគរយ ថ្នាក់អនុវិទ្យាល័យគឺ ៤៩,៧ភាគរយ និង ៥០៣ភាគរយ ថ្នាក់វិទ្យាល័យ គឺ៤៧,៧ភាគរយ និង៥២៣ភាគរយ។ ទិន្នន័យទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា អត្រាចុះឈ្មោះចូលរៀនមានភាពប្រហាក់ប្រហែលគ្នាស្មើរគ្រប់កម្រិត ជាពិសេសនៅកម្រិតអនុវិទ្យាល័យ ប៉ុន្តែអត្រាបោះបង់ការសិក្សាជាទូទៅរបស់សិស្សស្រីនៅតែមានកម្រិតខ្ពស់ជាងសិស្សប្រុស សិស្សស្រី ២០៩ភាគរយ នៅឆ្នាំ២០១៣/២០១៤) ។ ដោយហេតុនេះហើយ ស្ត្រីកម្ពុជា ជាច្រើនជាពិសេសស្ត្រីមកពីគ្រួសារក្រីក្រទទួលបានការអប់រំថ្នាក់ខ្ពស់ (ឧត្តមសិក្សា) នៅមានកម្រិតនៅឡើយ ដែលបណ្តាលឱ្យស្ត្រីអត់មានការងារធ្វើ និងក្លាយជាស្ត្រីក្រីក្រ។ ភាពក្រីក្រជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ស្ត្រីក្នុងការចូលរួមក្នុងឆាកនយោបាយនៅពេលដែលបញ្ហាចម្បងរបស់ពួកគេ គឺការរស់រានមានជីវិត ហើយពួកគេមិនមានជម្រើសណាផ្សេងក្រៅពីចំណាយពេលវេលាសម្រាប់បំពេញតម្រូវការមូលដ្ឋានក្នុងគ្រួសាររបស់ពួកគេនោះឡើយ។ បន្ថែមពីលើនេះទៅទៀតទោះបីជាស្ត្រីមួយចំនួនមានការងារពេញម៉ោងនៅក្រៅផ្ទះ ប៉ុន្តែពួកគេនៅតែដើរតួនាទីជាស្ត្រីមេផ្ទះ និងម្តាយនៅក្នុងគ្រួសារដែលពួកគេត្រូវទទួលបន្ទុក ទាំងការងារក្នុងផ្ទះ និងការងារជំនាញរបស់ពួកគេ។ បន្ទុកទាំងនេះក៏ជាឧបសគ្គមួយរបស់ស្ត្រីក្នុងការចូលរួមក្នុងឆាក នយោបាយ ឬសង្គម ពីព្រោះពួកគេមានការទទួលខុសត្រូវច្រើនទាំងការងារវិជ្ជាជីវៈ និងការងារផ្ទះ។

### ៣.១.១.៣. ខ្វះទំនុកចិត្ត និងការគាំទ្រពីសង្គម និងសមាជិកគ្រួសារ

គ្រួសារកម្ពុជាភាគច្រើនមិនសូវលើកទឹកចិត្ត ស្ត្រីឱ្យចូលរួមក្នុងវិស័យនយោបាយ ដោយសារតែប្រពៃណីជឿថា ស្ត្រីកើតមកគឺសម្រាប់តែធ្វើការងារជាមេផ្ទះ និងការងារនៅក្នុងផ្ទះ។ ជាមួយហេតុផលនេះហើយ បានធ្វើឱ្យស្ត្រីខ្វះទំនុកចិត្តលើខ្លួនឯងក្នុងការក្លាយខ្លួនជាអ្នកតំណាងនៅក្នុងស្ថាប័ននយោបាយជាផ្លូវការណាមួយដូចជា សភា ក្រសួង ឬគណបក្សនយោបាយ។ បើគ្មានទំនុកចិត្ត និងការប្តេជ្ញាចិត្តទេ ស្ត្រីមិនអាចឈានទៅដល់កម្រិតខ្ពស់ បំផុតនៅក្នុងឆាកនយោបាយបានទេ។ ហើយប្រសិនបើស្ត្រីទទួលបានឱកាសដូចគ្នានឹងបុរស ស្ត្រីក៏អាចទាមទារសិទ្ធិសេរីភាពរបស់ពួកគេ។ ស្ត្រីពូកែខាងធ្វើយុទ្ធនាការ អ្នករៀបចំ និងគៀងគរការគាំទ្រ ប៉ុន្តែភាពភ័យខ្លាចពេលខ្លះ បានរារាំងស្ត្រីក្នុងការចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត និងចូលរួមក្នុងឆាកនយោបាយ។ ហេតុដូច្នេះហើយ ស្ត្រីត្រូវការការគាំទ្រយ៉ាងខ្លាំងពីសង្គម និងសមាជិកគ្រួសាររបស់ពួកគេ ហើយត្រូវមានការអប់រំខ្ពស់ដើម្បីចូលរួមក្នុងផ្នែកនយោបាយ និងការធ្វើសេចក្តីសម្រេច។

នៅស្ថាប័នមួយចំនួន ស្ត្រីមិនទទួលបានជំនាញបច្ចេកវិទ្យាមួយចំនួននោះទេដូចជា ថ្នាក់ IT មានស្ត្រីតែ ៥ នាក់ក្នុងចំណោមសិស្ស ៣០នាក់ដែលបានទៅរៀនផ្នែក IT។ ហើយមានមុខវិជ្ជាជីវៈមួយចំនួនទៀតដូចជា ខាងសំណង់ ខាងលើគ្រឿងយន្តស្ត្រីមិនសូវបានលើកតម្កើងឡើយ ដូចនេះ វានៅតែមានបញ្ហាប្រឈមសម្រាប់ គាត់ហើយកត្តាប្រឈមចុងក្រោយនោះគឺការអនុវត្តគោលនយោបាយសមភាពយេនឌ័រតែម្តង។ ប្រសិនបើយើង ចេញតែគោលនយោបាយមិនបានអនុវត្តទេសមភាពយេនឌ័រនឹងមិនត្រូវលើកតម្កើនទេ។

## ៣.១.២. ឧបសគ្គរារាំងការចូលរួមរបស់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យានៅកម្ពុជា

បច្ចេកវិទ្យាមានការរីកចម្រើនជាលំដាប់ ហើយបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងស្ទើរគ្រប់វិស័យនៃ សង្គមសេដ្ឋកិច្ចជាតិ។ ស្ត្រីមានសមត្ថភាព និងគំនិតច្នៃប្រឌិតប្លែកៗ ដែលអាចចូលរួមយ៉ាងសកម្មដល់ការ អភិវឌ្ឍបច្ចេកវិទ្យានៅកម្ពុជា ប៉ុន្តែការចូលរួមរបស់ពួកគេមានចំនួនតិចនៅឡើយ។ ខាងក្រោម នេះជាឧបសគ្គ មួយចំនួនដែលស្ត្រីកម្ពុជាកំពុងជួបប្រទះ ដែលរារាំងដល់ការចូលរួមរបស់ពួកគេក្នុង វិស័យបច្ចេកវិទ្យារួមមាន៖

- **បទដ្ឋានសង្គម** បទដ្ឋានសង្គមមួយចំនួនអាចធ្វើឱ្យស្ត្រីយល់ឃើញថាពួកគេមិនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ក្នុងការចាប់អាជីពក្នុងវិស័យបច្ចេកវិទ្យា។ ជាក់ស្តែង មានមតិមួយចំនួនបានលើកឡើងថា ការងារក្នុងវិស័យដូចជា គណនេយ្យ ទីផ្សារ និងទំនាក់ទំនងជាដើម។ ជាការងារស័ក្តិសមនឹងស្ត្រី រីឯ ការងារក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ជាការងាររបស់បុរស ហើយដែលចំណុចនេះ បានធ្វើ ឱ្យស្ត្រីភាគច្រើនស្ទាក់ស្ទើរក្នុងការចាប់អាជីពក្នុងវិស័យបច្ចេកវិទ្យា។ ជាឧទាហរណ៍ យោងតាម គេហទំព័រ CambojaNews នៅឆ្នាំ២០២១ ស្ថាបនិកនៃកម្មវិធី Code for Girl ដែលជាកម្មវិធីផ្តល់ការបណ្តុះបណ្តាល ផ្នែកសរសេរកូដតាមអនឡាញដល់ក្មេងស្រី ពិសេសក្មេងស្រីនៅតាមជនបទ បានលើកឡើងថាក្មេង ស្រីភាគច្រើនយល់ឃើញថា «**ការងារសរសេរកូដជាការងាររបស់បុរស**»។ មតិនេះបានធ្វើឱ្យក្មេងស្រីជា ច្រើនស្ទាក់ស្ទើរក្នុងការបន្តការសិក្សាទាក់ទងនឹងការសរសេរកូដនៅថ្នាក់ឧត្តមសិក្សា។
- **ចំណង់ចំណូលចិត្ត** យោងតាមការសិក្សាស្រាវជ្រាវរបស់លោក កៅ សុវណ្ណសុផល ស្តីពី **«អាកប្បកិរិយា របស់សិស្សវិទ្យាល័យនៅកម្ពុជាចំពោះវិទ្យាសាស្ត្រ និន្នាការ និងគំរូ»** នៅឆ្នាំ២០១៩ សិស្សប្រុសមាន អាកប្បកិរិយាវិជ្ជមានចំពោះមុខវិជ្ជាវិទ្យាសាស្ត្រជាងសិស្សស្រី ហើយពួកគេមានគម្រោង ច្បាស់លាស់ ជាងក្មេងស្រីក្នុងការចាប់ជំនាញផ្នែកវិទ្យាសាស្ត្រនាពេលអនាគត និងមានភាពសប្បាយ រីករាយជាង ក្មេងស្រីនៅពេលធ្វើការអនុវត្តជាក់ស្តែងនូវការងារទាក់ទងនឹងវិទ្យាសាស្ត្រ។ ក្មេងស្រីភាគច្រើនត្រូវជួយ កិច្ចការងារផ្ទះរបស់ឪពុកម្តាយ ដែលធ្វើឱ្យពួកគេមានពេលវេលាតិចសម្រាប់ចំណាយ ពេលស្វែងយល់ និងអនុវត្តការងារទាក់ទងនឹងមុខវិជ្ជាវិទ្យាសាស្ត្រដ៏លំបាក ដែលធ្វើឱ្យក្មេងស្រីមិនសូវ ចាប់អារម្មណ៍នឹង មុខវិជ្ជានេះ។

- **កង្វះការយល់ដឹងពីវិស័យបច្ចេកវិទ្យា** កង្វះការយល់ដឹងពីវិស័យបច្ចេកវិទ្យាក៏ជាកត្តាមួយដែលរារាំងស្ត្រីក្នុងការចូលរួមក្នុងវិស័យនេះកាន់តែច្រើន។ ជាក់ស្តែង យោងតាមរបាយការណ៍ ស្តីពី **«កត្តាជះឥទ្ធិពលដល់ការចូលរួមរបស់ស្ត្រីក្នុងអាជីពផ្នែកបច្ចេកវិទ្យានៅកម្ពុជា»** របស់ USAID នៅឆ្នាំ២០១៨ បានបង្ហាញថា ការយល់ដឹងអំពីបច្ចេកវិទ្យា ពិសេសនៅតាមទីជនបទក្នុងប្រទេសកម្ពុជាមានកម្រិតនៅឡើយ។ កង្វះការយល់ដឹងពីវិស័យនេះអាចរារាំងពួកគេក្នុងការចូលរួមក្នុងវិស័យនេះព្រោះពួកគេមិនទាន់ដឹងច្បាស់ថាតើអាជីពក្នុងវិស័យបច្ចេកវិទ្យាស័ក្តិសមនឹងពួកគេឬអត់ ហើយពួកគេមិនទាន់ដឹងពីឱកាសដែលពួកគេអាចទទួលបានពីវិស័យនេះ។
- **កង្វះការលើកទឹកចិត្តពីគ្រួសារ** យោងតាមកិច្ចសម្ភាសន៍របស់ NewsRoom Cambodia ជាមួយក្មេងស្រីដែលកំពុងបន្តការសិក្សាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅឆ្នាំ២០២០ បានបង្ហាញថា គ្រួសាររបស់ពួកគេភាគច្រើនមិនគាំទ្រឱ្យពួកគេរៀនមុខវិជ្ជានេះទេ។ សិស្សមួយចំនួនជ្រើសរើសមុខជំនាញសិក្សាដោយស្របតាមការសម្រេចចិត្តរបស់គ្រួសារ ហើយកង្វះការលើកទឹកចិត្តពីគ្រួសារបានរារាំងក្មេងស្រីជាច្រើនក្នុងការរៀនជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅថ្នាក់ឧត្តមសិក្សា។ ឪពុកម្តាយមួយចំនួនបានយល់ឃើញថាក្មេងស្រីមិនគួររៀនជំនាញដែលពិបាក ហើយពួកគាត់ក៏មិនសូវយល់ពីសារៈសំខាន់និងឱកាសដែលក្មេងស្រីអាចទទួលបានពីវិស័យនេះផងដែរ។
- **កង្វះគំរូជាស្ត្រី** យោងតាមរបាយការណ៍របស់ USAID ស្តីពី **«កត្តាជះឥទ្ធិពលដល់ការចូលរួម របស់ស្ត្រីក្នុងអាជីពផ្នែកបច្ចេកវិទ្យានៅកម្ពុជា»** នៅឆ្នាំ២០១៨ ក៏បានបង្ហាញថា គ្រូបង្រៀនផ្នែក ព័ត៌មានវិទ្យា និងអ្នកជោគជ័យក្នុងផ្នែកនេះភាគច្រើនជាបុរស ដែលធ្វើឱ្យសិស្សស្រីមានការលំបាកក្នុងការស្វែងរកអ្នកដែលមានចរិតលក្ខណៈដូចគ្នាធ្វើជាគំរូ។ ការណ៍នេះ អាចធ្វើឱ្យស្ត្រីយល់ឃើញថាពួកគេមិនអាចទទួលបានជោគជ័យក្នុងវិស័យនេះដូចបុរស។[១៥]

## ៣.២. ដំណោះស្រាយ

### ៣.២.១. អនុសញ្ញាស្តីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី

ចាប់តាំងពីការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមកសមភាពរវាងបុរស ស្ត្រី និងការមិនរើសអើងក្នុងការទទួលបានសិទ្ធិនានា គឺជាគោលការណ៍ជាសារវ័ន្តនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ មានចែងពីបទបញ្ញត្តិនានា ដែលបញ្ជាក់ច្បាស់ថា ស្ត្រីពិតជាត្រូវទទួលបានសិទ្ធិមនុស្សដូចគ្នាដូចបុរសដែរដោយផ្អែកលើមូលដ្ឋានសមភាព និងដោយមិនមានការរើសអើងណាមួយឡើយ។ ទោះជាយ៉ាង

[១៥] សៀវភៅ វឌ្ឍភាពស្ត្រីក្នុងវិស័យនយោបាយ, លោកស្រី គីម កែវធីតា និងលោកស្រី ជា ម៉ាលីកា, ខែកញ្ញា ឆ្នាំ២០១៦, ទំព័រ៥-៦

ណាក៏ដោយ ស្ត្រីពាសពេញពិភពលោកបន្តប្រឈមនឹងឧបសគ្គនានាក្នុងការទទួលបានសិទ្ធិមនុស្សរបស់គេដោយឈរលើមូលដ្ឋានស្មើភាពគ្នានឹងបុរសរួមទាំងការរើសអើងក្នុងទំរង់ជាច្រើន។

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ អង្គការសហប្រជាជាតិបាន អនុម័តសន្ធិសញ្ញាមួយ សំដៅដោះស្រាយនូវឧបសគ្គមួយចំនួនដែលរារាំងស្ត្រីមិនឱ្យទទួលបានសិទ្ធិស្មើគ្នានេះ គឺអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (**CEDAW**)។ មិនដូចកតិកាសញ្ញាអន្តរជាតិ មួយស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមួយទៀត ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ **CEDAW** មិនបានចែងពីសិទ្ធិមនុស្សសំខាន់ថ្មីៗនោះទេ សិទ្ធិមនុស្សទាំងអស់បានចែងនៅក្នុងកតិកាសញ្ញាទាំងនេះហើយដូចជា សិទ្ធិរស់រានមានជីវិតសិទ្ធិសុខភាព ឬសេរីភាពនៃការបញ្ចេញមតិបានអនុវត្តរួចហើយចំពោះស្ត្រី ក៏ដូចជាចំពោះបុរសទាំងអស់ដែរ។ ផ្ទុយទៅវិញ **CEDAW** គ្រាន់តែស្វែងរកដំណោះស្រាយចំពោះឧបសគ្គនានាដ៏ជាក់លាក់ដែលក្នុងការអនុវត្តន៍ជាក់ស្តែងឧបសគ្គទាំងនេះនៅតែបន្តរាំងស្ត្រីជាច្រើនពីការទទួលបាននូវសិទ្ធិរបស់គេតាមមសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗទៀត។ **CEDAW** ជារឿយៗត្រូវបានហៅថា **សន្ធិសញ្ញាសិទ្ធិនារី**។

អនុសញ្ញានេះមិនបានលើកឡើងឱ្យច្បាស់ពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីឡើយ។ ចាប់តាំងពីការអនុម័តអនុសញ្ញានេះមក អនុសញ្ញានេះត្រូវបានទទួលស្គាល់ថាអំពើហឹង្សាប្រឆាំងនឹងស្ត្រី គឺជាមួយទំរង់មួយនៃការរើសអើងប្រឆាំងនឹងស្ត្រី ហើយចាំបាច់ត្រូវតែរកដំណោះស្រាយ។ រដ្ឋាភិបាល ត្រូវតែចាត់វិធានការដើម្បីលុបបំបាត់រាល់ទំរង់នៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីទោះជាអំពើនោះប្រព្រឹត្តឡើងជាសាធារណៈ ឬតាមគេហដ្ឋានឯកជនក៏ដោយ។ អនុសញ្ញានេះលើកឡើងពីបញ្ហានៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដោយតំរូវឱ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែងក្នុងវិស័យសំខាន់ៗ បីគឺ៖

- វិធានការទូទៅ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងយ៉ាងតឹងរឹងប្រឆាំងនឹងស្ត្រីភេទក្នុងក្របខ័ណ្ឌច្បាប់ សង្គម និងវប្បធម៌របស់ប្រទេស បន្ទាប់មកនឹងមានការចាត់វិធានការជាក់លាក់ចំពោះការទទួលបានរបស់ស្ត្រី
- សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់គេ
- សិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់គេ។ ប្រភេទទាំងបីនេះ ទាក់ទងគ្នានឹងផ្នែកទី១ ទី២ និងទី៣ នៃអនុសញ្ញានេះ។

### ៣.២.១.១. វិធានការទូទៅដើម្បីលុបបំបាត់ការរើសអើង

ភាគីនីមួយៗនៃអនុសញ្ញា **CEDAW** ត្រូវតែអនុម័តគោលនយោបាយនៃការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ដើម្បីសំរេចគោលបំណងនេះមាត្រា២ នៃអនុសញ្ញាតំរូវឱ្យរដ្ឋាភិបាលចាត់វិធានការជាក់ស្តែង

ជាបន្តបន្ទាប់ដើម្បីការពារស្ត្រីប្រឆាំងនឹងការរើសអើងតាមរយៈច្បាប់ការប្រយុទ្ធប្រឆាំងនឹងទម្លាប់នៃការរើសអើង ហើយត្រូវកែទំរង់ច្បាប់ទាំងឡាយណាដែលមានលក្ខណៈរើសអើង។ បន្ទាប់មក រដ្ឋាភិបាលត្រូវចាប់ផ្តើមលើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍ និងវឌ្ឍនភាពរបស់ស្ត្រីលើគ្រប់វិស័យរួមទាំងវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ (មាត្រា៣)។ ដើម្បីសំរេចបាននូវគោលបំណងនេះ រដ្ឋាភិបាលអាចអនុម័តនូវអ្វីដែលហៅថា វិធានការពិសេសបណ្តោះអាសន្ន សំដៅពន្លឿនសមភាពតាមព្រឹត្តិហេតុរវាងស្ត្រី និងបុរស(មាត្រា៤)។ នេះមានន័យថា មិនមែនជាទង្វើរើសអើងប្រឆាំងនឹងបុរសរបស់រដ្ឋាភិបាលក្នុងការផ្តល់សេចក្តីលំអៀងដល់ស្ត្រីឱ្យបានច្រើនជាងបុរសឡើយ ដោយឈរលើមូលដ្ឋានបណ្តោះអាសន្ននេះ ដើម្បីកែតំរូវទំលាប់រើសអើង ដែលចាក់ឫសយ៉ាងជ្រៅក្នុងសង្គម ដែលបុរសត្រួតត្រាលើស្ត្រី។

អនុសញ្ញានេះ ជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាលតតាំងនឹងគំនិតរើសអើងតាមបែបទំលាប់ដែលថា ភេទមួយទាបជាង ឬខ្ពស់ជាងភេទមួយទៀត ឬថាស្ត្រី និងបុរសត្រូវបំពេញការងារតាមតួនាទីជាក់លាក់ ដោយស្វ័យប្រវត្តិក្នុងសង្គម (មាត្រា៥)។ ឧទាហរណ៍ បញ្ហាមាតុភាព អនុសញ្ញានេះ តំរូវឱ្យមានការអប់រំតាមគ្រួសារ ដើម្បីលើកស្ទួយឱ្យមានការយល់ដឹងត្រឹមត្រូវនៃបញ្ហាមាតុភាព ថាជាតួនាទីរបស់សង្គម ហើយត្រូវទទួលស្គាល់ថាទាំងបុរស និងស្ត្រីត្រូវចែករំលែកការទទួលខុសត្រូវរួមគ្នាក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងការអភិវឌ្ឍកូនរបស់គេឱ្យទទួលបានផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់កុមារ។ អនុសញ្ញានេះក៏តំរូវឱ្យចាត់វិធានការបង្រ្កាបការជួញដូរស្ត្រី និងការធ្វើអាជីវកម្មពេស្យាកម្មលើស្ត្រីភេទ។

ការទទួលបានរបស់ស្ត្រីនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផ្នែកទី២នៃអនុសញ្ញានេះ មានចែងពីបញ្ហាជាក់លាក់មួយចំនួនទាក់ទងនឹងការរើសអើងដែលរារាំងស្ត្រីពីការទទួលបានពេញលេញនូវ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយឈរលើមូលដ្ឋានដូចបុរសដែរ ដោយអំពាវនាវឱ្យចាត់វិធានការចំពោះ៖

- លើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈ ព្រមទាំងលើកស្ទួយសិទ្ធិបោះឆ្នោតកាន់តំណែងក្នុងមុខងារសាធារណៈតាក់តែងគោលនយោបាយរបស់រដ្ឋាភិបាល និងចូលរួមក្នុងសង្គមស៊ីវិល
- លើកស្ទួយឱកាសដល់ស្ត្រី ដើម្បីធ្វើជាតំណាងរដ្ឋាភិបាលលើឆាកអន្តរជាតិ និងបំរើការងារតាមអង្គការអន្តរជាតិ
- ត្រូវធានាឱ្យស្ត្រីទាំងអស់មានសិទ្ធិស្មើគ្នាទទួលបានសញ្ជាតិ
- ការទទួលបានរបស់ស្ត្រីនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ផ្នែកទី៣នៃអនុសញ្ញានេះ មានចែងជាលំដាប់លំដោយពីបញ្ហាជាក់លាក់មួយចំនួនចំពោះការរើសអើង ដែលរារាំងដល់ការទទួលបានរបស់ស្ត្រីនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់គេ ដោយឈរលើមូលដ្ឋានដូចគ្នាដូចបុរសដែរ រួមទាំងតំរូវ

ការឱ្យចាត់វិធានការដើម្បីលុបបំបាត់ការរើសអើង និងលើកស្ទួយឱកាសស្មើគ្នាដល់ ការអប់រំរួមមាន សិទ្ធិទទួលបានការអប់រំស្មើគ្នានៅគ្រប់កំរិត រួមទាំង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំបន្ត កម្មវិធីអប់រំ និងបទដ្ឋាន អប់រំដូចគ្នាការដកចេញក្រុមនិយមពីប្រព័ន្ធអប់រំ សិទ្ធិទទួលបានមូលនីធិស្មើគ្នាសំរាប់ការអប់រំ ចាត់វិធានការកាត់បន្ថយអត្រាសិស្សស្ត្រីបោះបង់ការសិក្សា និងផ្តល់ការអប់រំផ្នែកសុខភាព និងកម្មវិធីផែនការគ្រួសារ

- ការងារ រួមមានសិទ្ធិការងារ ឱកាសស្មើគ្នាក្នុងក្របខ័ណ្ឌជ្រើសរើសការងារ និងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ លក្ខខ័ណ្ឌការងារស្មើគ្នា សេរីភាពជ្រើសរើសវិជ្ជាជីវៈ ឬការងារការទទួលបានប្រាក់កំរៃស្មើគ្នា ទទួលបានប្រយោជន៍ពីការព្យាបាល និងសន្តិសុខសង្គម។ លើសពីនេះទៀត ស្ត្រីមិនមែនជាកម្មវត្ថុនៃការរើសអើងដោយសារតែលក្ខខណ្ឌអាពាហ៍ពិពាហ៍ ឬមាតុភាពឡើយ ពួកគេអាចទទួលប្រាក់ឧបត្ថម្ភពីការឈប់សំរាកមាតុភាព និងការជួយឧបត្ថម្ភពិសេសដើម្បីអាចឱ្យឪពុកម្តាយមានលទ្ធភាពចងក្រងសង្គមគ្រួសារ និងការប្តេជ្ញាចិត្តក្នុងការងាររបស់គេ ហើយត្រូវការពារពីហានិភ័យនៅកន្លែងធ្វើការនៅពេលមានផ្ទៃពោះ
- ការថែទាំសុខភាព រួមមានការថែទាំសមរម្យនៅពេលមានផ្ទៃពោះ សំរាលកូន និងក្រោយពេលផ្តល់កំណើតកូន
- ជីវភាពសេដ្ឋកិច្ច និងសង្គមកិច្ច រួមមានទទួលបានផលប្រយោជន៍ គ្រួសារ សេវាកម្មធនាគារ និងសកម្មភាពកំសាន្ត កីឡា និងវប្បធម៌។ លើសពីនេះទៀត មាត្រា១៤ មានចែងពីបញ្ហាជាក់លាក់មួយចំនួន ដែលស្ត្រីនៅតាមជនបទប្រឈមមុខ។ ជារឿយៗ ពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាដល់ការរស់រានផ្នែកសេដ្ឋកិច្ច នៃគ្រួសាររបស់គេស្វែងរកការធានាពីការចូលរួមរបស់ពួកគេក្នុងផែនការអភិវឌ្ឍក្នុងសកម្មភាពក្រុមជួយខ្លួនឯង និងសហគមន៍។

ប្រទេសកម្ពុជា បានក្លាយជាភាគីនៃអនុសញ្ញា **CEDAW** នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញធានាការពារដល់អនុសញ្ញានេះ ព្រមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀតថាជាផ្នែកមួយនៃច្បាប់របស់កម្ពុជា។ លើសពីនេះទៅទៀត មាត្រា៤៥ បញ្ជាក់យ៉ាងច្បាស់ថា “**រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទត្រូវលុបបំបាត់**” ហើយមានមាត្រាជាច្រើនទៀត នៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិត្រង់ជំពូក៣ នៃរដ្ឋធម្មនុញ្ញចែងយ៉ាងច្បាស់ថាសិទ្ធិទាំងនេះអនុវត្តបានចំពោះពលរដ្ឋកម្ពុជាទាំងពីរភេទ”។ នៅក្នុងសេចក្តីសំរេចរបស់ខ្លួនកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ថាប័នមួយបង្កើតឡើងដើម្បីការពាររដ្ឋធម្មនុញ្ញបានបញ្ជាក់ជាថ្មីពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិក្នុងច្បាប់ជាតិកម្ពុជា ហើយបានរំលឹក

ដល់ចៅក្រមថាក្នុងការសំរេចក្តី និងការបកស្រាយច្បាប់ចៅក្រមត្រូវតែប្រកាន់ឱ្យបានខ្ជាប់តាមបទបញ្ញត្តិទាំងឡាយក្នុងសន្ធិសញ្ញានានារួមទាំងអនុសញ្ញា CEDAW ដែរ។

**៣.២.១.២. គណកម្មាធិការ** CEDAW

នៅពេលក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះ រដ្ឋនេះធ្វើការប្តេជ្ញាចិត្តដែលជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះពលរដ្ឋរបស់ខ្លួន និងជាពិសេសចំពោះស្ត្រី ក៏ដូចជាចំពោះសហគមន៍អន្តរជាតិ ថាខ្លួននឹងអនុវត្តតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិស្ត្រី ដើម្បីបញ្ចប់ការរើសអើង។ តាមរយៈសន្ធិសញ្ញានេះ គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ដែលស្គាល់ជាទូទៅថាគណកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ជួនកាលហៅថាគណកម្មាធិការ CEDAW) ត្រូវបានបង្កើតឡើងដើម្បីឃ្លាំមើលការរីកចំរើន ដែលអនុវត្តដោយរដ្ឋនានាក្នុងការបំពេញនូវការប្តេជ្ញាចិត្តរបស់ពួកគេ។ រដ្ឋទាំងអស់ចាំបាច់ត្រូវរាយការណ៍ជូនគណៈកម្មាធិការតាមកាលកំណត់ពីការចាត់វិធានការអនុវត្តអនុសញ្ញានេះ។ បន្ទាប់មកគណៈកម្មាធិការផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលសំរាប់ចាត់វិធានការបន្ថែមទៀត។ ប្រទេសកម្ពុជា បានធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាលើកដំបូងកាលពីឆ្នាំ២០០៥ ហើយគណៈកម្មាធិការ បានចេញអនុសាសន៍នៅខែមករា ឆ្នាំ២០០៦។ រដ្ឋាភិបាល ដាក់របាយការណ៍តាមកាលកំណត់លើកទី២ កាលពីខែវិច្ឆិកា ឆ្នាំ២០០៩ ហើយរបាយការណ៍នេះនឹងត្រូវពិនិត្យពិចារណាដោយគណៈកម្មាធិការនៅពេលណាមួយក្នុងឆ្នាំ២០១០ ឬឆ្នាំ២០១១។ យន្តការឃ្លាំមើលបន្ថែម ដែលមានចែងក្នុងពិធីសារបន្ថែមលើអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។

កាលពីខែធ្នូ ឆ្នាំ១៩៩៩ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តពិធីសារបន្ថែមមួយ ដែលអនុញ្ញាតឱ្យរដ្ឋនានាជ្រើសរើសដើម្បីផ្តល់សិទ្ធិដល់គណៈកម្មាធិការ CEDAW នៅក្រុងហ្សឺណែវ ពិនិត្យ ពិចារណាលើបណ្តឹងពីឯកត្តបុគ្គល ដែលអះអាងថា សិទ្ធិរបស់គេត្រូវបានរំលោភបំពាន។ គណៈកម្មាធិការ អាចទទួលបណ្តឹងបែបនេះបានតែពីបណ្តាប្រទេសណា ដែលបានជ្រើសរើសផ្តល់សច្ចាប័នលើពិធីសារនេះប៉ុណ្ណោះ ហើយអាចពិនិត្យបណ្តឹងតែនៅពេលណាបណ្តឹងនោះបំពេញបាននូវលក្ខណៈវិនិច្ឆ័យមួយចំនួន ជាពិសេស បណ្តឹងនេះអាចយកមកពិនិត្យបានលុះត្រាតែឯកត្តបុគ្គលនោះបានប្រើប្រាស់អស់ដំណោះស្រាយក្នុងស្រុកទៅហើយ។ ពិធីសារបន្ថែមនេះក៏ផ្តល់សិទ្ធិដល់គណកម្មាធិការ CEDAW ធ្វើការសាកសួរនៅពេលមានភស្តុតាងនៃការរំលោភធ្ងន់ធ្ងរជាប្រព័ន្ធចំពោះបទបញ្ញត្តិនានានៃអនុសញ្ញានេះ។

ក្រោយពីគណៈកម្មាធិការ CEDAW ផ្តល់អនុសាសន៍រួចមក នាខែសីហា ឆ្នាំ២០០៩ រដ្ឋសភាបានអនុម័តច្បាប់ជាតិមួយដើម្បីផ្តល់សច្ចាប័នលើពិធីសារបន្ថែមនេះ។ នៅពេលដែល នីតិវិធីច្បាប់អន្តរជាតិត្រូវបានបំពេញ

ចប់សព្វគ្រប់ ដើម្បីធ្វើឱ្យសច្ចាប័ននេះមានសុពលភាពតាមផ្លូវច្បាប់នៅក្នុងច្បាប់អន្តរជាតិ នោះស្ត្រីនៅប្រទេសកម្ពុជានឹងអាចដាក់បណ្តឹងបុគ្គលជូនគណៈកម្មាធិការនៅក្រុងហ្សឺណែវ ប្រសិនបើពួកគេជឿជាក់ថាជាជនរងគ្រោះនៃការរើសអើងដែលជាការរំលោភបំពានលើអនុសញ្ញានេះ។[១៦]

### ៣.២.២. ក្រសួងកិច្ចការនារី

#### ៣.២.២.១. ការបង្កើតក្រសួងកិច្ចការនារី

យោងតាមព្រះរាជក្រមស្តីពីការបង្កើតក្រសួងកិច្ចការនារី នស/រកម/០១៩៦/២២ ក្រសួងកិច្ចការនារី ត្រូវបានបង្កើតឡើងក្រោមចំណុះរាជរដ្ឋាភិបាលកម្ពុជា ហើយក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះផងដែរ ក្រសួងកិច្ចការនារីត្រូវបានដឹងនាំដោយរដ្ឋមន្ត្រីមួយរូបជានារីដែរអាចអមដោយរដ្ឋលេខាធិការ និងឬអនុរដ្ឋលេខាធិការតាមការចាំបាច់។

#### ៣.២.២.២. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

យោងតាមអនុក្រឹតស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី។ ក្រសួងកិច្ចការនារីមានមុខងារ និងភារកិច្ចដូចតទៅៈ

- ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍គោលនយោបាយជាតិ ដើម្បីធានាឱ្យស្ត្រីទទួលបាននូវផលប្រយោជន៍ដូចបុរស និងលើកកម្ពស់ស្ថានភាពរបស់ស្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញ សម្របសម្រួល តស៊ូមតិដើម្បីស្វែងរកការគាំទ្រ តាមដាន និងត្រួតពិនិត្យវាយតម្លៃការអនុវត្តគោលនយោបាយជាតិ និងកម្មវិធីផ្សេងៗ ក្នុងគោលដៅលើកកម្ពស់ស្ថានភាពស្ត្រី
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ មន្ទីរខេត្តក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ គោលនយោបាយមូលដ្ឋាន និងកម្មវិធីផ្សេងៗ ព្រមទាំងដើម្បីបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមាក្នុងក្រសួង ស្ថាប័នជាតិគ្រប់ថ្នាក់តាំងពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋាន
- សិក្សាស្រាវជ្រាវរៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗដើម្បីកាត់បន្ថយគម្លាតយេនឌ័រ និងបង្កើនឋានៈតួនាទីរបស់ស្ត្រី

[១៦] គេហទំព័រ https://cambodia.ohchr.org/sites/default/files/Treaty/CEDAW_KH.pdf, ដកស្រង់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលជំរុញដំណើរការកម្មវិធីជួយដល់ស្ត្រី ជាពិសេសស្ត្រីចាស់ជរា ឬគ្មានទីពឹង ឬពិការ ឬមេម៉ាយ ស្ត្រី និងកុមាររងគ្រោះដោយជម្ងឺអេដស៍ ដោយការជួញដូររងគ្រោះពីរាល់ទម្រង់នៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី រួមមានការចាប់រំលោភសេពសន្ថវៈ និងអំពើហឹង្សាក្នុងគ្រួសារជាដើម
- ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្តល់លទ្ធភាពក្នុងការទទួលនូវសេវាឥណទាន និងបង្កើតមុខរបរសម្រាប់ស្ត្រី
- រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយព័ត៌មានប្រឆាំងនឹងទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ
- ជំរុញឱ្យស្ត្រី និងកុមារទទួលនូវសិទ្ធិការពារតាមផ្លូវច្បាប់ និងដោយយុត្តិធម៌តាមរយៈការធ្វើជាអ្នកដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះទៅតុលាការ និងការដាក់បញ្ចូលទៅក្នុងច្បាប់ ការអនុវត្តន៍ច្បាប់ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការអប់រំឱ្យបានជាអតិបរមា
- ជំរុញឱ្យស្ត្រី និងកុមារទទួលការថែទាំសុខភាពបឋម ការប្រើប្រាស់សេវាថែទាំក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព ជាពិសេសុខភាពបន្តពូជ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងការលើកស្ទួយស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ
- ជំរុញការចូលរៀន និងកាត់បន្ថយការបោះបង់ចោលការសិក្សារបស់សិស្សស្រីនៅគ្រប់កម្រិត ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ព្រមទាំងបង្កើនអក្ខរភាព និងជំនាញរបស់ស្ត្រី
- លើកកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរតាមរយៈការផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាពដូចជាឯកសារបោះពុម្ព វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទំនើប។ល។ លើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងការរៀបចំកម្មវិធីនេះ
- ជំរុញការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារបំពេញបន្ថែមឱ្យអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង ព្រមទាំងច្បាប់ និងអនុសញ្ញាអន្តរជាតិដទៃទៀតដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី

និងកុមារ។[១៧] ហើយក្នុងនោះទៀតសោត ក្រសួងកិច្ចការនារីក៏មាន អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ចំណុះចំនួន៣នាយកដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋាន ការពារផ្លូវច្បាប់
- នាយកដ្ឋាន ស្ត្រី និងសុខភាព
- នាយកដ្ឋាន ស្ត្រី និងការអប់រំ។

**ក. ភារកិច្ចនាយកដ្ឋានការពារផ្លូវច្បាប់**

នាយកដ្ឋានការពារផ្លូវច្បាប់មានភារកិច្ចដូចជា៖

- ➢ រៀបចំគោលការណ៍ និងគោលនយោបាយដើម្បីការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី
- ➢ រៀបចំ តាក់តែង សេចក្តីព្រាងច្បាប់ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗដើម្បីការពារស្ត្រី ក្មេងស្រី ឱ្យចាកផុតពីអំពើហឹង្សា និងការកេងប្រវ័ញ្ច ហើយធានាបាននូវសមភាព និងសមធម៌យេនឌ័រ
- ➢ ចូលរួមផ្តល់យោបល់ក្នុងការតាក់តែងអត្ថបទច្បាប់ដែលរៀបចំដោយស្ថាប័នផ្សេងៗ ដែលពាក់ព័ន្ធស្ត្រី និងកុមារ
- ➢ រៀបចំឱ្យមានជាអនុស្សារណៈនៃការយោគយល់គ្នាជាមួយប្រទេសជិតខាង ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ជាពិសេស្ត្រី និងកុមារ និងកិច្ចការពារជនរងគ្រោះ និងតាមដានការអនុវត្តន៍ច្បាប់ បទប្បញ្ញត្តិ អនុស្សារណៈនានាឱ្យមានប្រសិទ្ធភាព
- ➢ កសាងសមត្ថភាពមន្ត្រី បុគ្គលិកក្រសួងតាំងពីថ្នាក់ជាតិដល់ថ្នាក់ខេត្ត ក្រុង និងក្រសួងពាក់ព័ន្ធ អំពីផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារនឹងសិទ្ធិមនុស្សលើមូលដ្ឋាននៃសមភាពយេនឌ័រខ្លឹមសារអនុសញ្ញា ពិធីសារអន្តរជាតិនិងអនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការពហុភាគីនានាដែលពាក់ព័ន្ធដល់ស្ត្រី
- ➢ កសាងសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្តរបស់ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធអំពីការទប់ស្កាត់រាល់រូបភាពនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី ជំនាញពិគ្រោះយោបល់ផ្នែកច្បាប់ និងផ្នែកចិត្តសាស្ត្រ
- ➢ សម្របសម្រួល ដើម្បីស្វែងរកការប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះ និងបញ្ជូនបន្តទៅសេវានានារបស់អង្គការក្រៅរដ្ឋាភិបាល ដែលអាចជួយពួកគេបាន

[១៧] ព្រះរាជក្រម ស្តីពីការបង្កើតក្រសួងកិច្ចការនារី, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦, មាត្រា១-៣

- សម្របសម្រួល និងជំរុញអន្តរាគមន៍តាមផ្លូវច្បាប់ដល់ជនរងគ្រោះដោយការជួញដូរ ដោយអំពើហឹង្សាក្នុងគ្រួសារ ដោយការចាប់រំលោភសេពសន្ថវៈ ឬដោយការរំលោភបំពានដទៃទៀត
- ធ្វើជាអ្នកដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះទៅតុលាការ
- អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ ផលវិបាកនៃអំពើហឹង្សាប្រឆាំងស្ត្រី និងការជួញដូរផ្លូវភេទ
- ទំនាក់ទំនង និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អ្នកផ្តល់ជំនួយ ដើម្បីអនុវត្ត និងរក្សានិរន្តរភាពការងារផ្នែកការពារផ្លូវច្បាប់ ជាពិសេសការធ្វើអន្តរាគមន៍ជួយជនរងគ្រោះ
- នាយកដ្ឋានការពារផ្លូវច្បាប់ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

### ខ. ភារកិច្ចនាយកដ្ឋានស្ត្រី និងសុខភាព

នាយកដ្ឋានស្ត្រី និងសុខភាពមានភារកិច្ចដូចជា៖

- ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព ស្ត្រី កុមារ មាតា និងទារក ដោយផ្តល់ព័ត៌មាន ស្តីពីសុខភាពអនាម័យ អាហារូបត្ថម្ភ ធ្វើការផ្សព្វផ្សាយអប់រំ អំពីសិទ្ធិ និងលទ្ធភាពទទួលបាននូវសេវាថែទាំសុខភាពដែលមានសុវត្ថិភាព ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តតាមបណ្តាខេត្ត ក្រុង និងសហគមន៍នានាដើម្បីធ្វើការងារនេះ
- ស្វែងរកការគាំទ្រពីថ្នាក់ដឹកនាំរបស់ស្ថាប័នពាក់ព័ន្ធបញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួងស្ថាប័នទាំងឡាយនូវការលើកកម្ពស់យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ការថែទាំ និងការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍
- ចរាចរ និងតស៊ូមតិដើម្បីឱ្យស្ថាប័នពាក់ព័ន្ធអនុវត្តគោលនយោបាយ និងសេចក្តីណែនាំអំពីការផ្តល់ សេវាសុខភាពដោយឥតគិតថ្លៃ និងប្រើប្រាស់មូលនិធិសមធម៌
- ពង្រឹងសមត្ថភាពមន្ត្រី បុគ្គលិករបស់ក្រសួង និងក្រុមជំនាញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យយល់ពីសិទ្ធិរបស់ស្ត្រី កុមារ ដើម្បីទទួលនូវសេវាថែទាំសុខភាពបឋម ជាពិសេសសុខភាពបន្តពូជ
- ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីសុខភាពស្ត្រី និងកុមារ។
- នាយកដ្ឋាន ស្ត្រី និងសុខភាព ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

### គ. ភារកិច្ចនាយកដ្ឋាន ស្ត្រី និងការអប់រំ

នាយកដ្ឋាន ស្ត្រី និងការអប់រំមានភារកិច្ចៈ

- ផ្សព្វផ្សាយ អប់រំ អំពីសារៈសំខាន់នៃការអប់រំសម្រាប់ស្ត្រី និងក្មេងស្រីសារៈសំខាន់នៃការថែទាំទារក និងកុមារទាំងរាងកាយ និងបញ្ញាស្មារតី ព្រមទាំងបង្កើនការយល់ដឹង អំពីសិទ្ធិកុមារ និងសិទ្ធិស្ត្រីក្នុងការទទួលនូវការអប់រំ
- សហការជាមួយក្រសួងអប់រំយុវជន និងកីឡា អង្គការ ស្ថាប័នជាតិ និងអង្គការអន្តរជាតិ ដើម្បីបន្តអភិវឌ្ឍន៍គោលនយោបាយ និងកម្មវិធីអប់រំកុមារតូច លើកកម្ពស់ការអប់រំរបស់កុមារី អក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធ រួមមាន ការផ្តល់អាហាររូបករណ៍ និងកម្មវិធីផ្តល់អាហារតាមសាលារៀន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីបង្កើត និងគ្រប់គ្រងអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី និងទារកដ្ឋាន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើជាគ្រូអក្ខរកម្ម និងអ្នកថែទាំកុមារដែលមានជំនាញ និងរៀបចំការបំប៉នសមត្ថភាពបច្ចេកទេសទៅតាមតម្រូវការជាក់ស្តែង
- សម្របសម្រួលក្នុងការបើកថ្នាក់អក្ខរកម្ម និងកន្លែងថែទាំកុមារនៅតាមភូមិគោលនិងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី
- នាយកដ្ឋាន ស្ត្រី និងការអប់រំដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។[១៨]

[១៨] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី, លេខ ១៣ អនក្រ.បក, ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥, មាត្រា៣

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវប្រធានបទខាងលើកន្លងមក យើងបានឃើញថាស្ត្រីពិតជាបានចូលរួមយ៉ាងសំខាន់ និងមើលឃើញក្នុងការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និងសង្គម។ ហើយការរួមចំណែកទាំងនេះ គឺជាការចូលរួមយ៉ាងសំខាន់សម្រាប់សុខុមាលភាពគ្រួសារ និងសហគមន៍ ពិសេសក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។ បន្ថែមពីនេះទៀតសោត ស្ត្រីកំពុងនឹងសម្រេចបាននូវយុទ្ធនាការណ៍លើកស្ទួយកម្ពស់សមភាពយេនឌ័រ ក្នុងច្បាប់គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិនានា ព្រមទាំងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ។ អាស្រ័យដូចនេះ ក្រសួងបាននឹងកំពុងជំរុញការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ ផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានកំណែទម្រង់វិមជ្ឈការ និងសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ មួយវិញទៀត ទោះបីជាយើងឃើញមានការលើកកម្ពស់ស្ត្រីនិងក្មេងស្រីក៏ដោយ ប៉ុន្តែស្ត្រីនូវតែជួបប្រទះ និងកត្តាប្រឈមច្រើនជាងបុរសនៅក្នុងការឈោងចាប់យកនូវមុខតំណែងខ្ពស់ៗអាចនិយាយបានថាបរិយាកាសការងារហាក់បីដូចជាអំណោយផលសម្រាប់បុរសជាងស្ត្រី។ ម្យ៉ាងវិញទៀត ការចាប់យកមុខតំណែងជាអ្នកគ្រប់គ្រងក៏អាចជាបញ្ហានៃការធ្វើឲ្យមាន តុល្យភាពជីវិត និងតុល្យភាពការងាររបស់ស្ត្រីផងដែរ។ ពីព្រោះពួកគាត់ត្រូវបានផ្ទត់គំនិតរបស់សង្គម គិតថាពួកគាត់ជាអ្នកមើលថែទាំគ្រួសារប្រសើរជាងបុរស។ ហើយបន្ទាប់មក រាជរដ្ឋាភិបាលក៏បានបង្កើតអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើសប្រឆាំងនិងស្ត្រី។ ចាប់តាំងពីការអនុម័តអនុសញ្ញានេះមកត្រូវបានគេទទួលស្គាល់ថាអំពើហឹង្សាប្រឆាំងនឹងស្ត្រី គឺជាទម្រង់មួយនៃការរើសអើសប្រឆាំងនឹងស្ត្រី ហើយចាំបាច់ត្រូវតែរកដំណោះស្រាយ។

យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវលើប្រធានបទស្ត្រី និងការអភិវឌ្ឍជាតិបានធ្វើឲ្យនាងខ្ញុំទាំងពីរនាក់មានការយល់ដឹងកាន់តែច្បាប់អំពីការលើកស្ទួយ និងផ្តល់តម្លៃឲ្យស្ត្រី ដើម្បីជាឱកាសសម្រាប់ស្ត្រីក្នុងការចូលរួមសកម្មភាពសេដ្ឋកិច្ច នយោបាយនិងសង្គមជាតិឲ្យបានច្រើនឡើងជាងមុន។ ហើយទាំងនេះ គឺជាលទ្ធផលនៃសកម្មភាពលើកស្ទួយរបស់ស្ត្រីរយៈពេលជាច្រើនឆ្នាំកន្លងទៅពីសំណាក់រដ្ឋាភិបាលបក្សនយោបាយ និងអង្គការសង្គមស៊ីវិល។ ការលើកស្ទួយសិទ្ធិស្ត្រីឲ្យស្មើបុរសក្នុងគ្រប់វិស័យ និងការដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីឲ្យបានរួសរាន់ គឺជាកិច្ចការចំពោះមុខរបស់រដ្ឋាភិបាល។ ស្ត្រីខ្មែរគួរតែក្លាយជាអ្នករួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសទៅតាមសមត្ថភាពរៀងៗខ្លួន ហើយការលើកស្ទួយសិទ្ធិស្ត្រីក៏មិនគួរក្លាយជាមូលហេតុធ្វើឲ្យបែកបាក់សង្គមគ្រួសារខ្មែរនោះដែរ។ ក្នុងនាមជាប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា មិនថានាងខ្ញុំ ប្រជាពលរដ្ឋប្រុស ស្រី ចាស់ ក្មេងទេ គឺត្រូវតែចូលរួមចំណែកមិនអាចខ្វះបានក្នុងការលើកតម្កើងស្ត្រីក្នុងការសម្រេចចិត្តជាមួយនឹងភាពជាអ្នកដឹកនាំ។ ទោះបីថាយើងជាបុរស យើងក៏ត្រូវយល់ដឹងនឹងលើកតម្កើងស្ត្រីដែរ ព្រោះយើងអាចមានប្អូនស្រី

មានម្តាយ និងប្រពន្ធនៅក្បែរៗខ្លួនយើង ហើយឥឡូវនេះ ការលេចធ្លោរបស់ស្ត្រីនៅក្នុងសង្គមមិនមែនថាមានសមភាពយេនឌ័រហើយ គឺល្អប្រសើរទាំងអស់នោះទេ បើយើងក្រឡេកទៅមើលផ្នែកជនបទវិញ ស្ត្រីខ្លះនូវតែអត់ចេះអក្សរ នេះគឺជាបញ្ហាប្រឈមសម្រាប់ពួកគាត់។ ការលើកតម្កើងអាចធ្វើឡើងបានក្នុងរូបភាពច្រើនជាច្រើនដូចជា អ្នកខ្លះជាដៃគូអាជីវកម្មរបស់ស្ត្រី អ្នកខ្លះជួបជជែកជាមួយស្ត្រី អ្នកខ្លះព្យាយាមដោះស្រាយបញ្ហាជាមួយស្ត្រីអ្វីដែលសំខាន់នោះ គឺយើងកុំមើលរំលងវា។ នៅក្នុងក្រុមគ្រួសារ មិត្តភក្តិ ឬនៅក្នុងសង្គមក្បែរយើង យើងត្រូវបង្រៀនពួកគាត់បន្តិចម្តងៗទាក់ទងនឹងសមភាពយេនឌ័រ។ យើងក៏អាចចូលរួមផ្តល់ជាយោបល់ក្នុងការចូលរួមចំណែកដោះស្រាយបញ្ហានានាផងដែរ។

សរុបជារួមមកយើងអាចសន្និដ្ឋានបានថា ប្រធានបទខាងលើពិតជាមានសារៈណាស់ ចំពោះមនុស្សគ្រប់រូប ជាពិសេសស្ត្រី និងកុមារី ពីព្រោះប្រធាននេះបានបង្ហាញឱ្យឃើញពីការវិវត្តរបស់ស្ត្រីភេទ តាំងពីសង្គមមិនអោយតម្លៃរហូតដល់ពេលដែលសង្គមទទួលស្គាល់នូវសមត្ថភាព និងអោយតម្លៃ ពិសេសនោះគឺលើកតំកើនតម្លៃរបស់ស្ត្រី និងកុមារីមានការផ្តល់អតិភាព និងជួយជ្រោមជ្រែងពីសំណាក់អ្នកជុំវិញ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវកន្លងមក និងឃើញពីស្ថានភាពរបស់ស្ត្រី យើងឃើញថារយៈពេលចុងក្រោយនេះ គឺបានផ្លាស់ប្តូរយ៉ាងខ្លាំងនាពេលបច្ចុប្បន្ននេះ។ ជាពិសេសការអនុវត្តគោលការណ៍ជាសារវ័ន្តនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗមានចែងពីបទបញ្ញត្តិនានាដែលបញ្ជាក់ច្បាស់ថាស្ត្រីពិតជាត្រូវទទួលបានសិទ្ធិមនុស្សដូចគ្នានឹងបុរសដែរដោយផ្អែកលើមូលដ្ឋានសមភាព និងមិនមានការរើសអើងណាមួយឡើយ។

នាងខ្ញុំទាំងពីរនាក់ សូមបញ្ចេញមតិដើម្បីចូលរួមដោះស្រាយដូចជា៖

- ផ្សព្វផ្សាយច្បាប់នានាដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈទាំងអស់
- បង្កើនចំនួនស្ត្រីក្នុងតួនាទី ដែលត្រូវធ្វើការសម្រេចចិត្តនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងជួររដ្ឋាភិបាល ដើម្បីឱ្យជនរងគ្រោះ ដោយអំពើហិង្សាក្នុងគ្រួសារមានអារម្មណ៍កក់ក្តៅជាងមុនក្នុងការស្វែងរកជំនួយ
- ប្រឹងប្រែងបង្កើនចំនួនចៅក្រមមេធាវី និងមន្ត្រីនគរបាលស្ត្រីឱ្យបានកាន់តែច្រើនជាងមុន
- បង្កើនបរិមាណជម្រកសុវត្ថិភាព និងសេវាសង្គមឱ្យបានច្រើនជាងមុន និងការបណ្តុះបណ្តាលវិជ្ជាជីវៈនៅពេលណាដែលចាំបាច់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ
- ស្នើរឱ្យមានការបង្កើនចំនួនថវិកាជាតិ ដើម្បីអនុវត្តកម្មវិធីប្រឆាំងអំពើហិង្សាក្នុងគ្រួសារឱ្យបានសមរម្យ
- ជម្រុញឱ្យមានសហគ្រាស ដែលកាន់កាប់ដោយស្ត្រីដើម្បីឱ្យស្ត្រីកាន់តែមានឯករាជ្យភាពខាងហិរញ្ញវត្ថុ
- លើកស្ទួយការតាមដានឱ្យបានខ្លាំងក្លា និងមិនលំអៀងយេនឌ័រដោយអាជ្ញាធរអំពីបណ្តឹងអំពើហិង្សាក្នុងគ្រួសារ
- អនុវត្តការអប់រំដោយឥតគិតថ្លៃចំពោះកុមារី និងស្ត្រីទាំងអស់
- ផ្តល់ការព្យាបាលសុខភាពដោយឥតគិតថ្លៃដល់គ្រួសារក្រីក្រ
- ជម្រុញនិងលើកទឹកដល់ស្ត្រីក្នុងការសិក្សាមុខជំនាញឌីជីថល
- លើកកម្ពស់ឱ្យមានការបកប្រែនូវប្រភពផ្សេងៗ (រួមមាន វិឌីអូ សំណុំទិន្នន័យ និងឯកសារបណ្តុះបណ្តាលនានា) ទៅជាភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច
- ផ្តល់អាទិភាព ដល់ការដោះស្រាយភាពមានកំណត់នៃបច្ចេកវិទ្យាព័ត៌មាន ក្នុងនោះរួមមានការបញ្ចូលតភ្ជាប់បណ្តាញឌីជីថល ទៅកាន់តំបន់ជនបទដោយឯករាជ្យ
- ស្នើឱ្យមានចូលរួមរបស់ស្ត្រីកាន់តែច្រើនក្នុងឆាកនយោបាយ និងសង្គមសេដ្ឋកិច្ច
- ពង្រឹងសមត្ថភាពរបស់ស្ត្រីនៅគ្រប់វិស័យ
- លើកទឹកចិត្តផ្តល់អាទិភាពចំពោះស្ត្រីគ្រប់ស្ថានភាព

- ផ្តល់យោបល់ និងកែលំអររាល់បញ្ហាដែលកើតមានចំពោះស្ត្រី និងក្មេងស្រី
- បង្ការនិងទប់ស្កាត់បញ្ហាងាយរងគ្រោះផ្សេងៗសម្រាប់ស្ត្រី និងក្មេងស្រី
- បង្កើនការឃោសនាជម្រុញឱ្យស្ត្រីធ្វើការងារសង្គមឲបានច្រើន
- បង្កើតឱ្យមានចំនួនមណ្ឌលសុខភាពនៅតំបន់ដាច់ស្រយាលឱ្យបានច្រើនជាងមុន
- កាត់បន្ថយការប៉ះពាល់ជាអវិជ្ជមានទៅលើស្ថានភាពស្ត្រីនៅកន្លែងធ្វើការ។

# ឯកសារយោង

# ឯកសារយោង

## ១. សៀវភៅ ទ្រឹស្តី

- នីតិរដ្ឋធម្មនុញ្ញ
- នីតិរដ្ឋបាលទូទៅ របស់បណ្ឌិត សាយ បូរី
- នីតិរដ្ឋបាលទូទៅ របស់អនុបណ្ឌិត ហៀង សាង
- នីតិរដ្ឋបាលទូទៅ របស់សាស្ត្រាចារ្យ ឌឿក ពិដោរ
- ទ្រឹស្តីរដ្ឋបាលសាធារណៈ របស់សាស្ត្រាចារ្យ ឌឿក ពិដោរ

## ២. សៀវភៅឯកទេស

- នារីរតនៈទី៤ ឆ្នាំ២០១៤-២០១៨
- វឌ្ឍភាពស្ត្រីក្នុងវិស័យនយោបាយ លោកស្រី កឹម កែវធីតា និងលោកស្រី ជា ម៉ាលីកា ឆ្នាំ២០១៦
- ស្ថានភាពស្ត្រីនៅកម្ពុជា Natalie Hacks ឆ្នាំ២០០៤

## ៣. បទដ្ឋានគតិយុត្តជាតិ

- ព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ២២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
  - ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១
  - ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពី ការបង្កើតក្រសួងកិច្ចការនារី នៅក្នុង មាត្រា១-៣
- ព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ២២
  - អនុក្រឹត្យលេខ ១៣ អនក្រ.បក អនុក្រឹត្យចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥

## ៤. គេហទំព័រ

- គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/216267-2021-10-15-02-13-19.html
- គេហទំព័រ https://ncdd.gov.kh/news-kh/gender-lead-to-happiness/
- គេហទំព័រ https://khmerhistorydiscovery.wordpress.com/2020/06/16/khd-57-learn-baley-khmer/
- គេហទំព័រ https://thmeythmey.com/?page=detail&id=37262
- គេហទំព័រ https://ams.com.kh/central/detail/937786
- គេហទំព័រ https://freshnewsasia.com/index.php/en/
- គេហទំព័រ https://www.cambodia4point0.org/kh/women-and-tech
- គេហទំព័រ https://cam.kasenpost.com/?p=4191
- គេហទំព័រ https://vayofm.com/news/detail/121377-801.html

- គេហទំព័រ https://m.freshnewsasia.com/index.php/en/localnews/302829-2023-08-03-10-10-25.html
- គេហទំព័រ https://www.popular.com.kh/social/792122.html/
- គេហទំព័រ https://cambodia.ohchr.org/sites/default/files/Treaty/CEDAW_KH.pdf
- គេហទំព័រ https://cambodia.ohchr.org/sites/default/files/Treaty/CEDAW_KH.pdf
- គេហទំព័រ https://www.undp.org/sites/g/files/zskgke326/files/migration/kh/b31d3c182752d96158600ebbb9a6e20a156d485cc24f28cd8fa2f689fb25933e.pdf

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** លោកយាយដូនពេញ

**ឧបសម្ព័ន្ធទី២៖** ព្រះនាងឥន្ទ្រទេវី

**ឧបសម្ព័ន្ធទី៣៖** លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី

**ឧបសម្ព័ន្ធទី៤៖** អ្នកនាង រស់ រតនៈ ( Chef Nak )

**ឧបសម្ព័ន្ធទី៥៖** វិស័យសុខាភិបាល

**ឧបសម្ព័ន្ធទី៦៖** វិស័យបច្ចេកវិទ្យាឌីជីថល

## ២. ឧបសម្ព័ន្ធគតិយុត្តជាតិ

**ឧបសម្ព័ន្ធទី១៖** ព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ២២ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ លោកយាយដូនពេញ







# ឧបសម្ព័ន្ធទី២៖ ព្រះនាងឥន្ទ្រទេវី










## ឧបសម្ព័ន្ធទី៣៖ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី

លោកទំទាវបណ្ឌិត ពេជ ចន្ទមុន្នី បានទទួលសិទ្ធិធ្វើជាម្ចាស់ផ្ទះរៀបចំសន្និបាតកាយឬទ្ធិនារីពិភពលោក លើកទី៣៩ នៅឆ្នាំ២០២៩





## **ឧបសម្ព័ន្ធទី៤៖ អ្នកនាង រស់ រតនៈ**( Chef Nak )

អ្នកនាងបានចាប់ផ្តើមចងក្រងសៀវភៅធ្វើម្ហូបដំបូងនៅឆ្នាំ២០១៩ ក្រោមចំណងជើងថា **«ញ៉ាំ»**



អ្នកនាងត្រូវបានគេចាត់ទុកជាមេចុងភៅស្រីល្បីឈ្មោះដំបូងនៅកម្ពុជាដែលបាននាំយកម្ហូបខ្មែរទៅកាន់ឆាកពិភពលោកក្រោមចំណងជើង **«សោយ»** រហូតបានឈ្នះរង្វាន់ **Gourmand Award** ជាសៀវភៅធ្វើម្ហូបល្អបំផុតនៅលើពិភពលោក



## ឧបសម្ព័ន្ធទី៥៖ វិស័យសុខាភិបាល

**រដ្ឋមន្ត្រី ម៉ម ប៊ុនហេង** បានមានប្រសាស៍ថា៖ ស្ត្រីជាង៥០% កំពុងបំពេញការងារក្នុងវិស័យសុខាភិបាល ហើយស្ត្រីពិតជាដើរតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកលើកស្ទួយវិស័យសុខាភិបាល និងប្រទេសជាតិ





# ឧបសម្ព័ន្ធទី៦៖ វិស័យបច្ចេកវិទ្យាឌីជីថល








# ឧបសម្ព័ន្ធគតិយុត្តជាតិ

# ព្រះរាជក្រម

នស/រកម/០១៩៦/២២

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២.នស ៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# ការបង្កើតក្រសួងកិច្ចការនារី

មាត្រា ១.-

ត្រូវបានបង្កើតក្រសួងកិច្ចការនារីចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២.-

ក្រសួងកិច្ចការនារីមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ក្រសួងកិច្ចការនារីត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារីដែលអាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤.-

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥.-

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥

**សម្រេច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំបណ្តាអង្គភាពនៃក្រសួងកិច្ចការនារី និងកំណត់បេសកម្មរបស់ក្រសួង ព្រមទាំងមុខការ នៃអគ្គាធិការដ្ឋាន អគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា។

## ជំពូកទី ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងកិច្ចការនារី ត្រូវរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

**ក្រសួងកិច្ចការនារី មានមុខងារ និងភារកិច្ចដូចតទៅ :**

- ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការអនុវត្តន៏គោលនយោបាយជាតិ ដើម្បីធានាឱ្យស្ត្រីទទួលបាននូវផលប្រយោជន៏ដូចបុរស និងលើកកម្ពស់ស្ថានភាពរបស់ស្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញ សម្របសម្រួល តស៊ូមតិដើម្បីស្វែងរកការគាំទ្រ តាមដាន និងត្រួតពិនិត្យវាយតម្លៃការអនុវត្តគោលនយោបាយជាតិ និងកម្មវិធីផ្សេងៗ ក្នុងគោលដៅលើកកម្ពស់ស្ថានភាពស្ត្រី
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ មន្ទីរខេត្ត ក្រុង ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការអភិវឌ្ឍន៏ដែលពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយជាតិ គោលនយោបាយមូលដ្ឋាន និងកម្មវិធីផ្សេងៗ ព្រមទាំងដើម្បីបង្កើនសមាមាត្រ នៃការចូលរួមរបស់ស្ត្រី ឱ្យបានជាអតិបរមាក្នុងក្រសួង ស្ថាប័នជាតិគ្រប់ថ្នាក់ តាំងពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន
- សិក្សា ស្រាវជ្រាវ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ និងបង្កើនឋានៈតួនាទីរបស់ស្ត្រី
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ជំរុញដំណើរការកម្មវិធី ជួយដល់ស្ត្រី ជាពិសេសស្ត្រីចាស់ជរា ឬគ្មានទីពឹង ឬពិការ ឬមេម៉ាយ ស្ត្រី និងកុមារ

រងគ្រោះដោយជម្ងឺអេដស៍ ដោយការជួញដូរ រងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី រួមមានការចាប់រំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារជាដើម

- ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកកម្ពស់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យមផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ផ្តល់លទ្ធភាពក្នុងការទទួលនូវសេវាឥណទាន និងបង្កើតមុខរបរសម្រាប់ស្ត្រី
- រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយព័ត៌មាន ប្រឆាំងនឹងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ
- ជំរុញឱ្យស្ត្រី និងកុមារ ទទួលនូវសិទ្ធិការពារតាមផ្លូវច្បាប់ និងដោយយុត្តិធម៌ តាមរយៈការធ្វើជាអ្នកដើមបណ្តឹងជូសមុខឱ្យជនរងគ្រោះទៅតុលាការ និងការដាក់បញ្ចូលទៅក្នុងច្បាប់ ការអនុវត្តន៍ច្បាប់ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការអប់រំឱ្យបានជាអតិបរមា
- ជំរុញឱ្យស្ត្រី និងកុមារ ទទួលការថែទាំសុខភាពបឋម ការប្រើប្រាស់សេវាថែទាំក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព ជាពិសេសុខភាពបន្តពូជ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងការលើកស្ទួយស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ
- ជំរុញការចូលរៀន និងកាត់បន្ថយការបោះបង់ចោលការសិក្សារបស់សិស្សស្រីនៅគ្រប់កម្រិត ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ព្រមទាំងបង្កើនអក្ខរភាព និងជំនាញរបស់ស្ត្រី
- លើកកម្ពស់សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ តាមរយៈការផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាព ដូចជា ឯកសារបោះពុម្ព វិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទំនើប ។ល។ និងលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងការរៀបចំកម្មវិធីនេះ
- ជំរុញការអនុវត្តន៍អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី នាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទណ្ឌកម្ម ការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ បំពេញបន្ថែមឱ្យអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង ព្រមទាំងច្បាប់ និងអនុសញ្ញាអន្តរជាតិដទៃទៀត ដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី និងកុមារ ។

**មាត្រា ៤.-**

ក្រសួងកិច្ចការនារី មានរចនាសម្ព័ន្ធដូចតទៅ :

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន

- បន្តកម្មវិធីឥណទាន ផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារគ្រប់កម្រិត និងប្រែក្លាយកម្មវិធីនេះទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុ

នាយកដ្ឋាន អភិវឌ្ឍន៍សេដ្ឋកិច្ច ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧

## អគ្គនាយកដ្ឋាន អភិវឌ្ឍន៍សង្គម

**មាត្រា ១៥.-**

អគ្គនាយកដ្ឋាន អភិវឌ្ឍន៍សង្គម មានភារកិច្ចធ្វើជាសេនាធិការជូនក្រសួងលើការងារ :

- ទំនាក់ទំនងសម្របសម្រួល គ្រប់គ្រងការងារពាក់ព័ន្ធ និងការការពារផ្លូវច្បាប់ លើកកម្ពស់សុខភាព និងការអប់រំស្ត្រី
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ដឹកនាំដោយអគ្គនាយកមួយរូប ដែលមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម មាននាយកដ្ឋានចំណុះចំនួន ៣ ដូចខាងក្រោម :

- នាយកដ្ឋាន ការពារផ្លូវច្បាប់
- នាយកដ្ឋាន ស្ត្រី និងសុខភាព
- នាយកដ្ឋាន ស្ត្រី និងការអប់រំ ។

**មាត្រា ១៦.-**

**នាយកដ្ឋាន ការពារផ្លូវច្បាប់** មានភារកិច្ច :

- រៀបចំគោលការណ៍ និងគោលនយោបាយ ដើម្បីការពារផ្លូវច្បាប់ដល់ស្ត្រី និងក្មេងស្រី
- រៀបចំ តាក់តែង សេចក្តីព្រាងច្បាប់ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ ដើម្បីការពារស្ត្រី ក្មេងស្រី ឱ្យចាកផុតពីអំពើហិង្សា និងការកេងប្រវ័ញ្ច ហើយធានាបាននូវសមភាព និងសមធម៌យេនឌ័រ
- ចូលរួមផ្តល់យោបល់ក្នុងការតាក់តែងអត្ថបទច្បាប់ ដែលរៀបចំដោយស្ថាប័នផ្សេងៗ ដែលពាក់ព័ន្ធស្ត្រី និងកុមារ

- រៀបចំឱ្យមានជាអនុស្សារណៈនៃការយោគយល់គ្នាជាមួយប្រទេសជិតខាង ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ជាពិសេស្ត្រី និងកុមារ និងកិច្ចការពារជនរងគ្រោះ និងតាមដានការអនុវត្តន៍ច្បាប់ បទប្បញ្ញត្តិ អនុស្សារណៈនានា ឱ្យមានប្រសិទ្ធភាព
- កសាងសមត្ថភាពមន្ត្រី បុគ្គលិកក្រសួងតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ខេត្ត ក្រុង និងក្រសួងពាក់ព័ន្ធ អំពីផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងស្ត្រី និងកុមារនឹងសិទ្ធិមនុស្ស លើមូលដ្ឋាននៃសមភាពយេនឌ័រ ខ្លឹមសារអនុសញ្ញា ពិធីសារអន្តរជាតិ និងអនុស្សារណៈ នៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការពហុភាគីនានា ដែលពាក់ព័ន្ធដល់ស្ត្រី
- កសាងសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត របស់ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ អំពីការទប់ស្កាត់រាល់រូបភាព នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងជំនាញពិគ្រោះយោបល់ផ្នែកច្បាប់ និងផ្នែកចិត្តសាស្ត្រ
- សម្របសម្រួល ដើម្បីស្វែងរកការប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្នែកចិត្តសាស្ត្រដល់ជនរងគ្រោះ និងបញ្ជូនបន្តទៅសេវានានារបស់អង្គការក្រៅរដ្ឋាភិបាល ដែលអាចជួយពួកគេបាន
- សម្របសម្រួល និងជំរុញអន្តរាគមន៍តាមផ្លូវច្បាប់ ដល់ជនរងគ្រោះដោយការជួញដូរ ដោយអំពើហិង្សាក្នុងគ្រួសារ ដោយការចាប់រំលោភសេពសន្ថវៈ ឬដោយការរំលោភបំពានដទៃទៀត
- ធ្វើជាអ្នកដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះទៅតុលាការ
- អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីគ្រោះថ្នាក់ និងផលវិបាកនៃអំពើហិង្សាប្រឆាំងស្ត្រី និងការជួញដូរផ្លូវភេទ
- ទំនាក់ទំនង និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អ្នកផ្តល់ជំនួយ ដើម្បីអនុវត្ត និងរក្សានិរន្តរភាពការងារផ្នែកការពារផ្លូវច្បាប់ ជាពិសេសការធ្វើអន្តរាគមន៍ជួយជនរងគ្រោះ ។

នាយកដ្ឋាន ការពារផ្លូវច្បាប់ ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៧.-**

**នាយកដ្ឋាន ស្ត្រី និងសុខភាព** មានភារកិច្ច :

- ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព ស្ត្រី កុមារ មាតា និងទារក ដោយផ្តល់ព័ត៌មានស្តីពីសុខភាពអនាម័យ អាហារូបត្ថម្ភ ធ្វើការផ្សព្វផ្សាយអប់រំ អំពីសិទ្ធិ និងលទ្ធភាពទទួលបាននូវសេវាថែទាំសុខភាព ដែលមានសុវត្ថិភាព ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តតាមបណ្តាខេត្ត ក្រុង និងសហគមន៍នានា ដើម្បីធ្វើការងារនេះ

- ស្វែងរកការគាំទ្រពីថ្នាក់ដឹកនាំរបស់ស្ថាប័នពាក់ព័ន្ធ បញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នទាំងឡាយ នូវការលើកកម្ពស់យុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ការថែទាំនិងការគាំទ្រ ដល់អ្នកផ្ទុកមេរោគអេដស៍
- ចរាចរ និងតស៊ូមតិ ដើម្បីឱ្យស្ថាប័នពាក់ព័ន្ធអនុវត្តគោលនយោបាយ និងសេចក្តីណែនាំអំពីការផ្តល់ សេវាសុខភាពដោយឥតគិតថ្លៃ និងប្រើប្រាស់មូលនិធិសមធម៌
- ពង្រឹងសមត្ថភាពមន្ត្រី បុគ្គលិករបស់ក្រសួង និងក្រុមជំនាញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យយល់ពីសិទ្ធិរបស់ស្ត្រី កុមារ ដើម្បីទទួលនូវសេវាថែទាំសុខភាពបឋម ជាពិសេសសុខភាពបន្តពូជ
- ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីសុខភាពស្ត្រី និងកុមារ ។

នាយកដ្ឋាន ស្ត្រី និងសុខភាព ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៨.-**

**នាយកដ្ឋាន ស្ត្រី និងការអប់រំ** មានភារកិច្ច :

- ផ្សព្វផ្សាយ អប់រំ អំពីសារៈសំខាន់ នៃការអប់រំសម្រាប់ស្ត្រី និងក្មេងស្រី សារៈសំខាន់នៃការថែទាំទារក និងកុមារ ទាំងរាងកាយ និងបញ្ញាស្មារតី ព្រមទាំងបង្កើនការយល់ដឹង អំពីសិទ្ធិកុមារ និងសិទ្ធិស្ត្រី ក្នុងការទទួល នូវការអប់រំ
- សហការជាមួយក្រសួងអប់រំយុវជន និងកីឡា អង្គការ ស្ថាប័នជាតិ និងអង្គការអន្តរជាតិ ដើម្បីបន្តអភិវឌ្ឍន៍គោលនយោបាយ និងកម្មវិធីអប់រំកុមារតូច លើកកម្ពស់ការអប់រំរបស់កុមារី អក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធ រួមមាន ការផ្តល់អាហាររូបករណ៍ និងកម្មវិធីផ្តល់អាហារតាមសាលារៀន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើត និងគ្រប់គ្រងអន្តេវាសិកដ្ឋាន សម្រាប់សិស្សស្រី និងទារកដ្ឋាន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើជាគ្រូអក្ខរកម្ម និងអ្នកថែទាំកុមារ ដែលមានជំនាញ និងរៀបចំការបំប៉នសមត្ថភាពបច្ចេកទេសទៅតាមតម្រូវការជាក់ស្តែង
- សម្របសម្រួលក្នុងការបើកថ្នាក់អក្ខរកម្ម និងកន្លែងថែទាំកុមារ នៅតាមភូមិគោល និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី

នាយកដ្ឋាន ស្ត្រី និងការអប់រំ ដឹកនាំដោយប្រធានមួយរូប ដែលមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។